ទស្សនាវដ្តីនៃមជ្ឈមណ្ឌលឯកសារកម្ពុជា

# ស្វែងរកការពិត



- ១៧ មេសា ២០២១
- ប៉ុល ពត និងចលនាខ្មែរក្រហមបានស្លាប់ទៅជាមួយគ្នា
- ការចងចាំរបស់កងទ័ពខ្មែរក្រហមនៅថ្ងៃ ១៧ មេសា ឆ្នាំ១៩៧៥

ចែកជូនដោយឥតគិតថ្លៃដល់មន្ទីរ ស្រុក និងឃុំ ទូទាំងព្រះរាជាណាចក្រកម្ពុជា

លេខ២៥៦ ខែមេសា ឆ្នាំ២០២១

# ទស្សនាវដ្តីនៃមជ្ឈមណ្ឌលឯកសារកម្ពុជា

លេខ ២៥៦ ខែមេសា ឆ្នាំ២០២១



យោធាខ្មែរក្រហមចូលក្នុងទីក្រុងភ្នំពេញ
នៅថ្ងៃទី១៧ ខែមេសា ឆ្នាំ១៩៧៥។
(បណ្ណសារមជ្ឈមណ្ឌលឯកសារកម្ពុជា)

## មាតិកា

**សំបុត្រ**

◆ ១៧ មេសា ២០២១.........................១

◆ ប៉ុល ពត និងចលនាខ្មែរក្រហមបានស្លាប់..... ៣

**ផ្នែកឯកសារ**

◆ ប៉ុយ កែវ ហៅ បួខាវ លេខាស្រុកកុកឡាក់...៧

**ផ្នែកប្រវត្តិសាស្ត្រ និងការស្រាវជ្រាវ**

◆ ភូមិកោះថ្មនៅមុន និងក្នុងសម័យសង្គ្រាម ... ១០

◆ ទូច ឈាង៖ នីរសារកងវរសេនាធំ៨១២... ១៣

◆ ខ្ញុំរង់ចាំពុកដល់ថ្ងៃលិចមិនឃើញ............១៦

◆ ជីវិតតស៊ូជាមួយខ្មែរក្រហម................ ២១

◆ ឡុង យ៉ំ៖ រៀបរាប់រឿងរ៉ាវក្នុងរបបខ្មែរ .... ២៦

◆ ខ្មែរក្រហម និង ថៃក្រហម ................ ២៩

◆ កប៉ាល់របស់ចិនបានដឹកទំនិញចេញពីឃ្លាំង.. ៣៣

**ផ្នែកច្បាប់**

សាលក្រមសំណុំរឿង០០២/០២ .............. ៣៦

**ផ្នែកវេទិកាសាធារណៈ**

◆ ការចងចាំពីថ្ងៃទី១៧ ខែមេសា ........... ៤៥

◆ ការចងចាំរបស់កងទ័ពខ្មែរក្រហមនៅ ថ្ងៃ ១៧ មេសា ឆ្នាំ១៩៧៥ ...............៤៨

◆ ជ្រុងមួយនៃព្រឹត្តិការណ៍ថ្ងៃទី១៧ ខែមេសា ឆ្នាំ១៩៧៥ ..............................៥២

◆ មាស យឹម ពីគ្រូបង្រៀនក្នុងរបបសង្គម.... ៥៦

**ផ្នែកស្រាវជ្រាវរកគ្រួសារ**

«ដេះដង់ធូលី» រឿងរ៉ាវចេញពីប្រជាជនថ្មីក្រោមរបបកម្ពុជាប្រជាធិបតេយ្យ

◆ ស៊ីវ សុខគា៖ អ្នកបើកតាក់ស៊ី ............... ៦០

**រក្សាសិទ្ធិ**
មជ្ឈមណ្ឌលឯកសារកម្ពុជា
អនុញ្ញាតឲ្យបោះពុម្ពផ្សាយដោយ
ក្រសួងព័ត៌មាននៃព្រះរាជាណាចក្រកម្ពុជា
ប្រកាសទេសរដ្ឋមន្ត្រី និងរដ្ឋមន្ត្រីក្រសួងព័ត៌មាន
លេខ៣៧/៥៣.មប្រក
ចុះថ្ងៃទី៣០ ខែតុលា ឆ្នាំ២០១៨
រូបថតឯកសារ៖ មជ្ឈមណ្ឌលឯកសារកម្ពុជា

**ស្នេរលេខនេះ៖** លី សុខឃាង, ដារ៉ារដ្ឋ មេត្តា, សុខ វណ្ណៈ, ហ៊ាន ពិសី, ភា រស្មី, អ៊ុន សុដាវី, គាត ស្រីខ្មែន, សួត វិចិត្រ, មេក វិន, ស៊ាង ចិន្តា, ឡុង ដានី, លី កុកឆាយ, ដេង ពង្សរ៉ាស៊ី, សូ ហាន់, វេនី ខកហ្មៀល និង ប៊ាង ពីវិន្ត,
**អ្នកនិពន្ធ និងស្រាវជ្រាវ៖** ដារ៉ារដ្ឋ មេត្តា **អ្នកបកប្រែ៖** អ៊ុន សុដាវី **និពន្ធនាយកទូទៅ៖** សោម ប៊ុនថន
**ជំនួយការនិពន្ធនាយក៖** អ៊ុន សុដាវី **ក្រាហ្វិកកុំព្យូទ័រ៖** លី សេនសូនីឡា **គ្រប់គ្រងការចែកផ្សាយ៖** ឆេង វ៉េង

Email: dccam@online.com.kh, Homepage: www.dccam.org, www.cambodiatribunal.org, www.cambodiasri.org

# ១៧ មេសា ២០២១

*លី កុកឆាយ*



វិមានឯករាជ្យ នៅថ្ងៃទី១៧ ខែមេសា ឆ្នាំ២០២១។ (សន លាក់/មជ្ឈមណ្ឌលឯកសារកម្ពុជា)



កងទ័ពកំពុងឈរយាមនៅលើមហាវិថី ហ្សាល់ ដឺហ្គោល ក្នុងក្រុងភ្នំពេញ នៅដើមឆ្នាំ១៩៧៩។ (បណ្ណសារមជ្ឈមណ្ឌលឯកសារកម្ពុជា)

ទីក្រុងភ្នំពេញប្រែជាមានសភាពស្ងប់ស្ងាត់ម្តងទៀត បន្ទាប់ពីរយៈពេល៤៦ឆ្នាំក្រោយរបបខ្មែរក្រហម។ នៅថ្ងៃទី១៧ ខែមេសា ឆ្នាំ ១៩៧៥ កងកម្លាំងខ្មែរក្រហមបានកាន់កាប់រាជធានីភ្នំពេញ។ ភ្លាមៗ បន្ទាប់ពីការប្រកាសអំពីជ័យជម្នះរបស់ខ្លួន ក្រុមខ្មែរក្រហមបានធ្វើឲ្យរាជធានីភ្នំពេញ ប្រែជាទីក្រុងដ៏ស្ងាត់ជ្រងំ គ្មានមនុស្សរស់នៅ ហើយទីប្រជុំជនដទៃទៀតនៅក្នុងប្រទេសកម្ពុជាក៏មានសភាពដូចគ្នាដែរ។ ប្រជាជនទាំងអស់ ត្រូវបានបង្ខំឲ្យចាកចេញពីទីក្រុង ហើយផ្លូវដែលមានសភាពអ៊ូអរបានប្រែទៅជាស្ងាត់ជ្រងំ និងគ្មានមនុស្សដើរ។

ថ្ងៃនេះ ដោយអនុវត្តតាមវិធានការសុខភាពសាធារណៈក្នុងការឆ្លើយតបនឹងការរីករាលដាលនៃជំងឺ



ផ្លូវនៅក្នុងសង្កាត់ស្ទឹងមានជ័យ ក្រុងភ្នំពេញនៅថ្ងៃទី១៧ ខែមេសា ឆ្នាំ២០២១។ (លី កុកឆាយ/មជ្ឈមណ្ឌលឯកសារកម្ពុជា)

*កូវីដ-១៩ ទីក្រុងភ្នំពេញត្រូវបានបិទខ្ទប់ ហើយប្រជាជនទាំងអស់ គឺតម្រូវឲ្យស្នាក់នៅក្នុងផ្ទះមិនចេញក្រៅ។*

*ទោះបីជាកាលៈទេសៈកាលពីថ្ងៃទី១៧ ខែមេសា ឆ្នាំ ១៩៧៥ និងកាលៈទេសៈសព្វថ្ងៃ មានសភាពខុសគ្នាខ្លាំងយ៉ាងណាក៏ដោយ ក៏យើងមិនអាចបដិសេធបានទេថា សភាពស្ងប់ស្ងាត់ និងភាពសង្ងៃតនៃទីក្រុងនាពេលបច្ចុប្បន្ននេះ ពិតជាបានរំឭកពីរឿងរ៉ាវរបស់ប្រទេសកម្ពុជាដែលត្រូវបានខ្ទេចខ្ទាំកាលពីពេលមុន។*

*នៅលើដងវិថីដែលលាតសន្ធឹងយ៉ាងវែង យើងអាចមើលឃើញតែរថយន្តសង្គ្រោះបន្ទាន់ប៉ុណ្ណោះ ដែលមានផ្ទុកបុគ្គលិកពេទ្យក្នុងឯកសណ្ឋានពណ៌ស កំពុងប្រញាប់ប្រញាល់ទៅដឹកជញ្ជូន និងថែទាំអ្នកជំងឺដែលទទួលរងការប៉ះពាល់ជាមួយជំងឺកូវីដ-១៩។*

*នៅពេលដែលខ្ញុំកំពុងសម្លឹងមើលទៅដងវិថី អ្នកជិតខាងវ័យចំណាស់ម្នាក់ ដែលខ្ញុំអាចមើលឃើញថា មុខរបស់គាត់មានពាក់ម៉ាស់ការពារផង បានដើរចូលមកជិតខ្ញុំ។ គាត់មានអាយុ៧០ឆ្នាំ។ គាត់បាននិយាយប្រាប់ខ្ញុំពីរឿងដែលយើងមិនអាចទទួលអបអរពិធីបុណ្យចូលឆ្នាំខ្មែរឆ្នាំនេះបាន។ គាត់បានប្រាប់ខ្ញុំ ពីការរីករាលដាលនៃជំងឺរាតត្បាតនាពេលបច្ចុប្បន្ន ដែលធ្វើឲ្យគាត់នឹកឃើញដល់រឿងរ៉ាវរបស់គាត់ក្នុងថ្ងៃទី១៧ ខែមេសា ឆ្នាំ១៩៧៥។ គាត់នៅចាំបានថា គាត់បានឃើញទាហានខ្មែរក្រហមស្លៀកពាក់ខ្មៅ ហើយអង្គុយនៅលើរថក្រោះដែលបើកបរតាមផ្លូវ។*

*ខ្ញុំបានបង្ហាញពីការចង់ដឹង ចង់ឮ ចំពោះរឿងរ៉ាវរបស់គាត់ ហើយខ្ញុំបានសួរគាត់ (កុង បៀវ) ថា តើមានរឿងរ៉ាវអ្វីទៀតដែលគាត់ចងចាំនៅពេលនោះ? បុរសចំណាស់បន្ត៖*

***«ភ្លាមៗបន្ទាប់ពីខ្មែរក្រហមកាន់កាប់រាជធានី អ្នកភ្នំពេញត្រូវបានជម្លៀសទៅកាន់ទីជនបទ ហើយខ្ញុំបានដើរអស់រយៈពេល៥ថ្ងៃ ទៅភាគខាងជើងនៃខេត្តព្រៃវែង។ ខ្ញុំត្រូវបានគេបញ្ជូនទៅដឹកប្រឡាយនៅបឹងស្នេហ៍ ហើយខ្ញុំធ្វើការរាល់ថ្ងៃចាប់ពីម៉ោង៥ព្រឹកដល់៥ល្ងាច តែគេឲ្យខ្ញុំហូបបបរពីរស្លាបព្រាប៉ុណ្ណោះ។ ក្មួយជាយុវជនកម្ពុជាជំនាន់ក្រោយ មានសំណាងណាស់ ព្រោះថាក្មួយមានផ្ទះស្នាក់នៅ អាហារហូបចុក សម្លៀកបំពាក់ស្លៀក និងគ្រូពេទ្យព្យាបាល។ ខ្ញុំចងចាំថា ខ្ញុំមិនមានអ្វីទាំងអស់នេះទេ នៅពេលខ្ញុំមានអាយុប្រហែលក្មួយក្នុងរបបខ្មែរក្រហម» ។***

*រឿងរ៉ាវរបស់គាត់បានធ្វើឲ្យខ្ញុំស្វែងយល់ពីឥទ្ធិពលនៃទស្សនៈ និងជាពិសេសទស្សនៈលើប្រវត្តិសាស្ត្រ។ ខ្ញុំដឹងថាការលំបាកក្នុងការជាប់បិទខ្ទប់រយៈពេល១៤ថ្ងៃនៅភ្នំពេញ គឺមិនអាចប្រៀបធៀបទៅនឹងការគ្រប់គ្រងរបស់ខ្មែរក្រហមជិត៤ឆ្នាំ ក្នុងរបបកម្ពុជាប្រជាធិបតេយ្យបាននោះទេ។*

*ការឆ្លើយតបរបស់រាជរដ្ឋាភិបាលកម្ពុជាចំពោះជំងឺរាតត្បាត គឺតម្រូវឲ្យមានការហាមឃាត់ការធ្វើដំណើរ និងសូម្បីតែការជួបជុំតាមទីសាធារណៈ។ វិធានការទាំងនេះមិនផ្អែកលើរបៀបវារៈនយោបាយ ឬមនោគមវិជ្ជានោះទេ ប៉ុន្តែជាការប្តេជ្ញាចិត្តចំពោះសុខភាពសាធារណៈ និងជួយសង្គ្រោះអាយុជីវិតប្រជាជនទូទៅ។ បើប្រៀបធៀបទៅនឹងការគ្រប់គ្រងប្រទេសរបស់ខ្មែរក្រហម ខ្មែរក្រហមបានជម្លៀសប្រជាជនចំនួនប្រមាណ២លាននាក់ ចេញពីទីក្រុង ដែលបណ្តាលឲ្យមានមនុស្សស្លាប់រាប់ពាន់នាក់។*

*ខ្ញុំជឿជាក់ថា ប្រទេសកម្ពុជាមានសមត្ថភាពក្នុងការយកឈ្នះលើការរីករាលដាលនៃជំងឺកូវីដ-១៩ ប្រសិនបើមនុស្សម្នាក់ៗប្តេជ្ញាគោរពតាមវិធានការសុខភាព និងបទបញ្ជារបស់រាជរដ្ឋាភិបាលកម្ពុជា ដែលការប្តេជ្ញាចិត្តនេះមិនត្រឹមតែជាការលះបង់ប្រយោជន៍បុគ្គលដើម្បីប្រយោជន៍សាធារណៈប៉ុណ្ណោះទេ ប៉ុន្តែថែមទាំងជាការបង្ហាញឲ្យឃើញនូវទស្សនៈវិស័យដ៏ប្រាកដប្រជាមួយ ក្នុងការស្វែងយល់អំពីស្ថានភាពបច្ចុប្បន្ន និងប្រវត្តិសាស្ត្រ។ សភាពស្ងប់ស្ងាត់ និងភាពសង្ងៃតនៃទីក្រុង បានផ្តិតយករូបភាពប្រទេសកម្ពុជាដែលត្រូវបានបំផ្លាញ។ ប៉ុន្តែអ្វីដែលនៅពីក្រោយរូបភាពទាំងនេះ គឺជាស្មារតីដ៏រឹងមាំរបស់ប្រជាជនកម្ពុជា ដែលបានរួបរួមគ្នាក្នុងគោលដៅរួមមួយ ក្នុងការយកឈ្នះលើការរីករាលដាលនៃជំងឺរាតត្បាតកូវីដ-១៩។*



*រង្វង់មូលស្ពានជ្រោយចង្វារត្រើយខាងលិច (ទល់មុខស្ពានទូតបារាំង) ក្នុងក្រុងភ្នំពេញ នៅពេលរសៀល ថ្ងៃទី១៧ ខែមេសា ឆ្នាំ២០២១។ (សោម ប៊ុនថន/មជ្ឈមណ្ឌលឯកសារកម្ពុជា)*

# ប៉ុល ពត និងចលនាខ្មែរក្រហម បានស្លាប់ទៅជាមួយគ្នា

*លី សុខឃាង*



*ប៉ុល ពត (រូបខាងស្តាំជួរមុខ) ជាមួយ វ៉ាង តុងស៊ិញ អនុប្រធានគណៈកម្មាធិការមជ្ឈិមបក្សកុម្មុយនីស្តចិន នៅខែវិច្ឆិកា ឆ្នាំ១៩៧៨។ (បណ្ណសារមជ្ឈមណ្ឌលឯកសារកម្ពុជា)*

ការស្លាប់របស់ ប៉ុល ពត កាលពីថ្ងៃទី១៥ ខែមេសា ឆ្នាំ១៩៩៨ បានធ្វើឲ្យអន្តរាយដល់ចលនាខ្មែរក្រហម នៅអន្លង់វែង ដែលធ្លាប់ជាតំបន់តស៊ូចុងក្រោយ។ ការស្លាប់នេះបានក្លាយជាសញ្ញាណនៃការកកើតឡើងនូវសន្តិភាព យុត្តិធម៌ និងការផ្សះផ្សាជាតិ និងជាការបើកសករាជថ្មីប្រកបដោយក្តីសង្ឃឹមសម្រាប់ប្រជាជនកម្ពុជាទៀតផង។ ទោះជាយ៉ាងណាក្តី សព្វថ្ងៃនេះ ប្រជាជនកម្ពុជា នៅតែបន្តសួរសំណួរមួយគឺថា តើ ប៉ុល ពត គួរតែមានចំណែកអ្វីខ្លះនៅក្នុងប្រវត្តិរឿងរ៉ាវរបស់ប្រទេសជាតិ ជុំវិញរបបវាលពិឃាត និងគ្រោះមហន្តរាយទាំងឡាយកាលពីចុងទសវត្សរ៍ឆ្នាំ១៩៧០?

ប៉ុល ពត ដែលមានឈ្មោះដើម សាឡុត ស បានកាន់តំណែងជានាយករដ្ឋមន្ត្រីនៃរបបកម្ពុជាប្រជាធិបតេយ្យ។ ប៉ុល ពត ត្រូវបានចងចាំថាជាមេគំនិតក្នុងការប្រព្រឹត្តអំពើប្រល័យពូជសាសន៍ ដែលបានឆក់យកអាយុជីវិតប្រជាជនកម្ពុជាប្រមាណជាពីរលាននាក់ នៅចន្លោះថ្ងៃទី១៧ ខែមេសា ឆ្នាំ១៩៧៥ រហូតដល់ថ្ងៃទី៦ ខែមករា ឆ្នាំ១៩៧៩។ បន្ទាប់ពីរបបរបស់ខ្លួនត្រូវបានបណ្តេញចេញ

ពីអំណាច ដោយរណសិរ្សសាមគ្គីសង្គ្រោះជាតិកម្ពុជា សហការជាមួយកងទ័ពវៀតណាម សមាជិកនិងកម្មាភិបាលរបស់ខ្លួនគ្រប់លំដាប់ថ្នាក់បានរត់បែកខ្ញែកមករស់នៅតាមបណ្ដោយព្រំដែនកម្ពុជាថៃ។ អ្នកខ្លះក៏បានស្វែងរកការជ្រកកោននៅក្នុងប្រទេសថៃ។ ខណៈពេលដែលក្រុមមេបញ្ជាការយោធានិងកម្មាភិបាលជាន់ខ្ពស់ជាច្រើន ប្រញាប់ប្រញាល់ប្រមែប្រមូលក្រុមរបស់ខ្លួនឡើងវិញ ដើម្បីត្រៀមបន្តការតស៊ូរយៈពេលយូរអង្វែងទៅមុខទៀត ក្នុងសេចក្ដីសង្ឃឹមថានឹងច្បមយកអំណាចមកវិញ ប៉ុល ពតក៏បានចាប់ផ្ដើមដំណើរត្រាច់ចររបស់ខ្លួនអស់រយៈពេល ១៨ឆ្នាំ នៅក្នុងប្រទេសកម្ពុជាផង និងប្រទេសថៃផង ។ ប៉ុល ពត បានឈប់សំចតនៅតាមគោលដៅជាច្រើន ក្នុងកិច្ចខិតខំប្រឹងប្រែងដើម្បីរស់រានមានជីវិត និងធ្វើឲ្យចលនាខ្មែរក្រហមមានភាពរស់រវើក។

ប៉ុល ពត និងមនុស្សជំនិតបំផុតរបស់ខ្លួន រួមមាន នួន ជា អតីតប្រធានសភាតំណាងប្រជាជនកម្ពុជានៃរបបកម្ពុជាប្រជាធិបតេយ្យ និងខៀវ សំផន អតីតប្រធានគណៈប្រធានរដ្ឋនៃរបបកម្ពុជាប្រជាធិបតេយ្យ បានរត់គេចចេញពីការត្រួតត្រារបស់វៀតណាមឆ្ពោះទៅកាន់សំឡូត និងខេត្តកោះកុង ក្នុងឆ្នាំ១៩៧៩។ ជាច្រើនសប្ដាហ៍ក្រោយមក ក្រុមរបស់ខ្លួនក៏បានរត់ចូលក្នុងទឹកដីថៃ និងខេត្តមួយចំនួននៅតាមបណ្ដោយព្រំដែនកម្ពុជាថៃ ដោយបានបង្កើតទីបញ្ជាការ ដើម្បីដឹកនាំបញ្ជាកងទ័ពខ្មែរក្រហមដែលនៅសេសសល់រហូតដល់ឆ្នាំ១៩៨២។ ប៉ុល ពត មិនឈប់នៅត្រឹមនោះឡើយ ដោយបានបន្តពង្រីកដែនគ្រប់គ្រងរបស់ខ្លួននៅត្រង់ចំណុច អូរស្មួស្ដី ដែលមានចម្ងាយ២ប្រាំគីឡូម៉ែត្រប៉ុណ្ណោះចូលមកក្នុងប្រទេសកម្ពុជាពីព្រំដែន។ អូរស្មួស្ដីត្រូវបានស្គាល់ថាជា មន្ទីរ៨៧ ដែលជាទីបញ្ជាការសឹកដើម្បីគ្រប់គ្រងសភាពការណ៍សមរភូមិ តម្រង់ទិសការចរចា និងដាក់ឲ្យដំណើរការវិទ្យុផ្សាយសំឡេងរបស់កម្ពុជាប្រជាធិបតេយ្យ។

នៅក្នុងរដូវក្ដៅនាឆ្នាំ១៩៨៥ ប្រតិបត្តិការរបស់វៀតណាមបានវាយកម្ទេចមូលដ្ឋានទាំងអស់របស់ខ្មែរក្រហមនៅក្នុងទឹកដីកម្ពុជា និងបានបង្ខំឲ្យប៉ុល ពត និងក្រុមអ្នកដឹកនាំរបស់ខ្លួនដកថយទៅកាន់ខេត្តត្រាត នៃប្រទេសថៃ។ នៅទីនោះ ប៉ុល ពត បានបង្កើតមន្ទីរចំនួនបីគឺ



ប៉ុល ពត (សា ឡុត ស) និងកូនស្រី ស ផត្ថតា នៅឆ្នាំ១៩៨៦។
(បណ្ណសារមជ្ឈមណ្ឌលឯកសារកម្ពុជា)

ផ្ទះ៥០ ដែលជាទីតាំងរបស់ខ្លួនផ្ទាល់ ផ្ទះ២០ ដែលជាទីតាំងរបស់ នួន ជា និងខៀវ សំផន និង ក១៨ ដែលជាសាលានយោបាយមជ្ឈិមបក្ស។ បន្ទាប់ពីការដកថយជាផ្លូវការរបស់វៀតណាមពីប្រទេសកម្ពុជានៅឆ្នាំ១៩៨៩ ប៉ុល ពត ត្រូវការពេលវេលាបីឆ្នាំបន្ទាប់ពីនោះទៀត ដើម្បីមកតាំងទីនៅត្រង់ភ្នំឆ័ត្រ ដែលមានក្មួយប្រុសរបស់ខ្លួនឈ្មោះ សូ ហុង នៅទីនោះស្រាប់ និងបន្តទៅកាន់ជប់គគីរទៀត។ នៅទីតាំងនេះ ប៉ុល ពត បានដឹកនាំបញ្ជាកងពល៥១៩ដោយផ្ទាល់ នេះបើតាមអ្នកផ្ដល់សម្ភាសន៍។ ខណៈពេលដែលរាជរដ្ឋាភិបាលបានបើកការវាយប្រហារលើទីតាំងខាងលើនេះ ប៉ុល ពត បានធ្វើបន្លាស់ទីជាលើកចុងក្រោយឆ្ពោះទៅកាន់អន្លង់វែង នៅក្នុងឆ្នាំ១៩៩៣ (ឬនៅក្នុងឆ្នាំ១៩៩៤) ដោយមានជំនួយពី ឈិត ជឿន ហៅតាម៉ុក ដែលជាមេបញ្ជាការនៅទីនោះ។ អន្លង់វែង

បានក្លាយជាក្តីសង្ឃឹមចុងក្រោយរបស់ ប៉ុល ពត ក្នុងការរក្សាចលនានេះឲ្យមានភាពរស់រវើក និងអាចទាមទារបាននូវការគ្រប់គ្រងកម្លាំងដែលនៅសេសសល់។

ទំនាក់ទំនងរវាងប៉ុល ពត និង តាម៉ុកមានភាពល្អិងល្អរចត់ និងប្រែទៅជាការផ្តាច់ផ្តិលជីវិតទៅវិញ បន្ទាប់ពីប៉ុល ពត បានបញ្ជាឲ្យសម្លាប់សុន សេន អតីតរដ្ឋមន្ត្រីក្រសួងការពារជាតិរបស់កម្ពុជាប្រជាធិបតេយ្យ និងក្រុមគ្រួសារនៅក្នុងខែមិថុនា ឆ្នាំ១៩៩៧។ ទង្វើរបស់ប៉ុល ពត បានជុតបញ្ឆេះឲ្យមានការវាយប្រយុទ្ធគ្នារយៈពេល៥ថ្ងៃរវាងកងកម្លាំងដែលស្មោះស្ម័គ្រជាមួយខ្លួន និងកងកម្លាំងដែលស្មោះស្ម័គ្រជាមួយតាម៉ុក។ នៅទីបំផុត ប៉ុល ពត ត្រូវបានចាប់ខ្លួន។ អ្នកនៅក្រោមបង្គាប់របស់តាម៉ុកបានកាត់ទោស ប៉ុល ពត ដោយបានការចូលរួមពីមនុស្សប្រមាណ៤០០នាក់។ ប៉ុល ពត ត្រូវបានដាក់ឲ្យជាប់ឃុំនៅក្នុងផ្ទះ រហូតដល់គាត់ស្លាប់ដោយជំងឺគាំងបេះដូងនៅថ្ងៃទី១៥ ខែមេសា ឆ្នាំ១៩៩៨។ ការស្លាប់របស់គាត់បានជះឥទ្ធិពលយ៉ាងខ្លាំងទៅលើចលនាខ្មែរក្រហម និងដំណើរផ្សះផ្សាជាតិ។

ទីមួយ ការស្លាប់របស់ ប៉ុល ពត បានបង្កឲ្យមានការបែកខ្ញែក និងលែងជឿទុកចិត្តគ្នាកាន់តែខ្លាំងឡើងរវាងសមាជិក និងកម្មាភិបាលខ្មែរក្រហមគ្រប់លំដាប់ថ្នាក់។ ខណៈពេលដែលអ្នកខ្លះនៅមានភាពភ័យខ្លាចនៃការបន្តធ្វើបន្សុទ្ធកម្មផ្ទៃក្នុងសមាជិកនិងកម្មាភិបាលជាច្រើនទៀត ខឹងសម្បារនឹងការកាត់ទោសនោះទៀតផង។ ហែម ភិន អតីតទាហានខ្មែរក្រហមម្នាក់នៅអន្លង់វែង ដែលមានវ័យ៧៦ឆ្នាំ បានចាត់ទុកការស្លាប់របស់ប៉ុល ពត ថាជា «ការបាក់ទឹកចិត្តហើយគិតថាខ្លួនលែងមានមេដឹកនាំតទៅទៀតហើយ»។ ចំណែក ពាញ ញឿន អតីតសមាជិកខ្មែរក្រហមនៅអន្លង់វែង ដែលមានវ័យ៦០ឆ្នាំ បានអះអាងថា ការកាត់ទោស ប៉ុល ពត ផុសចេញពីការប្រេះឆាផ្ទៃក្នុង និងជាទង្វើក្បត់របស់ តាម៉ុក ។

សពរបស់ប៉ុល ពត ត្រូវបានបូជានៅថ្ងៃទី១៧ ខែមេសា ដែលមានរយៈពេល២៣ឆ្នាំគត់ ចាប់តាំងពីរបបខ្មែរក្រហមបានឡើងកាន់អំណាច និងបានជម្លៀសប្រជាជនចេញពីទីក្រុងនិងទីប្រជុំជននានា។ បច្ចុប្បន្ននេះ ទីតាំងបូជាសពត្រូវបានអភិរក្សជាតំបន់ប្រវត្តិសាស្ត្រមួយ ក្នុងចំណោម១៤ នៅក្នុងស្រុកអន្លង់វែង។ នៅមុនដំណាច់ឆ្នាំនោះ ចលនាខ្មែរក្រហមនៅអន្លង់វែងបានធ្វើសមាហរណកម្មចូលមកក្នុងសង្គមជាតិវិញ។

ទីពីរ ដោយសារតែ ប៉ុល ពត ត្រូវបានមើលឃើញថាជាអ្នកដឹកនាំដ៏សំខាន់របស់ចលនាខ្មែរក្រហមទាំងមូល ដែលជាមេដឹកនាំបែបនិកាយបុគ្គលតែម្នាក់ឯង ការស្លាប់របស់ ប៉ុល ពត ក៏មានន័យស្មើនឹងចុងបញ្ចប់នៃចលនាដែរ។ តាម៉ុកមិនទទួលបាននូវការគោរព ឬកិត្តិនាមដូចគ្នានេះទេក្នុងចំណោមកម្មាភិបាលខ្មែរក្រហម ដើម្បីដឹកនាំបន្តចលនានេះ។

បើពិនិត្យមើលពីផលប៉ះពាល់ប្រកបដោយមហន្តរាយរបស់ប៉ុល ពត មកលើប្រទេសទាំងមូលវិញ ប្រជាជនកម្ពុជានាពេលសព្វថ្ងៃនេះកំពុងព្យាយាមស្វែងយល់អំពីប្រវត្តិរឿងរ៉ាវនេះ។ ក៏ប៉ុន្តែ ប្រវត្តិរឿងរ៉ាវរបស់ប្រទេសជាតិមួយនៅតែពិបាកធ្វើឲ្យមានភាពស៊ីសង្វាក់ជាមួយប្រវត្តិសាស្ត្រ។ ដោយហេតុថាយើងមិនអាចបែងចែកឲ្យដាច់ស្រឡះពីគ្នា ថាតើនរណាជាជនរងគ្រោះ ហើយនរណាជាជនដៃដល់នៃអំពើឧក្រិដ្ឋកម្មខ្មែរក្រហម ប្រជាជននៅក្នុងសង្គមនៅតែមានការយល់ប្លែកៗគ្នាទៅលើបញ្ហានេះ។ ដំណើរការតុលាការ ការអប់រំ និងការស្រាវជ្រាវបែបសង្គមវិជ្ជា ពិតជាមានសារសំខាន់ក្នុងជួយដោះស្រាយបញ្ហាប្រឈមនៅក្នុងសង្គមជាតិបានខ្លះដែរ។

ដំណើរការយុត្តិធម៌នៃការដាក់ទោសទណ្ឌរបស់អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា ឬតុលាការខ្មែរក្រហម មានសារសំខាន់ៗ បេសកកម្មរបស់អង្គជំនុំជម្រះនេះគឺត្រូវនាំយកមកកាត់ទោសចំពោះ «មេដឹកនាំជាន់ខ្ពស់ និងអ្នកទទួលខុសត្រូវខ្ពស់បំផុតចំពោះបទឧក្រិដ្ឋកម្មដែលបានប្រព្រឹត្តឡើងនៅក្នុងរយៈកាលនៃកម្ពុជាប្រជាធិបតេយ្យ (១៩៧៥-១៩៧៩)» ។ អង្គជំនុំជម្រះក៏បានផ្តន្ទាទោសដាក់គុកអស់មួយជីវិតទៅលើអតីតមេដឹកនាំខ្មែរក្រហមចំនួនបីនាក់ រួមមាន នួន ជា ខៀវ សំផន និងកាំង ហ្កេកអ៊ាវ ហៅឌុច ដែលធ្លាប់ជាប្រធានគុកទួលស្លែង។ គុកទួលស្លែងគឺជាគុកដែលមនុស្សជាង១ម៉ឺន ៨ពាន់ត្រូវបានធ្វើទារុណកម្ម សួរចម្លើយ និងសម្លាប់។

លើសពីនេះទៀត ទីតាំងឧក្រិដ្ឋកម្ម បូជនីយដ្ឋានមន្ទីរសន្តិសុខ និងទីតាំងផ្សេងទៀតដែលជាប់ពាក់ព័ន្ធជា

មួយនឹងរបបខ្មែរក្រហម ត្រូវបានថែរក្សាទុកនៅទូទាំងប្រទេស។ សូម្បីតែ អន្លង់វែង ក៏មានទីតាំងប្រវត្តិសាស្ត្រចំនួន១៨កន្លែងដែរ ដោយរាប់បញ្ចូលទាំងទីតាំងបូជាសព ប៉ុល ពត។ ទីតាំងបូជាសព ប៉ុល ពត នេះ បាននិងកំពុងក្លាយជាទីតាំងដ៏ទាក់ទាញបំផុតមួយដែរសម្រាប់ទេសចរក្នុងស្រុក និងបរទេស ហើយជាពិសេសជាទីតាំងសម្រាប់សិស្សានុសិស្ស និងនិស្សិត ដើម្បីរៀនសូត្រពីប្រវត្តិសាស្ត្រនៃអំពើប្រល័យពូជសាសន៍ និងប្រវត្តិរឿងរ៉ាវបន្តបន្ទាប់មកជាច្រើនទៀត។ អន្លង់វែង គឺជាចំណុចគោលប្រវត្តិសាស្ត្រដ៏មានសារសំខាន់ ដែលឆ្លុះបញ្ចាំងពីអំពើរំលោភបំពានសិទ្ធិមនុស្សធ្ងន់ធ្ងរបំផុតរបស់ខ្មែរក្រហម។

អន្លង់វែងដែលធ្លាប់តំបន់តស៊ូចុងក្រោយរបស់ខ្មែរក្រហមនេះ មានប្រវត្តិសាស្ត្រដ៏វិសេសវិសាលមួយដែលស្តែងឲ្យឃើញពីបរិបទសង្គ្រាមផង និងសន្តិភាពផង។ អន្លង់វែងបានបង្ហាញឲ្យឃើញពីប្រវត្តិរឿងរ៉ាវផ្ទាល់ស្តីពីចលនាខ្មែរក្រហម ដោយសារតែ៨០ភាគរយនៃប្រជាជននៅទីនោះធ្លាប់បម្រើការជាមួយចលនានេះ។

ប្រវត្តិរឿងរ៉ាវ គួបផ្សំជាមួយនឹងការបង្រៀនអំពើរបបប្រល័យពូជសាសន៍របស់ខ្មែរក្រហម ត្រូវបានដាក់បញ្ចូលទៅក្នុងកម្មវិធីសិក្សា ដែលជាការខិតខំប្រឹងប្រែងដើម្បីប្រមូលផ្តុំនូវទស្សនៈផ្សេងៗគ្នាអំពីប្រវត្តិសាស្ត្រ។

ប្រវត្តិរឿងរ៉ាវរបស់ប្រទេសជាតិប្រកបដោយភាពគ្រប់ជ្រុងជ្រោយអាចធ្វើទៅបាន ដរាបណាទស្សនៈយល់ឃើញផ្សេងៗត្រូវបានទទួលយក។ ខៀន រ៉ុំ ដែលមានវ័យ៦៣ឆ្នាំ និងរស់នៅក្នុងខេត្តឧត្តរមានជ័យ និងក៏ជាដើមបណ្តឹងម្នាក់នៅឯអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជាបានគូសបញ្ជាក់ពីភាពចាំបាច់ក្នុងការរាប់បញ្ចូលព្រឹត្តិការណ៍ទាំងឡាយ និង សាច់រឿងរបស់បុគ្គលជាពិសេស រឿងរ៉ាវរបស់ ប៉ុល ពត គួរតែជាផ្នែកមួយនៃមេរៀនប្រវត្តិសាស្ត្រដែរ។ ការធ្វើបែបនេះ ប្រជាជនកម្ពុជាអាចពិភាក្សាអំពីតួនាទីរបស់ ប៉ុល ពត នៅក្នុងការបង្កើតឲ្យមានរបបវាលពិឃាត នៅក្នុងតុលាការ។ មានតែតាមរយៈការជជែកដេញដោលត្រង់ទៅត្រង់មកតែប៉ុណ្ណោះ ទើបយើងអាចជួយឲ្យអ្នករស់រានមានជីវិតទាំងឡាយផ្សះផ្សាជាមួយអតីតកាលបានខ្លះ។



កងកម្លាំងខ្មែរក្រហមនៅតំបន់អន្លង់វែង ធ្វើសមាហរណកម្មចុះចូលជាមួយរាជរដ្ឋាភិបាលកម្ពុជា នៅដើមឆ្នាំ១៩៩៩។ (បណ្ណសារមជ្ឈមណ្ឌលឯកសារកម្ពុជា)

# ប៊ុយ កែវ ហៅ បួខាវ លេខាស្រុកកុកឡាក់ តំបន់១០១ ភូមិភាគឦសាន

**ដារ៉ាវដ្ឋ មេត្តា**



*ជនជាតិភាគតិចដែលជាកងឈ្លបបដិវត្តន៍ខ្មែរក្រហមកំពុងដោតចម្រូង ការពារភូមិ នៅខេត្តរតនគិរី (ឆ្នាំ១៩៦៨-១៩៦៩)។ (បណ្ណសារមជ្ឈមណ្ឌលឯកសារកម្ពុជា)*

ខ្ញុំឈ្មោះ ប៊ុយ កែវ ហៅ បួខាវ មានអាយុ ៨០ឆ្នាំ នៅក្នុងឆ្នាំ១៩៧៧។ ខ្ញុំមានទីកន្លែងកំណើតនៅភូមិល្មៃ ឃុំកុកឡាក់ ស្រុកកុកឡាក់ តំបន់១០១ ភូមិភាគឦសាន។ ខ្ញុំមានឪពុកឈ្មោះ ប៊ុយ និងម្ដាយឈ្មោះ ចៀម។ ពុកម៉ែខ្ញុំគឺជាកសិករ ក្រោយមកពួកគាត់បានស្លាប់។ ខ្ញុំមានបងប្អូនបង្កើតទាំងអស់ចំនួន ៣នាក់គឺ ប្រុសចំនួន ២ និងស្រីចំនួន១នាក់។ ខ្ញុំមានប្រពន្ធម្នាក់ឈ្មោះ អៀម អម មានអាយុ២១ឆ្នាំ។ នាងគឺជាជនជាតិកាវែត។ ខ្ញុំរស់នៅជាមួយឪពុកម្ដាយខ្ញុំរហូតដល់ ឆ្នាំ១៩៥៣។ ក្រោយមកខ្ញុំបានចូលធ្វើជាទាហានបារាំងបានរយៈពេលប្រហែលបីខែ។

នៅក្នុងឆ្នាំ១៩៥៤ ខ្ញុំបានជួបជាមួយឈ្មោះ ហ៊ុម គឺជាអតីតប៉ូលីស នៅស្រុកវើនសៃ។ ហ៊ុម បាននាំខ្ញុំចូលធ្វើជាកងជីវពល។ បន្ទាប់មក ខ្ញុំបានជួបជាមួយចៅហ្វាយស្រុកវើនសៃ ឈ្មោះ ប៉ូរ៉ា ។ ចៅហ្វាស្រុក និង ហ៊ុម បានឲ្យខ្ញុំធ្វើជាគិញ ព្រមទាំងបានចាត់តាំងខ្ញុំ និងសមាជិកពីរនាក់ទៀតឈ្មោះ ទើន និង ពាក្យរ៍ ឲ្យទៅយកការណ៍នៅភូមិកាទន់ ស្រុកវើនសៃ តំបន់១០១ ។ នៅពេលខ្ញុំធ្វើជាគិញ ខ្ញុំក៏មានតួនាទីដើររកខ្មែរក្រហមនៅតាមមូលដ្ឋាន និងពង្រីកកម្លាំងគិញនៅក្នុងភូមិ។ ក្រោយមកប្រមូលបានព័ត៌មាន ខ្ញុំបានរាយការណ៍ទៅឲ្យចៅហ្វាយស្រុក។

នៅក្នុងឆ្នាំ១៩៥៦ ប៉ូរ៉ា បានឲ្យខ្ញុំធ្វើជាគិញដដែល។ គាត់បានចាត់តាំងខ្ញុំឲ្យមកយកការណ៍ ក្នុងស្រុកកុកឡាក់ ដែលក្រុមរបស់ខ្ញុំមានគ្នាបីនាក់ រួមមាន ខ្ញុំ, ចន និង ឈៀម។ យើងបានធ្វើសកម្មភាពពង្រីកកម្លាំងបានបីនាក់ទៀត មានឈ្មោះ លីន, ថី និង ប៊ុន។ ប៊ុន បានរត់ទៅប្រទេសឡាវ និងពីរនាក់ទៀតបានស្លាប់ពេលក្រោយមក។ ខ្ញុំបានទាក់ទងជាមួយឈ្មោះ ហឿង ធ្វើជាគ្រូបង្រៀន នៅស្រុកវើនសៃឲ្យជួយស្រាវជ្រាវរកក្រុមខ្មែរក្រហម។ បន្ទាប់ពីបានព័ត៌មានខ្ញុំក៏បានរាយការណ៍ទាក់ទងសកម្មភាពខ្មែរក្រហម ដែលកំពុងឃោសនាក្នុងចំណោមប្រជាជនឲ្យចៅហ្វាយស្រុកបានដឹង។ ក្រោយមក ខ្ញុំបានចូលរួមប្រជុំជាមួយចៅហ្វាយស្រុក ដែលមានសមាជិកប្រាំមួយនាក់ រួមមាន ហឿម អតីតប៉ូលីស ក្រោយមកបានរត់ទៅប្រទេសឡាវ, វ៉ៃន អតីតទាហាន, លាប អតីតស្មៀននៅសាលាស្រុក និង ភឿយ អតីតជំទប់លេខ៣ ដែលបច្ចុប្បន្នមានតួនាទីជាសមាជិកសហករណ៍ស្រុកវើនសៃ។

នៅក្នុងការប្រជុំលោក ចៅហ្វាយស្រុក បានដាក់ផែនការដើរស៊ើបការណ៍រកខ្មែរក្រហមតាមភូមិ, កសាង

កម្លាំងគិញតាមភូមិឃុំ, រក្សាទំនាក់ទំនងគ្នាទៅវិញទៅមក។ នៅពាក់កណ្តាលឆ្នាំ១៩៥៦ ខ្ញុំកសាងកម្លាំងបានបីនាក់មានឈ្មោះ ឆេវ, ដយ និង ដេង។ ឆេវ, ដយ និង ដេង បានស្លាប់នៅក្នុងឆ្នាំ១៩៦៤ ដោយបដិវត្តន៍ជាអ្នកកម្ទេច។

នៅក្នុងឆ្នាំ១៩៥៧ ខ្ញុំបានពិភាក្សាជាមួយឈ្មោះ អាត់ស៊ុយដង់, ឌីន, ភឹម ដែលជាទាហាន។ យើងបាននិយាយគ្នាអំពីយុទ្ធសាស្ត្រនៃការស៊ើបការណ៍ដោយលបស្តាប់តាមក្រោមផ្ទះប្រជាជននៅពេលយប់ ពេលប្រជាជនកំពុងប្រជុំ និងលបស្តាប់កន្លែងផ្លូវចេញចូល។ នៅដើមឆ្នាំ១៩៥៧ ខ្ញុំបានហៅកម្លាំងចាស់មកប្រជុំ និងអប់រំពីផែនការមួយចំនួន។ ឈាវ, ដយ ដែលជាកម្លាំងចាស់បានរាយការណ៍អំពីខ្មែរក្រហមដែលកំពុងឃោសនានៅភូមិកាឡាក់ និងភូមិរុក។ ក្រុមរបស់ខ្ញុំបានរាយការណ៍មកខ្ញុំរួចហើយខ្ញុំក៏រាយការណ៍ទៅចៅហ្វាយស្រុកបន្តទៀត។ បន្ទាប់មក ខ្ញុំបានឲ្យប៉ូលីសចុះទៅចាប់ក្រុមខ្មែរក្រហម។ នៅអំឡុងពេលនោះ ខ្ញុំកសាងកម្លាំងបានចំនួនពីរនាក់ទៀត គឺឈ្មោះ ដាន់ និង ឈ្មោះ ភឺន មានតួនាទីជាសមាជិកសហករណ៍នៅភូមិកងនាប់។

នៅក្នុងឆ្នាំ១៩៥៨ ខ្ញុំបានប្រជុំពង្រីកកម្លាំងចាស់ និងបានដាក់ផែនការស៊ើបការណ៍រកខ្មែរក្រហម ក្តាប់ចំនួនប្រជាជនដែលចូលរួមជាមួយខ្មែរក្រហម ត្រូវឲ្យមានទំនាក់ទំនងពីភូមិមួយទៅភូមិមួយ។ ក្រោយមកនៅឆ្នាំ១៩៦០ ខ្ញុំបានទាក់ទងជាមួយឈ្មោះ មាស គឺជាកាប៉ូរ៉ាល់ទាហាននៅបន្ទាយវើនសៃ។ យើងបានប្រជុំគ្នាដោយមានសមាជិកទាំងអស់ចំនួន ៥ចូលរួម ដើម្បីចែករំលែកពីបទពិសោធ៍តាមរកខ្មែរក្រហម និងបែងចែកទីតាំងព្រៃដើរតាមមុខព្រួញ។ នៅពេលនោះ ខ្ញុំកសាងកម្លាំងបានចំនួនពីរនាក់ទៀតឈ្មោះ សយ អតីតជំទប់ភូមិកោះកាក ក្រោយមកមាននាទីជាអនុលេខាឃុំកោះកាក ស្រុកកុកឡាក់ និង ថាត់ អតីតជីវពល នៅភូមិថាំង មាននាទីជាសមាជិកសហករណ៍ភូមិថាំង ស្រុក ស៤០។ នៅក្នុងឆ្នាំ១៩៦៧ ខ្ញុំបានដាច់ការទាក់ទងជាមួយចៅហ្វាយស្រុក ប៉ូរ៉ា។

នៅក្នុងឆ្នាំ១៩៦៣ ខ្ញុំបានចូលបដិវត្តន៍ នៅភូមិរុនទូច ឃុំកុកឡាក់ ស្រុកកុកឡាក់ តំបន់១០១ ដោយមាន ស្វាំង គឺជាអ្នកនាំចូល។

នៅក្នុងឆ្នាំ១៩៧០ ថង ឈើង បានខទ្ទេសនាមខ្ញុំឲ្យស្គាល់ប៊ុន ឡាប់ គឺជាគិញចាស់។ ឡាប់មានតួនាទីជាជាង នៅក្នុងតំបន់១០១។ នៅក្នុងឆ្នាំ១៩៧១ប៊ុន ឡាប់បាននាំខ្ញុំឲ្យស្គាល់ឈ្មោះស្វាត ជាមេគិញ ហើយបច្ចុប្បន្នគឺជាសេដ្ឋកិច្ចស្រុកស្រែពក តំបន់១០៤។ បន្ទាប់មកខ្ញុំបានធ្វើសកម្មភាពបំផុសមិនឲ្យប្រជាជនធ្វើបដិវត្តន៍ស្របតាមច្បាប់។ ខ្ញុំកសាងកម្លាំងបានចំនួនពីរនាក់ទៀតគឺ ឈន សហករណ៍ត្រពាំងវែង ស្រុកកុកឡាក់ និង ដាន់ ធ្វើជាងនៅក្នុងសហករណ៍ភូមិភ្នំគុត ស្រុកវើនសៃ។

នៅក្នុងឆ្នាំ១៩៧២ ស្វាត បានខ្ញុំឲ្យស្គាល់ឈ្មោះ សីឡា លេខាស្រុកស៊ីងត្រែង ដែលជាខ្សែគិញនៅស្រុកសៀមប៉ាង តំបន់១០៤ និងមានអនុលេខាឈ្មោះ វ៉ន់ ។ បន្ទាប់មកខ្ញុំបានធ្វើសកម្មភាពបំផុសប្រជាជនឲ្យស្នើសុំអំបិល និងក្រណាត់ ពីអង្គការ។

នៅក្នុងឆ្នាំ ១៩៧៣ ខ្ញុំបានបំផុសប្រជាជនឲ្យមានទំនាស់ជាមួយអង្គការដែលបានរៀបចំទៅជាសហករណ៍។ បន្ទាប់មក ខ្ញុំបានទាក់ទងជាមួយឈ្មោះ កាលាម តាមរយៈ ប៊ុន ឡាប់ តួនាទី គឺជាលេខាស្រុក ស៤០ តំបន់១០២ ដើម្បីរៀបចំគម្រោងទៅអនាគត។

នៅក្នុងខែមករា ឆ្នាំ១៩៧៤ ខ្ញុំបានប្រជុំជាមួយឈ្មោះ ថង ឈើង នៅក្នុងមន្ទីរស្រុកវើនសៃ ដែលមាន



អាវុធបុរាណដែលកងឈ្លបបដិវត្តន៍ខ្មែរក្រហមប្រើប្រាស់នៅក្នុងសង្គ្រាមផ្ទៃក្នុង ពីឆ្នាំ១៩៦៤ ដល់ ឆ្នាំ១៩៦៩។
(បណ្ណសារមជ្ឈមណ្ឌលឯកសារកម្ពុជា)

សមាជិកចំនួនប្រាំមួយនាក់ចូលរួមគឺ៖ ថង ឈើង, ប៊ុន ឡាប់, នូ លៃ, ប៊ុន អុម , ឈន និង ខ្ញុំ។ នៅក្នុងប្រជុំ យើងបានលើកឡើងអំពីការពិនិត្យលើចំណុចខ្សោយ និង ចំណុចខ្លាំងរបស់បដិវត្តន៍សម្រាប់បំផុសប្រជាជន និង កសាងកម្លាំងបន្ថែមទៀត។ ក្រោយពីការប្រជុំនៅក្នុងខែ មីនា ឆ្នាំ១៩៧៤ តាមរយៈ ប៊ុន ឡាប់ និង ខាំ ភី មាន តួនាទីជាអនុលេខាតំបន់១០១ បានអប់រំខ្ញុំឲ្យចូល សេ.អ៊ី.អា នៅក្នុងមន្ទីរស្រុកវើនសៃ ដែលមានអ្នកចូលរួមមាន ៖ នារី វ៉ាន់ ប្រធានកាត់ដេរតំបន់ ១០១, ថង ឈី លេខាស្រុក ២៣ តំបន់ ១០១, ផុស ប្រធានរោងចក្រអាររណើតំបន់ ១០១, ហ៊ីង ប្រធានពាណិជ្ជកម្មតំបន់១០១ និង ខ្ញុំ ដោយមានអ្នក ខន្មសនាមឈ្មោះ ប៊ុន ឡាប់ និងអ្នកទទួលស្គាល់ឈ្មោះ ខាំ ភី។ សមាជិកនៅក្នុងអង្គប្រជុំមានភារកិច្ចកសាងកម្លាំង សេ.អ៊ី.អា, ស៊ើបរកឃ្លាំងអាវុធ ឃ្លាំងអង្ករ ក្តាប់កងទ័ព រកមូលដ្ឋានបង្អែកលាក់កងទ័ពយួន និងក្តាប់សេដ្ឋកិច្ច ដើម្បីត្រៀមទុកចិញ្ចឹមទ័ពយួន។ នៅក្នុងខែកក្កដា ឆ្នាំ ១៩៧៤ ដដែល ខ្ញុំរកទីតាំងបានចំនួន ៣កន្លែង មាន ព្រៃ អូរទុង ខាងជើងស្រុកកុកឡាក់ ព្រៃចុងអូរកាអាន់ ស្ថិត នៅខាងជើងស្រុកកុកឡាក់ និង នៅកណ្តាលអូរកាឈាប ដែលជាព្រំប្រទល់ស្រុកកុកឡាក់ និងស្រុក៤១។

នៅក្នុងខែកុម្ភៈ ឆ្នាំ១៩៧៥ ខ្ញុំ, ខាំ ភី និង ប៊ុន ឡាប់ បានពិភាក្សាគ្នា និងចាត់តាំង អ៊ុំ ដែលមានតួនាទីជា អនុលេខាស្រុក ស៤០ និងនីរសារពីរនាក់ឈ្មោះ ញឹម និង យ៉ាំង ឲ្យទាក់ទងយួន។ ខាំ ភី បានសួរខ្ញុំអំពីផែនការត្រៀម ស្បៀង។ យើងបានត្រៀមស្បៀងតាមខ្សែរយៈនីមួយៗ បានចំនួនពី២០០ទៅ៣០០កំប៉ុង។ បន្ទាប់មក ខាំ ភី បាន ចាត់តាំងខ្ញុំឲ្យរៀបចំកន្លែងដែលរកបានទុកឲ្យយួន។

នៅខែមិថុនា ឆ្នាំ១៩៧៦ តាមរយៈ ខាំ ភី ខ្ញុំបានទាក់ ទងជាមួយឈ្មោះ ឡី គឺជាប្រធានវរសេនាធំ អង្គភាព ប្រចាំភូមិភាគឦសាន និង ឡេម គឺជាអនុប្រធានវរសេនាធំ ដើម្បីឲ្យ អិនដៀ, ឈី, ចាន់ ដើររកផ្លូវកាត់ពីស្រុក ២១ ទៅប្រទេសយួន ដើម្បីនាំទ័ពយួនចូលមក។ នៅក្នុងខែ កក្កដា ឆ្នាំ១៩៧៦ ខ្ញុំបានជួបជាមួយយួន នៅអូរឃ្លីម ដោយមាន ខ្ញុំ, ប៊ុន ឡាប់ និង ខាំ ភី។ ខាំ បានរាយការណ៍ អំពីការកសាងកម្លាំងបានបួននាក់ ក្នុងនោះមានកម្លាំង បង្កប់នៅក្នុងក្រសួងចំនួន៣នាក់ និង បានត្រៀមស្បៀង បានចំនួន៥០តោន។ ក្រោយមកខ្ញុំបានរាយការណ៍ បន្ថែម ដោយបានពង្រីកកម្លាំងបានពីរនាក់ ក្នុងនោះបង្កប់កម្លាំង នៅក្នុងកងទ័ពបានចំនួន១នាក់។ បន្ទាប់មកយួន បានដាក់ ផែនការពង្រីក និងពង្រឹងកម្លាំង, បង្កប់កម្លាំងបន្ថែមទៀត, ស៊ើបរកអាវុធ ស្បៀង ខោអាវ និង ត្រៀមស្បៀងអាហារ បន្ថែមទៀត។ យួនបានលើកអំពីទិសដៅ ប្រសិនបើមាន ស្បៀងគ្រប់គ្រាន់ នឹងវាយនៅក្នុងខែមេសា ឆ្នាំ១៩៧៧ ប៉ុន្តែប្រសិនបើមិនគ្រប់គ្រាន់ទេត្រូវលើកទៅខែវិច្ឆិកា ឆ្នាំ ១៩៧៧ វិញ។

ចាប់ពីខែតុលា ឆ្នាំ១៩៧៦ ដល់ខែមករា ឆ្នាំ១៩៧៧ នេះខ្ញុំមិនបានធ្វើសកម្មភាពអ្វីទាំងអស់ ដោយអង្គការឲ្យខ្ញុំ មករៀននៅភ្នំពេញ និង ដើរទស្សនកិច្ចតាមភូមិភាគ។ នៅខែមករា ឆ្នាំ១៩៧៧ ខ្ញុំបានជួបយួនបីនាក់ ដែលមាន ឈ្មោះ មុីង គឺជាប្រធាន នៅអូរឃ្លីម និងមាន ប៊ូខាវ, ខាំ ភី, ប៊ុន ឡាប់ និង អ៊ុំ ដែរ។ ខ្លឹមសារនៃការប្រជុំ ខាំ ភី បានរាយការណ៍ពីការបានបង្កើតកម្លាំងចាប់ពីខែ កក្កដា ឆ្នាំ១៩៧៦ មកបានចំនួន៦នាក់។ បង្កប់កម្លាំង ក្នុងមន្ទីរភូមិភាគបាន២នាក់។ ផ្នែកស្បៀងអាហារ មិនទាន់ បានប្រមូលទេ ព្រោះសមាជិកទាំងនោះទើបតែត្រឡប់មក ពីរៀន។ ក្រោយមកខ្ញុំបានរាយការណ៍បន្ថែមពីការរកផ្លូវ ទាក់ទងទៅខាងស្រុក ២២ ទៅស្រុក ២១ រហូតដល់ ប្រទេសវៀតណាមបានហើយ។ វៀតណាម បានណែនាំឲ្យ ត្រៀមស្បៀងទុកវាយបដិវត្តន៍ នៅខែមេសា ឆ្នាំ១៩៧៧ ហើយវៀតណាមបានឲ្យអាវុធចំនួន ២០ដើម ទុកសម្រាប់ បង្កើតទ័ព និង វិទ្យុទាក់ទងចំនួនពីរគ្រឿង គឺមួយគ្រឿងឲ្យ ខាំ ភី និង មួយគ្រឿងទៀតឲ្យ អ៊ុំ ។ ខ្ញុំជាមួយនីរសារពីរ នាក់គឺឈ្មោះ ឡូញ និង កាលី បានបន្តសកម្មភាពជាមួយ គ្នាចាប់តាំងពីឆ្នាំ១៩៧៤ រហូតដល់ខែមីនា ឆ្នាំ១៩៧៧ ក៏ត្រូវអង្គការចាប់ខ្លួន។ ខ្ញុំត្រូវបានសន្តិសុខគុកសួរចម្លើយ ដល់ថ្ងៃទី១២ ខែកក្កដា ឆ្នាំ១៩៧៧។

កំណត់ចំណាំ ៖ ចម្លើយសារភាពខាងលើដកស្រង់ចេញពី ឯកសារលេខ J00522។ រាល់ចម្លើយសារភាពរបស់អ្នក ទោសទាំងអស់នៅមន្ទីរសន្តិសុខស-២១ សុទ្ធតែឆ្លងកាត់ ការបង្ខិតបង្ខំ និងធ្វើទារុណកម្មធ្ងន់ធ្ងរពីកងសួរចម្លើយ របស់ខ្មែរក្រហម ដូច្នេះ យើងមិនអាចសន្និដ្ឋានបានថា ចម្លើយរបស់ ប៉ុយ កែវ ហៅ បូខាវ ពិតប្រាកដណានោះទេ។

# ភូមិកោះថ្មនៅមុន និងក្នុងសម័យសង្គ្រាម

សុខ វណ្ណៈ



ញឹក ជា ជនជាតិដើមភាគតិចស្មៀងកាត់ខ្មែរ សព្វថ្ងៃរស់នៅភូមិកោះថ្ម ឃុំទន្លូង ស្រុកមេមត់ ខេត្តកំពង់ចាម។ (សុខ វណ្ណៈ/មជ្ឈមណ្ឌលឯកសារកម្ពុជា)

ញឹក ជា គឺជាជនជាតិដើមភាគតិចស្មៀងកាត់ខ្មែរ និងមានស្រុកកំណើតនៅភូមិកោះថ្ម ឃុំទន្លូង ស្រុកមេមត់ ខេត្តកំពង់ចាម។ ញឹក ជា សព្វថ្ងៃមានអាយុ៨០ឆ្នាំ បានរៀបរាប់អំពីភូមិកោះថ្មកាលពីមុន និងក្នុងសម័យសង្គ្រាម ដូចខាងក្រោម៖

កាលពីដើមភូមិកោះថ្មមានឈ្មោះថា ភូមិអញ្ចាញលើ និងអញ្ចាញក្រោម។ នៅដើមទសវត្សរ៍ឆ្នាំ១៩៧០ នៅពេលដែលខ្មែរក្រហម (អ្នកភូមិហៅថា ក្រុមរណសិរ្សរួបរួមជាតិកម្ពុជា) បានចូលមកគ្រប់គ្រងភូមិអញ្ចាញ ខ្មែរក្រហមបានគិតថា ឈ្មោះភូមិអញ្ចាញពិបាកហៅ និងប្លែកពីឈ្មោះភូមិដទៃទៀត ម្យ៉ាងទៀតដោយឃើញមានផ្ទាំងថ្មធំៗបានដុះឡើងចំណុចកណ្តាលព្រៃកទន្លូងក្នុងភូមិសាស្ត្រភូមិអញ្ចាញរបៀបដូចជាកូនកោះ ខ្មែរក្រហមបានប្តូរឈ្មោះភូមិអញ្ចាញមកជាភូមិកោះថ្មវិញ។

ភូមិកោះថ្មស្ថិតនៅក្នុងឃុំទន្លូង ស្រុកមេមត់ ខេត្តកំពង់ចាម (បច្ចុប្បន្ន ខេត្តត្បូងឃ្មុំ)។ ភូមិកោះថ្ម គឺជាភូមិមួយក្នុងចំណោមភូមិជាច្រើនទៀត ដែលស្ថិតនៅតាមព្រំប្រទល់កម្ពុជា-វៀតណាម។ ប្រជាជនរស់នៅភូមិកោះថ្មភាគច្រើនគឺជាជនជាតិដើមភាគតិចស្មៀងប្រកបមុខរបរកាប់ព្រៃធ្វើចម្ការដាំស្រូវ។ ជនជាតិស្មៀងកាប់ឆ្ការព្រៃ

ដាំស្រូវបានរយៈពេលពីរទៅបីឆ្នាំរួចក៏ផ្លាស់ទៅធ្វើចម្ការដាំស្រូវ និងដាំដំណាំផ្សេងៗនៅកន្លែងថ្មីទៀត។ កាលពីមុនសម័យសង្គ្រាមភូមិកោះថ្មមានផ្ទៃដីធំទូលាយ ហើយប្រជាជនតិចតួចប៉ុណ្ណោះមានកម្មសិទ្ធិលើដីធ្លី។ ទីតាំងភូមិកោះថ្មនេះ មានលក្ខណៈងាយស្រួលដល់ប្រជាជនរស់នៅដូចជា៖ ទី១) មានដីធំទូលាយ ទី២) មានព្រៃឈើច្រើនសម្រាប់សង់លំនៅដ្ឋាន និង ទី៣) ងាយស្រួលរកម្ហូបពីព្រោះមានសត្វព្រៃច្រើនប្រភេទរស់នៅក្នុងតំបន់នោះដូចជា សត្វខ្លា ដំរី ជ្រូកព្រៃ ឈ្លូស ទន្សាយ ប្រើស និងពស់ ជាដើម។ កាលពីមុនសង្គ្រាម អ្នកភូមិកោះថ្ម ចេះសាមគ្គីគ្នា ហើយមានរបស់អ្វីមួយចែករំលែកគ្នា និងសង់លំនៅដ្ឋានតូចៗជាប់គ្នា និងរាប់អានគ្នាដូចបងប្អូនបង្កើត ប៉ុន្តែដោយសារតែសង្គ្រាមបានកើតឡើងជាច្រើនលើកច្រើនសារ បានធ្វើឲ្យប្រពៃណីវប្បធម៌របស់ភូមិកោះថ្មដែលជាជនជាតិដើមភាគតិចស្ទៀង ដូចជា ភាសានិយាយ សម្លៀកបំពាក់ប្រពៃណី ទំនៀមទម្លាប់ បាន បាត់បង់ស្ទើរទាំងស្រុង។

ខ្ញុំមានឪពុកឈ្មោះ ញឹក ម្ដាយឈ្មោះ អ៊ឹម និងមានបងប្អូនប្រុសពីរនាក់។ ខ្ញុំគឺជាកូនទីមួយនៅក្នុងគ្រួសារ ហើយកាលពីក្មេងខ្ញុំមិនបានរៀនសូត្រទេ។ ពេលខ្ញុំមានអាយុ១០ឆ្នាំ ឪពុករបស់ខ្ញុំបានស្លាប់ចោលខ្ញុំដោយសារកើតជំងឺហើមពោះ។ រយៈពេលប្រហែលជាពីរឆ្នាំបន្ទាប់ពីឪពុករបស់ខ្ញុំបានស្លាប់ទៅ ម្ដាយរបស់ខ្ញុំក៏បានស្លាប់ចោលខ្ញុំទៀតដោយសារជំងឺហើមដូចគ្នា។ ចាប់តាំងពីពេលនោះមក ខ្ញុំបានរស់នៅជាមួយម្ដាយមីង និងជួយធ្វើស្រែចម្ការគាត់រហូតដល់ខ្ញុំអាយុ១៦ឆ្នាំ ទើបខ្ញុំបួសជាព្រះសង្ឃនៅវត្តក្ដុល។ ខ្ញុំបួសបានរយៈពេល៣វស្សាក៏លាចាកសិក្ខាបទ មកជួយធ្វើស្រែចម្ការម្ដាយមីងវិញ។

នៅអំឡុងឆ្នាំ១៩៦០ ខ្ញុំបានរៀបអាពាហ៍ពិពាហ៍ជាមួយឈ្មោះ ឈុន លាង នៅភូមិក្ដុលដែលជាអ្នកភូមិនៅជិតគ្នា។ ពេលរៀបការហើយខ្ញុំបានមករស់នៅខាងប្រពន្ធប្រកបមុខរបរធ្វើស្រែចម្ការ នឹងមានកូនចំនួន៦នាក់ ស្រី២នាក់និងប្រុស៤នាក់។ នៅពេលនោះ មេភូមិក្ដុលបានចាត់តាំងឲ្យខ្ញុំជួយការពារភូមិ និងការពារផ្លូវលំនៅតាមព្រំដែន កម្ពុជា-វៀតណាម ដោយខ្លាចក្រែងមានចោរព្រៃ ឬមានហេតុការណ៍អ្វីកើតឡើង។ នៅជំនាន់នោះទំនាក់ទំនងរវាងប្រជាជនកម្ពុជា និងប្រជាជនវៀតណាមដែលនៅជាប់ព្រំដែនជាមួយគ្នាល្អប្រសើរ គឺមានការចេញចូលទៅវិញទៅមកបានស្រួល។ យើងអាចដើរចេញចូលក្នុងទឹកដីវៀតណាមបានចម្ងាយប្រហែល ៧ ទៅ ៨ គីឡូម៉ែត្របានយ៉ាងស្រួល ដូច្នេះហើយទើបអ្នកភូមិកោះថ្មដែលមានសាច់ញាតិបងប្អូននៅប្រទេសវៀតណាម ក្នុងភូមិស្រែត្នោត ស្រុក ឡុកនិញ ខេត្តសុងប៊ែ ចេញចូលទៅមករកគ្នាជាញឹកញាប់។

ពេលនោះខ្ញុំរួមជាមួយអ្នកភូមិកោះថ្ម អ្នកភូមិក្ដុល អ្នកភូមិស្វា បាននាំគ្នារកស៊ីទិញអង្ករ ថ្នាំពេទ្យ និងសម្ភារផ្សេងៗទៀតពីស្រុកមេមត់ យកមកលក់ឲ្យកងទ័ពវៀតកុងនៅជាប់ព្រំដែនកម្ពុជា-វៀតណាម ម្ដុំទួលនេត្យ ដែលមានចម្ងាយប្រមាណជាង ១០គីឡូម៉ែត្រ ពីភូមិកោះថ្ម ដោយមានប្រជាជនខ្លះដឹកទំនិញតាមកង់ អ្នកខ្លះរែក និងខ្លះទៀតដឹកតាមរទេះគោ។ ការលក់ដូរជាមួយកងទ័ពវៀតកុងមានភាពងាយស្រួល និងបានចំណេញប្រាក់ច្រើន។ បន្ទាប់មកទៀត ទាហានសហរដ្ឋអាមេរិកបានស៊ើបការណ៍ដឹងថា កងទ័ពវៀតកុង បានមកលាក់ខ្លួននៅក្នុងទឹកដីខ្មែរ ហើយយន្តហោះបានមកទម្លាក់គ្រាប់បែកយ៉ាងសន្ធឹកសន្ធាប់នៅតាមបណ្ដោយព្រំដែនកម្ពុជា-វៀតណាម ជាពិសេសនៅភូមិកោះថ្ម និងភូមិផ្សេងៗទៀតនៅឃុំទន្លុង ឃុំជាំក្រវៀន ឃុំតាម៉ៅ ក្នុងស្រុកមេមត់ ខេត្តកំពង់ចាម។

នៅថ្ងៃទី១៨ ខែមីនា ឆ្នាំ១៩៧០ មានព្រឹត្តិការណ៍កើតឡើង ដោយសារសេនាប្រមុខ លន់ នល់ បានធ្វើរដ្ឋប្រហារទម្លាក់សម្ដេចព្រះ នរោត្តម សីហនុ។ ពេលនោះខ្ញុំ និងប្រជាជនកោះថ្មទាំងប្រុស ទាំងស្រី បាននាំគ្នាទៅធ្វើបាតុកម្មទាមទារសម្ដេចឪមកវិញ។ យើងនាំគ្នាឡើងជិះរថយន្តធុនធំរបស់ក្រុម ហ៊ុនចម្ការកៅស៊ូនៅស្រុកមេមត់។ ប្រជាជនទាំងនោះមិនមានកាំភ្លើងទេ គឺនៅក្នុងដៃមានតែដំបង កាំបិត ពូថៅសំដៅទៅទីក្រុងភ្នំពេញ ប៉ុន្តែពេលទៅដល់ត្រឹមក្រុងកំពង់ចាម ក៏ត្រូវទាហាន លន់ នល់ ស្ទាក់ ដោយយករថពាសដែកដាក់យាំងនៅចំកណ្ដាលផ្លូវមិនឲ្យធ្វើដំណើរទៅមុខរួច ដូច្នេះប្រជាជនទាំងនោះ ក៏ធ្វើដំណើរមកភូមិកំណើតវិញ។ បន្ទាប់មកខ្ញុំបានស្ដាប់ពុការប្រកាសរបស់សម្ដេចឪតាមវិទ្យុពីក្រុងប៉េកាំងមកថាឲ្យកូនចៅចូលព្រៃម៉ាគីដើម្បីរំដោះជាតិ ។ ពេលនោះខ្ញុំដឹងថា មានឈ្មោះ ណាល់ ដែលសព្វថ្ងៃសម្ដេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន, ម៉ាន់, ឆយ, នាល,

ញ៉ាន់ និងមានយុវជនមួយចំនួនទៀត បានស្ម័គ្រចិត្តចូលព្រៃម៉ាគីតាមការអំពាវនាវរបស់សម្តេចឪ។

នៅអំឡុងឆ្នាំ១៩៧០ ដដែល សង្គ្រាមក៏ចាប់កើតមានឡើងជាបន្តបន្ទាប់រវាងក្រុមចលនាបដិវត្តន៍ខ្មែរក្រហមជាមួយទាហាន លន់ នល់។ នៅពេលនោះខ្ញុំបានឃើញទាហានសហរដ្ឋអាមេរិកមកបោះបន្ទាយនៅភូមិកោះថ្ម នៅភូមិស្វា ដោយមានទាំងរថក្រោះ និងខ្ទម្ពាគបក្រទៀតផង។ ខ្ញុំបានឃើញ ទាហានសហរដ្ឋអាមេរិកមានទាំងស្បែកស និងស្បែកខ្មៅ។ នៅពេលនោះ ក្រុមចលនាបដិវត្តន៍ខ្មែរក្រហម បានសហការជាមួយកងទ័ពវៀតកុងវាយតទល់នឹងទាហានសហរដ្ឋអាមេរិក និងទាហានធីវគី (ទាហានវៀតណាមខាងត្បូង)។ កាលនោះប្រជាជននៅភូមិកោះថ្ម ភូមិស្វា ភូមិក្តុល និងភូមិផ្សេងទៀតសុទ្ធតែទទួលរងគ្រោះដោយសារការទម្លាក់គ្រាប់បែក និងសង្គ្រាម។ រយៈពេលពីរទៅបីខែក្រោយមក ទាហានសហរដ្ឋអាមេរិក និងទាហានធីវគី បានដកកងទ័ពចេញពីភូមិកោះថ្ម ភូមិស្វា ភូមិពងទឹក និងភូមិផ្សេងទៀតទៅវិញអស់។

នៅថ្ងៃ១៧ មេសា ឆ្នាំ១៩៧៥ ខ្មែរក្រហមបានឡើងកាន់អំណាច។ មុនដំបូងខ្មែរក្រហមឲ្យប្រជាជននៅភូមិកោះថ្ម និងភូមិក្តុលធ្វើការងារស្រែចម្ការជារបៀបប្រវាស់ដៃ ដោយចែកស្រូវអង្ករតាមចំនួនសមាជិកគ្រួសារ។ នៅអំឡុងឆ្នាំ១៩៧៥ ដដែល ខ្ញុំបានឃើញវត្តមានយោធាខ្មែរក្រហមរាប់រយនាក់មកបោះបន្ទាយនៅភូមិកោះថ្ម និងបន្ទាយ៧៥។

នៅ១៩៧៦ ខ្មែរក្រហមបានបង្កើតជាសហករណ៍ហូបបាយរួម ហើយចាប់ផ្តើមប្រមូលទ្រព្យសម្បត្តិឯកជនដូចជាមាសប្រាក់ដីស្រែចម្ការ គោ ក្របី ចាន ឆ្នាំង ដាក់ជាទ្រព្យសម្បត្តិរួម។ នៅពេលនោះ គណៈឃុំទន្លូង មានឈ្មោះ តាចែម តាអ៊ុម តាញឹម និង ប៊ុន សារី។ ចាប់ពីឆ្នាំ១៩៧៦ រហូតដល់ពាក់កណ្តាលឆ្នាំ១៩៧៧ ប្រជាជនរស់នៅភូមិកោះថ្ម និងភូមិក្តុល បានរស់នៅ និងហូបចុកនៅក្នុងសហករណ៍ ប៉ុន្តែមិនទាន់ខ្វះខាតប៉ុន្មានទេ។ ទោះបីយ៉ាងណា ប្រជាជនត្រូវធ្វើស្រែ ចម្ការ លើកទំនប់ ជីកប្រឡាយ ខ្លះទៅធ្វើការនៅតាមកងចល័តដោយមិនបានរស់នៅជួបជុំគ្នាឡើយ ហើយយូរៗម្តងទើបបានជួបគ្នា។

នៅចុងឆ្នាំ១៩៧៧ ខ្ញុំបានដឹងថា មានព្រឹត្តិការណ៍មួយកើតឡើងនៅភូមិភាគបូព៌ាដោយ មេដឹកនាំខ្មែរក្រហមបានចោទថា ខាងភូមិភាគបូព៌ាក្បត់។ យោធាមកពីមជ្ឈិមបានចុះមកចាប់កងទ័ព និងកម្មាភិបាលខាងបូព៌ារួមមានគណៈស្រុក គណៈតំបន់ រួមទាំងប្រធានយោធាស្រុកតាមូង ស្រុកមេមត់មួយចំនួនយកទៅបាត់។ បន្ទាប់មកខ្មែរក្រហមបានជម្លៀសប្រជាជននៅភូមិកោះថ្ម ភូមិក្តុល ភូមិចង្កុំ និងភូមិជាប់ព្រំដែនវៀតណាមទាំងអស់ឲ្យមករស់នៅភូមិស្រែតាពិជ និងភូមិកូនក្រពើ ក្នុងឃុំជាំតាម៉ៅ ស្រុកមេមត់រយៈពេល៥ ទៅ ៦ខែ ទើបជម្លៀសបន្តឲ្យទៅរស់នៅខេត្តក្រចេះ។ ពេលរស់នៅក្នុងខេត្តក្រចេះប្រជាជនមិនមានអាហារហូបចុកគ្រប់គ្រាន់ទេ និងមានប្រជាជនស្លាប់ច្រើនទៀត។ ខ្ញុំជាមួយក្រុមគ្រួសារ ប្រពន្ធកូន ឪពុកម្តាយក្មេក និងបងប្អូន បានចាកចេញពីភូមិកំណើតដោយអង្គការបានប្រាប់ថា រស់នៅភូមិកំណើតមិនបានទេ ព្រោះមានសង្គ្រាមជាមួយប្រទេសវៀតណាម។

នៅចុងឆ្នាំ១៩៧៨ ខ្មែរក្រហមបានដឹកប្រជាជនតាមកាណូតពីខេត្តក្រចេះមកកាន់ភូមិភាគកណ្តាល និងតំបន់ផ្សេងៗទៀត។ ខ្ញុំ និងគ្រួសារក៏ត្រូវបានជម្លៀសទៅភូមិភាគកណ្តាល ដោយនៅទីនោះមានការលំបាកខ្លាំងណាស់ ព្រោះគ្មានអាហារហូបចុកគ្រប់គ្រាន់ និងមានមនុស្សច្រើនស្លាប់ដោយសារអត់មានអាហារ។ ទោះបីយ៉ាងណា ខ្មែរក្រហមនៅតែបន្តស្រាវជ្រាវរកយោធាភូមិភាគបូព៌ាដើម្បីយកទៅសម្លាប់ចោល។

នៅឆ្នាំ១៩៧៩ នៅពេលកងទ័ពស្ម័គ្រចិត្តវៀតណាមវាយចូលរំដោះប្រទេសកម្ពុជា ខ្ញុំបាននាំប្រពន្ធកូនត្រឡប់មកស្រុកកំណើតវិញ ដោយដើរតាមផ្លូវយប់ត្រង់ណាយើងសម្រាកត្រង់នោះ។ យើងត្រូវស្វែករកអង្ករ និងម្ហូបផងព្រមទាំងធ្វើដំណើរដោយថ្មើរជើងផង។ យើងបានចំណាយរយៈពេលជាង ១០ថ្ងៃ ទើបដើរមកដល់ស្រុកកំណើត។ ពេលមកដល់ភូមិដំបូង គឺខ្ញុំមិនទាន់ឃើញប្រជាជនចូលមករស់នៅច្រើនទេ គឺមានតែ ៧ទៅ៨ គ្រួសារប៉ុណ្ណោះ។ ក្នុងភូមិមានសភាពស្ងាត់។ យើងរស់នៅក្នុងភូមិបានរយៈពេលបួនប្រាំថ្ងៃ ទើបមានមនុស្សចូលមកជាបន្តបន្ទាប់ ប៉ុន្តែមានគ្រួសារខ្លះបានបាត់សមាជិកខ្លះ និងគ្រួសារខ្លះទៀតបានបាត់ខ្លួនទាំងអស់តែម្តង។ ក្រោយមក ខ្ញុំនិងប្រពន្ធនាំកូនចៅរកស៊ីលក់នំបញ្ចុកនៅក្នុងភូមិ និងធ្វើស្រែ ដើម្បីផ្គត់ផ្គង់ជីវភាពគ្រួសារ។

# ទូច ឈាង៖ នីរសារកងវរសេនាធំ៨១២

ហ៊ាន ពិសី




*ទូច ឈាង និង កូនប្រុស រស់នៅភូមិអូរគគីរលើ ឃុំលំទង ស្រុកអន្លង់វែង ខេត្តឧត្តរមានជ័យ។ ទូច ឈាង បានផ្តល់បទសម្ភាសន៍ទាក់ទងនឹងរឿងរ៉ាវក្នុងរបបខ្មែរក្រហមប្រាប់ដល់ ហ៊ាន ពិសី អ្នកស្រាវជ្រាវនៃមជ្ឈមណ្ឌលសន្តិភាពអន្លង់វែង។ (ហ៊ាន ពិសី/មជ្ឈមណ្ឌលឯកសារកម្ពុជា)*

ទូច ឈាង ភេទប្រុស អាយុ៥៩ឆ្នាំ មានទីកន្លែងកំណើតនៅភូមិយាង ឃុំយាង ស្រុកពួក ខេត្តសៀមរាប។ បច្ចុប្បន្ន ទូច ឈាង រស់នៅភូមិអូរគគីរលើ ឃុំលំទង ស្រុកអន្លង់វែង ខេត្តឧត្តរមានជ័យ បាននិយាយរៀបរាប់ដូចខាងក្រោមថា៖

នៅក្នុងឆ្នាំ១៩៧០ ប្រទេសកម្ពុជាចាប់ផ្តើមកើតមានព្រឹត្តិការណ៍រដ្ឋប្រហារទម្លាក់សម្តេចព្រះ នរោត្តម សីហនុ ដែលដឹកនាំដោយសេនាប្រមុខ លន់ នល់។ មួយឆ្នាំក្រោយមក ខ្មែរក្រហម បានជម្លៀសប្រជាជនទាំងអស់នៅក្នុងសង្កាត់យាង ទៅនៅភូមិដូនស្វា ស្ថិតនៅខាងកើតវត្តក្រឡាញ់។ នៅក្នុងឆ្នាំ១៩៧២ ខ្មែរក្រហមចាប់ផ្តើមរៀបចំឲ្យមានជាសហករណ៍ ហើយកម្មសិទ្ធិគ្រប់យ៉ាងត្រូវចាត់ចូលជាសម្បត្តិរួមទាំងអស់។ នៅពេលនោះជីវភាពប្រជាជនជួបនូវការលំបាកជាបន្តបន្ទាប់។

កាលណោះខ្ញុំនៅវ័យកុមារ ខ្មែរក្រហមបានចាត់តាំងខ្ញុំឲ្យធ្វើការងារកាប់ដើមទន្ទ្រានខែត្រធ្វើជី និងជីកដីដំបូក។ បន្ទាប់ពីសម្រាកពីធ្វើការងារ ខ្ញុំតែងឆ្លៀតពេលរៀនដោយខ្លួនឯងជាហេតុធ្វើឲ្យខ្មែរក្រហមសង្ស័យថា ខ្ញុំគឺជាកូនរបស់ក្រុមសក្តិភូមិ។ នៅខែតុលា ឆ្នាំ១៩៧៤ ខ្ញុំបានស្នើសុំប្រធានសហករណ៍ប្តូរទៅធ្វើការនៅមន្ទីរយោធាខាងស្រុក

វិញ។ នៅឆ្នាំ១៩៧៥ ពេលខ្ញុំធំឡើង ខ្មែរក្រហមបានជ្រើសរើសខ្ញុំឲ្យចូលធ្វើជាយោធា។

ដំបូងខ្ញុំយល់ថា ការចូលធ្វើជាយោធា ធ្វើឲ្យខ្ញុំសប្បាយ។ ប៉ុន្តែផ្ទុយស្រឡះពីការគិតរបស់ខ្ញុំ ខ្មែរក្រហមបានបញ្ជូនខ្ញុំទៅសមរភូមិមុខនៅបាខែងក្នុងខេត្តសៀមរាប។ ដោយភាពក្មេងខ្ចី ហើយគ្មានការហ្វឹកហាត់មុនពេលធ្វើសង្គ្រាម ធ្វើឲ្យខ្ញុំលំបាកយ៉ាងខ្លាំង រហូតធ្វើឲ្យខ្ញុំបាក់ស្បាតជាមួយនឹងស្នូរគ្រាប់កាំភ្លើង នៅក្នុងអំឡុងពេលប្រយុទ្ធគ្នា។ ក្រោយមក ខ្មែរក្រហមឈប់បញ្ជូនខ្ញុំទៅសមរភូមិ ហើយប្តូរខ្ញុំមកធ្វើជានីសាររបស់ តាប៉េង ដែលជាប្រធានកងវរសេនាធំ៨១២ ដែលមានបន្ទាយនៅក្បែរវត្តល្អក់ក្នុងខេត្តសៀមរាប។

របៀបនាំសារនៅពេលនោះ ខ្ញុំមានមធ្យោបាយពីរយ៉ាងគឺ ជិះកង់ និងជិះសេះ។ នៅអំឡុងពេលនោះ ដោយសារតែខ្ញុំជាមនុស្សជំនិតរបស់ប្រធានកងវរសេនាធំ៨១២ ខ្ញុំតែងឃើញមានភ្ញៀវចិនមកទស្សនកិច្ចនៅខេត្តសៀមរាប ហើយយោធានៅក្នុងកងវរសេនាធំ ៨១២ ចាំទទួលអមដំណើរភ្ញៀវចិនទាំងនោះ។ ខ្ញុំធ្លាប់ទៅទទួលក្រុមភ្ញៀវចិនចំនួនបីលើកនៅព្រលានយន្តហោះខេត្តសៀមរាប។ នៅពេលទៅទទួលភ្ញៀវចិនម្តងៗ ខ្ញុំត្រូវគោរពតាមការណែនាំមួយចំនួន ដូចជា ត្រូវស្លៀកសម្លៀកបំពាក់ពណ៌ខៀវព្រមទាំងមានក្រមាបង់ក ហើយម្យ៉ាងទៀត សម្រាប់តែអ្នកដែលមានតួនាទីជាប្រធានកងប៉ុណ្ណោះ ទើបអាចទៅអមដំណើរភ្ញៀវចិនបាន។ ក្រៅពីយោធា ខ្ញុំឃើញមានប្រជាជនជាច្រើនដែលបានស្លៀកសម្លៀកបំពាក់ពណ៌ខ្មៅឈរចាំអបអរសាទរ ខណៈពេលដែលភ្ញៀវចិនធ្វើដំណើរមកដល់ព្រលានយន្តហោះ។ ចំពោះដំណើរទស្សនកិច្ចរបស់ភ្ញៀវចិនទាំងនោះ គឺក្នុងបំណងអ្វី ឬទៅកាន់ទីកន្លែងណាខ្លះ គឺខ្ញុំមិនដឹងច្បាស់នោះទេ គ្រាន់តែដឹងថាបានទៅទស្សនកិច្ចប្រាសាទអង្គរវត្ត។ ចំណែកការហូបចុក នៅក្នុងមន្ទីកងវរសេនាធំ៨១២ ក៏ជួបការលំបាកច្រើនដែរ។ ពេលដែលប្រធានកងមិននៅ យើងពុំមានអាហារហូបចុកគ្រប់គ្រាន់ឡើយ។ ពេលខ្លះ ដោយសារតែអត់ឃ្លានខ្លាំងពេក យើងនាំគ្នាលួច មាន់ ទា របស់ប្រជាជនយកមកហូប។ ដោយឡែក ពេលដែលប្រធានកងនៅជាប់មូលដ្ឋាន ទើបយើងបានហូបឆ្អែត។



ប្រពន្ធរបស់ ទូច ឈាង នៅភូមិអូរគគីរលើ ឃុំលំទង ស្រុកអន្លង់វែង ខេត្តឧត្តរមានជ័យ។ (ហ៊ាន ពិសី/មជ្ឈមណ្ឌលឯកសារកម្ពុជា)

រហូតដល់ឆ្នាំ១៩៧៨ ខ្មែរក្រហមបានចាប់ផ្តើមរំសាយមន្ទីរកងវរសេនាធំ ៨១២ ចោល ក្រោមហេតុផលថា អ្នកខុត្តរក្បត់ និងចាប់ប្រធានកងវរសេនាធំ ៨១២ ប្រុកបាវយកទៅបាត់។ ចំណែកខ្ញុំ ខ្មែរក្រហមបានបញ្ជូនឲ្យមករស់នៅសហករណ៍វិញ ដោយមានប្រធានសហករណ៍ឈ្មោះ តាប៉ន។ ខ្ញុំគិតថា នៅសហករណ៍លែងលំបាកដូចមុនទៀតហើយ ប៉ុន្តែមិនដូចការគិតរបស់ខ្ញុំឡើយ គឺខ្ញុំនៅតែលំបាកដដែល។ ខ្ញុំត្រូវបានខ្មែរក្រហមបង្ខំឲ្យរែកដី និងធ្វើការស្ទើររាល់ថ្ងៃ។ ចំណែកការហូបចុកខ្ញុំទទួលបានរបបអាហារទៅតាមការកំណត់របស់ប្រធានសហករណ៍ក្នុងម្នាក់មួយចាន។ ជារឿយៗ នៅក្នុងសហករណ៍ខ្ញុំសង្កេតឃើញមានមនុស្សជាច្រើនត្រូវបានបាត់ខ្លួន ជាពិសេសអតីតទាហាន លន់ នល់។ សូម្បីតែប្អូនស្រីរបស់ប្រធានសហករណ៍ឈ្មោះ ជុក ដែលមានគ្រួសារជាអតីតកងទ័ពលន់ នល់ ក៏ត្រូវខ្មែរក្រហមយកទៅសម្លាប់ដែរ។ ខ្ញុំបានមកនៅសហករណ៍មិនដល់មួយខែផង ប្រធានសហករណ៍ចាប់ផ្តើមស្រាវជ្រាវ និងជ្រើសរើសឈ្មោះប្រជាជនបញ្ជូនទៅកងចល័ត។ ខ្ញុំស្ថិតនៅក្នុងចំណោមមនុស្សដែលត្រូវបានបញ្ជូនទៅលើកទំនប់កែងស្តៅ នៅក្នុងស្រុកពួក។

ខ្ញុំរស់នៅក្នុងកងចល័តរហូតដល់ឆ្នាំ១៩៧៩ កងទ័ពស្ម័គ្រចិត្តវៀតណាមវាយចូលមកប្រទេសកម្ពុជា។ អំឡុងពេលនោះ ប្រជាជនដែលនៅក្នុងកងចល័ត ត្រូវបានខ្មែរក្រហមបញ្ចូលឲ្យមកចូលកងយោធាវិញ ចំណែកខ្ញុំមិនបានចូលធ្វើជាយោធាទេ ព្រោះឮដំណឹងថាវៀតណាមនឹងចាប់យោធាខ្មែរក្រហមសម្លាប់ដោយអារកនឹងធាងត្នោត។ ដូច្នេះខ្ញុំ និងប្រជាជនផ្សេងទៀតនាំគ្នារត់ភៀសខ្លួនទៅខេត្តឧត្តរមានជ័យ។ ខ្ញុំបានភៀសខ្លួនទៅនៅភ្នំអាតោ ដែលស្ថិតនៅក្នុងស្រុកចុងកាល់ ហើយរស់នៅទីនោះជាមួយមេកងឈ្មោះ សុខ។ ខ្ញុំចាំបានថា ខ្ញុំរស់នៅនិងធ្វើការដឹកទំពាំងនៅភ្នំអាតោបានជិតមួយឆ្នាំ កងទ័ពស្ម័គ្រចិត្តវៀតណាមបានវាយលុកចូលមកដល់ ទើបខ្ញុំនិងប្រជាជនជាច្រើនផ្សេងទៀតចាប់ផ្ដើមរត់ភៀសខ្លួនឡើងភ្នំថ្មរោយ។

នៅក្នុងឆ្នាំ១៩៨៣ ខ្ញុំបានសម្រេចចិត្តចេញពីយោធាខ្មែរក្រហមទៅចូលរួមជាមួយ ទាហានប៉ារ៉ាវិញ ។ នៅឆ្នាំ១៩៨៧ ខ្ញុំបានមករៀបការប្រពន្ធនៅស្រុកកំណើតក្នុងខេត្តសៀមរាប។ កាលនោះ ខ្ញុំគ្រាន់តែរៀបចំពិធីសែនព្រេនដែលមានចាស់ទុំដឹងឮទាំងសងខាងប៉ុណ្ណោះ។ បន្ទាប់ពីរៀបចំពិធីចប់សព្វគ្រប់ ខ្ញុំក៏នាំប្រពន្ធធ្វើដំណើរមកកាន់ភ្នំដងរែក។ ឪពុកម្ដាយក្មេករបស់ខ្ញុំ ត្រូវរដ្ឋអំណាចហៅទៅសាកសួរ ដោយសារគាត់អនុញ្ញាតឲ្យកូនស្រីទៅតាមខ្ញុំ។ នៅអំឡុងពេលខ្ញុំធ្វើដំណើរ គឺមានតែពីរគ្រួសារតែប៉ុណ្ណោះ។ ខ្ញុំមានការលំបាកយ៉ាងខ្លាំង ដោយសារខ្ញុំធ្វើដំណើរក្នុងខែមេសា ដែលជារដូវប្រាំង ក្ដៅហួតហែងនិងគ្មានទឹកសម្រាប់ផឹក។ ខ្ញុំធ្វើដំណើរអស់រយៈពេលមួយយប់មួយថ្ងៃទើបយើងអាចរកទឹកផឹក រួចហើយបន្តដំណើរទៅមុខទៀត។ ខ្ញុំបានធ្វើដំណើរមកដល់ថ្គាមរមាស រួចហើយឡើងទៅកំពូលភ្នំស្រួចយ៉ាងត្រដាបត្រដួស។ ខ្ញុំនិងគ្រួសារបានរស់នៅភ្នំស្រួចរហូតដល់សភាពការណ៍ស្ងប់ស្ងាត់ ទើបខ្ញុំធ្វើដំណើរតាមរថយន្តចេញទៅជំរំសាយប៊ីប្រទេសថៃ។ ប៉ុន្តែខ្ញុំមិនបានទៅជំរំជាមួយប្រពន្ធទេ គឺខ្ញុំត្រូវបានមេកងវរបញ្ជូនខ្ញុំទៅរៀនយុទ្ធសាស្ត្រធ្វើសង្គ្រាមនៅប្រទេសម៉ាឡេស៊ីជំនួសគាត់ចំនួន ៦ខែ ដូច្នេះ ប្រពន្ធរបស់ខ្ញុំត្រូវទៅនៅជំរំតែម្នាក់ឯង។ ខ្ញុំបានជិះឡានពីបន្ទាយដីថ្មីនៅណាំង៉ីង ទៅខេត្តសុរិន្ទ ហើយឡើងជិះយន្តហោះនៅដនមឿន ប្រទេសថៃ។ ពេលទៅដល់ប្រទេសម៉ាឡេស៊ី ខ្ញុំត្រូវបានហ្វឹកហាត់បាញ់កាំភ្លើង, ដោះមីន, ដាក់មីន និងយុទ្ធសាស្ត្រផ្សេងៗដើម្បីក្លាយជាទ័ពព្រៃ។ បន្ទាប់ពីហ្វឹកហ្វឺនចប់ ខ្ញុំបានវិលត្រឡប់មកប្រទេសកម្ពុជាវិញ ហើយខ្ញុំបានរស់នៅជាមួយគ្រួសារក្នុងជំរំសាយប៊ី។ ប្រជាជននៅក្នុងជំរំសាយប៊ីទាំងអស់ទទួលបានជំនួយពីអង្គការសហប្រជាជាតិ ដែលមាន អង្ករ ស្បៀងអាហារ និងថ្នាំពេទ្យ។ សម្រាប់ស្ត្រីដែលមានផ្ទៃពោះបានទទួលថ្នាំប៉ូវ ឬចំណីអាហារសម្រាប់បំប៉នសុខភាពបន្ថែមទៀត។



ទូច ឈាង រួមជាមួយប្រពន្ធ និងកូនប្រុសរបស់គាត់ នៅភូមិអូរគគីរលើ ឃុំលំទង ស្រុកអន្លង់វែង ខេត្តឧត្តរមានជ័យ។
(ហ៊ាន ពិសី/មជ្ឈមណ្ឌលឯកសារកម្ពុជា)

នៅក្នុងឆ្នាំ ១៩៩១ ប្រជាជនទាំងអស់នៅក្នុងជំរំសាយប៊ី ត្រូវបានបញ្ជូនមកមាតុភូមិវិញ ដោយមានឡានចាំដឹកជញ្ជូនមក ហើយខ្ញុំបាននាំគ្រួសារវិលត្រឡប់ទៅស្រុកកំណើតវិញ។ មុនពេលបោះឆ្នោតឆ្នាំ ១៩៩៣ ខ្ញុំត្រូវបានរាជរដ្ឋាភិបាលកម្ពុជាបញ្ជូនឲ្យមកបម្រើការនៅក្នុងអង្គភាពទ័ពវិញ។ នៅឆ្នាំ១៩៩៦ ខ្ញុំបានឡើងទៅវាយប្រយុទ្ធតទល់ជាមួយកងកម្លាំងរបស់ខ្មែរក្រហមនៅអន្លង់វែង រហូតចុងឆ្នាំ១៩៩៧។ នៅពេលនោះ រដ្ឋាភិបាលចាប់ផ្ដើមចរចាជាមួយខ្មែរក្រហមនៅអន្លង់វែងដែលជាតំបន់តស៊ូចុងក្រោយ ក្នុងគោលបំណងស្វែងរកសន្តិភាព។ នៅដើមឆ្នាំ១៩៩៩ ខ្មែរក្រហមនៅតំបន់អន្លង់វែងបានធ្វើសមាហរណកម្មចុះចូលជាមួយរាជរដ្ឋាភិបាលកម្ពុជា។ ចាប់តាំងពីពេលនោះមក គ្រួសាររបស់ខ្ញុំបានរស់នៅជួបជុំគ្នានៅអន្លង់វែងរហូតមកដល់សព្វថ្ងៃ។

# ខ្ញុំរង់ចាំពុកដល់ថ្ងៃលិចមិនឃើញត្រឡប់មកផ្ទះវិញ

*ភា រស្មី*



*អ្នកគ្រូ ប៉ែន សុគុណ គឺជានាយិកានៃវិទ្យាល័យអន្លុងស ក្នុងភូមិអន្លុងស ឃុំអន្លុងស ស្រុកមេសាង ខេត្តព្រៃវែង។ (ផេង ពង្សរ៉ាស៊ី/មជ្ឈមណ្ឌលឯកសារកម្ពុជា)*

ស្ថិតក្នុងឯកសណ្ឋានគ្រូបង្រៀន អ្នកគ្រូ ប៉ែន សុគុណ បានទទួលស្វាគមន៍ក្រុមការងាររបស់មជ្ឈមណ្ឌលឯកសារកម្ពុជា នៅផ្ទះរបស់គាត់ក្នុងភូមិមហាសួន ឃុំស្វាយយា ស្រុកស្វាយជ្រំ ខេត្តស្វាយរៀង។ សព្វថ្ងៃ អ្នកគ្រូគឺជានាយិកានៃវិទ្យាល័យអន្លុងស ក្នុងភូមិអន្លុងស ឃុំអន្លុងស ស្រុកមេសាង ខេត្តព្រៃវែង ដែលជាទីកន្លែងកំណើតរបស់អ្នកគ្រូ។ អ្នកគ្រូ ប៉ែន សុគុណ បង្រៀនផង និងជាអ្នកគ្រប់គ្រងកិច្ចការទូទៅនៅសាលាផង ដែលធ្វើឲ្យអ្នកគ្រូមានការមមាញឹកយ៉ាងខ្លាំង។

កាលពីថ្ងៃទី០៨ ខែកុម្ភៈ ឆ្នាំ២០២១ ក្រុមការងារនៃមជ្ឈមណ្ឌលឯកសារកម្ពុជា បានចុះជួបសម្ភាសន៍ជាមួយអ្នកគ្រូនាយិកានៃវិទ្យាល័យអន្លុងស អ្នកគ្រូ ប៉ែន សុគុណ មានអាយុ ៥៦ឆ្នាំ នៅក្នុងបរិវេណផ្ទះដែលធំទូលាយរបស់គាត់។ អ្នកគ្រូ សុគុណ បានរៀបរាប់ដូចខាងក្រោមនេះថា៖

នៅឆ្នាំ១៩៧០ ខ្ញុំរួមជាមួយមិត្តភក្តិរបស់ខ្ញុំចំនួន ២នាក់និងបងជីដូនមួយរបស់ខ្ញុំម្នាក់ទៀត បានទៅទិញនំក្រូច ហូប នៅថ្នល់កែងជិតផ្សារ។ យើងដើរបណ្តើរហូប

នំបណ្តើរ និងប្រលែងគ្នាលេងយ៉ាងសប្បាយពេលត្រឡប់មកផ្ទះវិញ។ ខ្ញុំនិងបងជីដូនមួយរបស់ខ្ញុំដើរខាងមុខ និងមិត្តខ្ញុំពីរនាក់ទៀតដើរតាមក្រោយ។ ខ្ញុំនិងបងដើរជិតដល់មុខផ្ទះ ស្រាប់តែមានយន្តហោះមកទម្លាក់គ្រាប់បែក។ មិត្តរបស់ខ្ញុំពីរនាក់ដែលដើរខាងក្រោយខ្ញុំម្នាក់ស្លាប់ភ្លាមនៅកន្លែង និងម្នាក់ទៀតឈាមស្រោចខ្លួន ។ ចំណែកឪពុករបស់ខ្ញុំ គ្រាន់តែឮសំឡេងយន្តហោះលើអាកាសក៏រត់មកកញ្ឆក់ និងពរខ្ញុំរត់ចូលពួននៅក្នុងត្រង់សេ។ អ៊ំរបស់ខ្ញុំពេលឃើញមិត្តភក្តិរបស់ខ្ញុំពីរនាក់ត្រូវគ្រាប់ គាត់គិតថាជាខ្ញុំបានស្រែកហៅខ្ញុំ « ក្មួយគុណៗ ឲ្យចូលត្រង់សេៗ » ឃើញខ្ញុំមានរបួស អ៊ំរបស់ខ្ញុំប្រញាប់ចេញមកក្រៅ ហើយគាត់ក៏ត្រូវអំបែងគ្រាប់ដែរ។ គ្រាប់បែកទម្លាក់នោះបានឆក់យកជីវិតមិត្តរបស់ខ្ញុំពីរនាក់, មនុស្សចាស់ដែលជាអ្នកដំណើរ១នាក់ សត្វចិញ្ចឹម, ឆេះផ្ទះប្រជាជន និងចំរបងវត្តអង្គរស។ គ្រាប់បែកដែលទម្លាក់នោះមានចំនួនពីរគ្រាប់ មួយគ្រាប់នៅមុខផ្ទះខ្ញុំនិងមួយគ្រាប់ទៀតនៅខាងត្បូងភូមិ។

នៅក្នុងឆ្នាំ១៩៧៣ អង្គការបានចាប់ឪពុកខ្ញុំទៅឃុំឃាំងនៅព្រៃជើងចាប ប្រហែលដោយសារឪពុករបស់ខ្ញុំធ្វើជាគ្រូបង្រៀន។ ម្តាយរបស់ខ្ញុំ មិនបានទទួលដំណឹងពីឪពុកខ្ញុំឡើយ។ ដោយក្តីបារម្ភពីប្តី ម្តាយរបស់ខ្ញុំបានឲ្យខ្ញុំនិងបងស្រីកណ្តាល ចេញទៅដើររកគាត់។ នៅក្នុងសម័យនោះ មនុស្សចាស់ដូចជាម្តាយរបស់ខ្ញុំមិនត្រូវបានអនុញ្ញាតឲ្យដើរចេញក្រៅភូមិឆ្ងាយបានទេ មានតែក្មេងៗដូចខ្ញុំ និងបងស្រីប៉ុណ្ណោះទើបអាចចេញដើរក្រៅភូមិបាន។ ខ្ញុំចាំបានថាកាលនោះខ្ញុំអាយុប្រហែលជា៧ឆ្នាំនិងបងស្រីប្រហែលជា៩ឆ្នាំ។ យើងបានទៅផ្ទះឪពុកធំ និងស្នើឲ្យគាត់ជួយដើររកពុក។ ខ្ញុំពីរនាក់បងប្អូនដើរលុយទឹកជ្រៅៗ បណ្តើរយំបណ្តើរ មិនដឹងពុកនៅឯណា។ ក្រោយមក យើងបានជួបពុកនៅស្វាយជរៅ កន្លែងឃុំឃាំង។ នៅយប់នោះ ខ្ញុំបានស្នាក់នៅជាមួយពុក។ ដោយសារដើរផ្លូវឆ្ងាយ ឆ្លងអូរលុយទឹកជ្រៅៗ កាត់ព្រៃ និងត្រូវកម្តៅថ្ងៃខ្លាំង ធ្វើឲ្យយើងពីរនាក់បងប្អូនក្តៅខ្លួនខ្លាំង។ យប់នោះ ឪពុកខ្ញុំក៏ក្តៅខ្លួនដែរ។ ឪពុករបស់ខ្ញុំ បានត្រឹមយំពេលឃើញកូនក្តៅខ្លួនមិនបានមើលថែ។ លុះស្អែកឡើង អ៊ំរបស់ខ្ញុំបានជូនខ្ញុំនិងបងស្រីត្រឡប់មកផ្ទះវិញ។ ក្រោយមក ឪពុករបស់ខ្ញុំត្រូវបានដោះលែង។ បងប្អូនរបស់ឪពុកខ្ញុំនៅខាងលិចភូមិប្រាប់ឪពុកខ្ញុំថា «រត់ទៅវៀតណាមទៅ បើនៅមិនរស់ទេព្រោះគេស្អប់យើងមានជីវភាពធូរធា» ឪពុកខ្ញុំមិនរត់ទៅវៀតណាមទេ ព្រោះគាត់ដឹងថា បើគាត់ទៅប្រាកដជាត្រូវសម្លាប់ទាំងប្រពន្ធ និងកូនមិនខាន។ ក្រោយមកឪពុករបស់ខ្ញុំបាននាំគ្រួសារទៅរស់នៅក្បែរវត្តថ្មី ដោយធ្វើខ្ទមស្នាក់នៅ។

ចាប់ពីឆ្នាំ១៩៧០ ដល់ឆ្នាំ១៩៧៥ ខ្ញុំនិងបងៗ បានចូលរៀនដូចក្មេងដទៃ ប៉ុន្តែបន្ទាប់ពីខ្មែរក្រហមទទួលជ័យជម្នះថ្ងៃ១៧ ខែមេសា អង្គការមិនអនុញ្ញាតឲ្យបងប្អូនរបស់ខ្ញុំរៀនសូត្របន្តទៀតទេ។ ខ្មែរក្រហមបាននិយាយថា បងប្អូនរបស់ខ្ញុំគឺជាកូនអ្នកមូលធន «ពួកសក្តិសម្ព័ន្ធក្បាលស» ខ្មែរក្រហមដាក់ងារឲ្យយើងដូច្នេះ។ មិត្តភក្តិរបស់ខ្ញុំពីរនាក់បានសុំអង្វរខ្មែរក្រហមឲ្យខ្ញុំចូលរៀនដែរ ប៉ុន្តែអង្គការមិនព្រម ហើយបានចាត់តាំងឲ្យខ្ញុំនិងបងរបស់ខ្ញុំទៅកាប់ដីលើកទំនប់នៅស្រះតាអ៊ឹម ដែលខុសពីកុមារផ្សេងទៀតបានចូលរៀនជាមួយអង្គការ។



វត្តស្រះតាអ៊ឹម ស្ថិតនៅក្នុងស្រុកមេសាង ខេត្តព្រៃវែង។
(ផេង ពង្សរ៉ាស៊ី/មជ្ឈមណ្ឌលឯកសារកម្ពុជា)




នៅថ្ងៃជ័យជម្នះ ប្រជាជននៅក្នុងភូមិបានលេងភ្លេងអបអរសាទរ ប៉ុន្តែក្រោយមកស្ថានភាពនៅក្នុងភូមិកាន់តែលំបាកជាងមុនៗ ចំណែកប្រជាជន ១៧ មេសា ដែលជម្លៀសមករស់នៅក្នុងភូមិក៏លំបាកដែរៗ ប្រជាជនថ្មីទាំងនោះគ្រាន់តែរើសស្បែកគោដែលបោះចោល យកមកហូបក៏ត្រូវអង្គការចាប់យកទៅសម្លាប់ទាំងគ្រួសារ។ ចំណែកក្មេង ខ្មែរក្រហមយកទៅបោកខ្ទប់ដើមឈើ។

រហូតដល់ឆ្នាំ១៩៧៧ តាឈិន បានទទួលសំបុត្រមួយពីថ្នាក់លើ ហើយប្រាប់ឪពុកខ្ញុំឲ្យជួយរុះរោងនៅថ្នល់កែងៗ ឪពុករបស់ខ្ញុំបានសួរ តាឈិន ថា «ឲ្យយកពូថៅដែកកាស់ទៅដែរទេ? » គាត់ថាមិនបាច់ទេ ។ ខ្ញុំរង់ចាំឪពុករហូតដល់ល្ងាចមិនឃើញត្រឡប់មកផ្ទះវិញ។ ម្តាយរបស់ខ្ញុំបានទៅសួរប្រធានរោងបាយរួមៗ នៅទីនោះ ប្រជាជនខ្លះនិយាយថា មិនដឹង និង ប្រជាជនខ្លះទៀតនិយាយថា អង្គការចាប់យកទៅបាត់ហើយ។

នៅយប់នោះមានការសម្តែងរឿង ដាំ ដេង នៅស្រះតាអឹម ហើយម្តាយរបស់ខ្ញុំបានឲ្យខ្ញុំទៅមើល និងប្រាប់បងខ្ញុំអំពីដំណឹងរបស់ពុកដែលត្រូវបានអង្គការចាប់យកទៅមិនឃើញត្រឡប់មកផ្ទះវិញ។ បងស្រីខ្ញុំយំ ពេលបានដំណឹងនេះ ពេលគាត់មកដល់ផ្ទះ។ ឪពុករបស់ខ្ញុំមិនទាន់បានស្លៀកពាក់ខោអាវស្រួលបួលទេ គឺមានតែខោខ្លីមួយ ក្រមាគ្រើមត្បាញជំនាន់នោះ និងអាវយឺតពណ៌សមួយប៉ុណ្ណោះ។ ចំណែកគោ ដែលឪពុករបស់ខ្ញុំចិញ្ចឹមមើលថែរាល់ថ្ងៃ បានយំស្រែករោទ៍ ទន្ទ្រាំដី បីយប់មកហើយ ដោយមិនដឹងពីមូលហេតុ។ យាយរបស់ខ្ញុំដេកឈឺសម្រាកនៅលើគ្រែដែលឪពុកខ្ញុំនៅមើលថែ។ លុះបាត់មិនឃើញឪពុករបស់ខ្ញុំ យាយរបស់ខ្ញុំចេះតែសួររក។ ខ្ញុំមិនហ៊ានប្រាប់យាយពីដំណឹងរបស់ឪពុកខ្ញុំទេ។ យាយបានសួររកឪពុកខ្ញុំជាប្រចាំ ទើបម្តាយរបស់ខ្ញុំដាច់ចិត្តប្រាប់គាត់។ នៅពេលយាយបានដឹងដំណឹងនេះ យាយរបស់ខ្ញុំក្អកស្លាប់ភ្លាមៗ ដោយសារឈឺចិត្តខ្លាំងពេក។

នៅចុងឆ្នាំ១៩៧៧អង្គការបានបញ្ជូនគ្រួសារខ្ញុំឲ្យទៅនៅតំបន់ដីខ្សាច់ក្នុងខេត្តពោធិ៍សាត់។ កម្មាភិបាលខ្មែរក្រហមបានប្រាប់ទៀតថា នៅទីនោះសម្បូរអាហារហូបចុកណាស់។ មុនដំបូងគ្រួសាររបស់ខ្ញុំប្រកែកមិនព្រមទៅទេ។ ប៉ុន្តែក្រោយមកអង្គការមកគំរាមថា បើមិនទៅទេនឹងចងដាក់លើ ឡានបោះដូចសត្វជ្រូក ដូច្នេះហើយគ្រួសាររបស់ខ្ញុំក៏សម្រេចចិត្តចាកចេញទៅ។ យើងធ្វើដំណើរទៅដោយថ្មើរជើង យប់កន្លែងណាគឺយើងត្រូវដេកកន្លែងនោះ។ ក្រោយមក យើងទៅដល់អ្នកលឿង និងបានជិះកប៉ាល់បន្តទៅភ្នំពេញ។ ក្នុងពេលធ្វើដំណើរ មានកប៉ាល់ជាច្រើនស្ទើរតែបានលិច នៅមុខទន្លេចតុមុខ ដោយសារទឹកហូរក្តួចខ្លាំងពេក។ កប៉ាល់ដែលខ្ញុំជិះ អង្គការបានចងអបគ្នាពីរ និងមានអ្នកបើកដែលហាក់ដូចជាមានជំនាញ។ ក្រោយមកយើងបានឈប់សម្រាកនៅច្បារអំពៅរយៈពេលមួយយប់ រួចបន្តដំណើរដោយជិះរថភ្លើងទៅឈប់នៅស្វាយដូនកែវ ។ នៅទីនោះ មានអ្នកមកទទួលទៅកាន់សហករណ៍ផ្សេងៗ។ គ្រួសារខ្ញុំនៅសហករណ៍ចាហ៊ួយ អង្គការក៏បំបែកយើងឲ្យរស់នៅផ្សេងពីគ្នា។ អង្គការចាត់តាំងខ្ញុំឲ្យនៅកងកុមារ នៅផ្ទះបាយបឹងផុន។ អង្គការតម្រូវឲ្យក្មេងៗហូបបបរអង្ករមួយកំប៉ុងសម្រាប់គ្នា ៨ នាក់ ។ អ្នកណាហូបលឿនបានច្រើនអ្នកណាហូបយឺតជាងគេគឺបានតិចឬអត់តែម្តង។ ខ្ញុំបានទៅលួចហូបបបរនៅក្នុងកង



*សិស្សានុសិស្សវិទ្យាល័យអន្តរសចូលរួមវេទិកាថ្នាក់រៀនស្តីអំពីប្រវត្តិសាស្ត្រកម្ពុជាប្រជាធិបតេយ្យ (១៩៧៥-១៩៧៩) ។ (ផេង ពង្សរ៉ាស៊ី/មជ្ឈមណ្ឌលឯកសារកម្ពុជា)*



*សាលាបឋមសិក្សា ស្រះតាអឹម ស្ថិតនៅក្នុងស្រុកមេសាង ខេត្តព្រៃវែង។ (ផេង ពង្សរ៉ាស៊ី/មជ្ឈមណ្ឌលឯកសារកម្ពុជា)*

បងស្រីខ្ញុំព្រោះមានរបបគ្រាន់ជាងកងកុមារ និងម្យ៉ាងទៀតបងខ្ញុំហូបលឿនៗ ខ្ញុំតែងលួចបន្ទំចូលនៅពេលព្រលប់ព្រោះភ្លើងមិនសូវភ្លឺ ចំណែកភ្នែកយាយខាងដាំបាយមើលមិនសូវច្បាស់ៗ ក្រោយមកអង្គការបញ្ជូនខ្ញុំឲ្យទៅនៅភ្នំត្រនាប់គគីរ ប៉ុន្តែដោយសារតែខ្ញុំនឹកម៉ែខ្លាំងពេកទ្រាំពុំបាន ខ្ញុំក៏សម្រេចចិត្តលួចរត់ត្រឡប់មករកម៉ែៗ ក្រៅពីខ្ញុំ, គឺមានប៉ាក់និងម្នាក់ទៀតស្លាប់ បានលួចរត់មកផ្ទះៗ នៅតាមផ្លូវមានកម្មាភិបាលយកកាំបិតតាមកាប់យើងពីក្រោយៗ ប៉ុន្តែយើងបានរត់ពួនរហូតទាល់តែឈ្លបទៅបាត់ ទើបធ្វើដំណើរបន្តទៀតៗ យើងធ្វើដំណើរចេញមកតាំងពីម៉ោង៤រសៀលរហូតដល់កន្លែងម៉ែនៅរោងបាយបឹងផុន នៅម៉ោង១យប់ៗ ពេលមកដល់ម្តាយរបស់ខ្ញុំទៅសុំបាយនៅរោងចុងភៅឲ្យខ្ញុំហូប ប៉ុន្តែប្រធានរោងបាយថាមិនមានរបបសម្រាប់ខ្ញុំទេៗ ខ្ញុំបានហូបផ្លែធ្លូក និងផ្លែពុទ្រាជំនួសវិញៗ

នៅឆ្នាំ១៩៧៨ អង្គការបានបញ្ជូនខ្ញុំឲ្យទៅនៅផ្ទះបាយដៃនាវៗ នៅទីនោះខ្ញុំឃើញអ៊ំស្រីម្នាក់ដេរខ្មែរក្រហមដែលបានយកប្តីរបស់គាត់ទៅសម្លាប់ៗ បន្តិចក្រោយមកប្រធាននារីម្នាក់ មកចាប់អ៊ំនោះ ទៅអារកសម្លាប់ៗ ខ្ញុំព្រួសំឡេងស្រែក បន្តិចក្រោយមកប្រធាននារីត្រឡប់មកវិញ ហើយខ្ញុំឃើញគាត់កាន់កាំបិតប្រលាក់សុទ្ធតែឈាមៗ នៅសម័យនោះ ក្មេងៗដូចខ្ញុំ ប្រសិនបើប្រព្រឹត្តកំហុសនឹងត្រូវចាប់យកទៅផ្ទះបាយ ៣០ ប្តុសម្លាប់ចោលតែម្តងៗ មានកុមារម្នាក់ត្រូវបានអង្គការចាប់យកទៅផ្ទះបាយ ៣០ ដើម្បីធ្វើបាប និងបង្អត់អាហារៗ ខ្មែរក្រហមបានលើកបាវស្រូវអុកលើក្មេងនោះ ក្មេងនោះរាកចេញមកគឺ មិនមានលាមកទេ មានតែទឹក និងក្រសាលគូទលានចេញមកក្រៅៗ

នៅថ្ងៃទី៧ ខែមករា ឆ្នាំ១៩៧៩ កងទ័ពស្ម័គ្រចិត្តវៀតណាម និងកងទ័ពរណសិរ្សសាមគ្គីសង្គ្រោះជាតិកម្ពុជាបានទទួលជោគជ័យក្នុងការវាយយកទីក្រុងភ្នំពេញៗ ទឹកដីកម្ពុជាមួយភាគធំត្រូវបានគ្រប់គ្រងដោយទ័ពសម្ព័ន្ធមិត្ត ប៉ុន្តែនៅតំបន់ដែលខ្ញុំរស់នៅក្នុងខេត្តពោធិ៍សាត់គឺនៅគ្រប់គ្រងដោយកងទ័ពខ្មែរក្រហមៗ អំឡុងពេលនោះ ខ្ញុំឃើញមានយន្តហោះទម្លាក់គ្រាប់បែកបានហោះទៅដល់

ទីនោះ។ នៅជិតកន្លែងដែលខ្ញុំធ្វើការ ខ្ញុំឃើញកងទ័ពវៀតណាមធ្វើដំណើរទៅមកលើផ្លូវជាតិ ប៉ុន្តែខ្ញុំមិនដឹងធ្វើយ៉ាងណាដើម្បីឲ្យទ័ពវៀតណាមអាចចូលមកជួយយើងបានទេ។ ក្រោយមកអង្គការមានបំណងសម្លាប់ប្រជាជនទាំងអស់នៅទីនោះ ដោយមុនដំបូង គឺខ្មែរក្រហមសម្លាប់ក្រុមបងស្រីរបស់ខ្ញុំមុន។ មានពូម្នាក់ឈ្មោះ ក្អាត់ គឺជាប្រជាជនចាស់ ដែលមានសន្តានចិត្តល្អ បានប្រាប់បងស្រីរបស់ខ្ញុំឲ្យរត់។ ក្រោយមកទៀតអង្គការបានធ្វើនំបញ្ចុកឲ្យយើងហូប និងបម្រុងយកក្រុមបងស្រីរបស់ខ្ញុំទៅសម្លាប់។ ចំណែកមួយក្រុមទៀត ខ្ញុំឃើញកូនឈ្លបតូចៗបណ្តើរមនុស្សយកទៅសម្លាប់ ហើយនៅតាមផ្លូវមានពូម្នាក់បានរត់រួច។ នៅពេលពូម្នាក់នោះរត់ គឺមានយោធាខ្មែរក្រហមតូចៗកាន់កាំភ្លើងតាមដេញបាញ់ពីក្រោយប៉ុន្តែបាញ់មិនត្រូវ។ ខ្ញុំឃើញមានសាកសពគ្រប់ទីកន្លែងទាំងក្មេង ទាំងចាស់ ហើយពេលខ្លះខ្ញុំដេកក្បែរសាកសព។ គ្រួសាររបស់ខ្ញុំគិតគ្នាថា នឹងរត់កាត់ខ្សែត្រៀមឆ្លងមកខាងរំដោះ។ ប៉ុន្តែយើងត្រូវរង់ចាំដល់ថ្ងៃទី ៣០សិន ព្រោះមានអ៊ំប្រុសម្នាក់ប្រាប់ថានៅទីថ្ងៃ ៣០ នឹងមានកងទ័ពរំដោះមកជួយ។ មកដល់ថ្ងៃទី ៣០ កងទ័ពស្ម័គ្រចិត្តវៀតណាម និងកងទ័ពរណសិរ្សសាមគ្គីសង្គ្រោះជាតិកម្ពុជាចូលមកដល់។ នៅពេលស្ថានភាពចលាចលគ្រួសាររបស់ខ្ញុំក៏សម្រេចចិត្តរត់កាត់ខ្សែត្រៀម។ នៅពេលរត់មានគ្រាប់កាំភ្លើងហោះមកត្រូវមនុស្សដែលរត់ក្បែរខ្ញុំដួលជាច្រើននាក់ ហើយបងប្អូនរបស់ខ្ញុំបានរត់បែកគ្នា។ ខ្ញុំនៅជាមួយម្តាយ។ ក្រោយមកម្តាយខ្ញុំសម្រេចចិត្តត្រឡប់មកស្រុកកំណើតវិញ។ នៅពេលធ្វើដំណើរតាមផ្លូវមានប្រជាជនចិត្តល្អបានឲ្យអង្ករ និងម្ហូបអាហារមកយើងរហូតធ្វើដំណើរដល់ផ្ទះ។ បងស្រីរបស់ខ្ញុំបានធ្វើដំណើរទៅដល់ផ្ទះមុនយើង ហើយបងប្អូនដែលនៅក្នុងភូមិបានធ្វើបុណ្យឲ្យខ្ញុំ និងម្តាយខ្ញុំរួចហើយ ព្រោះអ្នកដែលរត់កាត់ខ្សែត្រៀម ភាគច្រើនត្រូវគ្រាប់កាំភ្លើងស្លាប់។

ក្រោយមកគ្រួសាររបស់ខ្ញុំបានធ្វើស្រែដើម្បីចិញ្ចឹមជីវិត ចំណែកបងស្រីរបស់ខ្ញុំឆ្លៀតកាត់ដេរសម្លៀកបំពាក់ដើម្បីរកប្រាក់ឲ្យខ្ញុំបានចូលរៀន។ បងស្រីរបស់ខ្ញុំខិតខំប្រឹងរកប្រាក់ឲ្យខ្ញុំបានរៀនសូត្រ ទើបខ្ញុំមានចំណេះវិជ្ជាអាចក្លាយជានាយិកានៃវិទ្យាល័យអង្គរស ដូចសព្វថ្ងៃនេះ។



អគារសិក្សានៅវិទ្យាល័យអង្គរស។ (ផេង ពង្សរ៉ាស៊ី/មជ្ឈមណ្ឌលឯកសារកម្ពុជា)

# ជីវិតតស៊ូជាមួយខ្មែរក្រហម

អ៊ុន សុជាទី

យិន ស៊ិន ហៅក្រូច ភេទប្រុស អាយុ៧០ឆ្នាំ សព្វថ្ងៃរស់នៅភូមិក្រពើពីរលើ ឃុំក្រពើពីរ ស្រុកវាលវែង ខេត្តពោធិ៍សាត់។ ក្រូច បានចែករំលែកអំពីបទពិសោធន៍ជីវិតរបស់គាត់ដែលបានតស៊ូជាមួយខ្មែរក្រហមថា៖

ខ្ញុំមានស្រុកកំណើតនៅភូមិទ័ពបោះ ឃុំធ្លកវៀន (ឃុំពីសង្គមចាស់) ស្រុកកំពង់ត្រឡាច ខេត្តកំពង់ឆ្នាំង។ ប្រពន្ធរបស់ខ្ញុំឈ្មោះ សូ ផល មានអាយុ៦៥ឆ្នាំ។ ខ្ញុំមានកូនស្រី ៤នាក់ និងកូនប្រុស ៤នាក់។ ឪពុករបស់ខ្ញុំឈ្មោះ សូត្រ និងម្តាយរបស់ខ្ញុំឈ្មោះ យាន។ ឪពុកម្តាយរបស់ខ្ញុំបានស្លាប់អស់ទៅហើយ។ ខ្ញុំមានបងប្អូន ៧នាក់ ប្រុស ៤នាក់និងស្រី ៣នាក់។ ខ្ញុំរៀនសូត្របានតិចតួចណាស់។ កាលពីក្មេង ខ្ញុំរៀនបានត្រឹមថ្នាក់ទី១១ ពីសង្គមចាស់។ ខ្ញុំបានឈប់រៀនរយៈពេល ២ឆ្នាំ មុនពេលដែលរដ្ឋប្រហារបានកើតឡើងក្នុងឆ្នាំ១៩៧០។ សព្វថ្ងៃនេះ ក្រុមគ្រួសាររបស់ខ្ញុំ ប្រកបមុខរបរដាំដំណាំដូចជា ពោត អំពៅ និងស្រូវដើម្បីចិញ្ចឹមជីវិត។



យឹម ស៊ិន ហៅក្រូច អាយុ ៧០ឆ្នាំ សព្វថ្ងៃរស់នៅភូមិក្រពើពីរលើ ឃុំក្រពើពីរ ស្រុកវាលវែង ខេត្តពោធិ៍សាត់។ (សុខ វណ្ណៈ/មជ្ឈមណ្ឌលឯកសារកម្ពុជា)។

## រត់ចូលព្រៃធ្វើយោធា

បន្ទាប់ពីរដ្ឋប្រហារបានកើតឡើងក្នុងឆ្នាំ១៩៧០ ប្រទេសកម្ពុជាបានផ្លាស់ប្តូរពីរបបសង្គមរាស្ត្រនិយម ដែលស្ថិតក្រោមការដឹកនាំរបស់សម្តេចសីហនុ ទៅជារបបសាធារណរដ្ឋខ្មែរ ដឹកនាំដោយរបស់ លន់ នល់ វិញ។ នៅក្នុងភូមិរបស់ខ្ញុំ មានការកេណ្ឌយុវជនឲ្យចូលធ្វើជាទាហានបម្រើដល់របបសាធារណរដ្ឋខ្មែរ។ ប្រជាជនមួយចំនួននាំគ្នាទៅបួសក្នុងគោលបំណងគេចវេះពីការចូលធ្វើទាហាន។ ប្រជាជនខ្លះទៀត បានយល់ព្រមចូលធ្វើជាទាហាន និងប្រជាជនមួយចំនួនផ្សេងទៀត បានរត់ចូលព្រៃដើម្បីចូលរួមជាមួយនឹងរដ្ឋាភិបាលរណសិរ្សរួបរួមជាតិកម្ពុជា។

ក្នុងឆ្នាំ១៩៧១ ខ្ញុំបានសម្រេចចិត្តចូលព្រៃតស៊ូជាមួយនឹងរដ្ឋាភិបាលរណសិរ្សរួបរួមជាតិកម្ពុជាប្រឆាំងនឹងរបប លន់ នល់។ មុនដំបូង ខ្ញុំបានចូលធ្វើជាយោធាភូមិភាគនិរតី តំបន់៣១ ។ នៅពេលនោះ ភូមិភាគនិរតី ទើបតែមានការចាប់ផ្តើមរៀបចំយោធាបានមួយភូមិភាគ មានចំនួន ៣ ក្រុម សម្រាប់ធ្វើសកម្មភាពប្រយុទ្ធតទល់នឹងទាហាន លន់ នល់។ ភូមិភាគនិរតី មិនទាន់មានកងឈ្លប បុកង

សេនាជននៅឡើយនោះទេ។ ក្រោយមក តាម៉ុក បានចុះមករៀបចំយោធាបន្ថែមទៀត ដោយយកយោធាពីខេត្តតាកែវមកខ្លះ និងពីបស្ចិមមកខ្លះ រួមជាមួយនឹងយោធាដែលយើងមានស្រាប់រៀបចំបានមួយអនុសេនាធំ។ ក្នុងមួយអនុសេនាធំ មានកងកម្លាំងយោធាចំនួនប្រហែល១០០ នាក់។

ក្នុងឆ្នាំ១៩៧២ យើងបានប្រមែប្រមូលយោធាមកពីគ្រប់ទីកន្លែងទាំងអស់ ហើយរៀបចំយោធាបានមួយកងវរសេនាធំ ដែលមានយោធាចំនួនប្រហែល ១០០០នាក់។ បន្ទាប់មក យើងបានចាប់ផ្ដើមវាយប្រយុទ្ធគ្នាជាមួយនឹងទាហាន លន់ នល់។ ខ្ញុំបានចូលរួមប្រយុទ្ធនៅម្ដុំខេត្តកំពង់ស្ពឺ និងវាយនៅកំពង់ត្រឡាច ខេត្តកំពង់ឆ្នាំង។ ក្នុងពេលធ្វើសង្គ្រាមដំបូងៗ យើងប្រើប្រាស់កាំភ្លើងដែលមានប្រភេទគ្រាប់ ១២.៧ ម.ម និងកាំភ្លើងបានមកពីទាហាន លន់នល់។ យើងតែងតែគំរាមទាហាន លន់នល់ យកកាំភ្លើងសម្រាប់ទុកប្រើប្រាស់។ បន្ទាប់ពីយើងប្រមូលបានកាំភ្លើងចាប់ពី ១០ ទៅ ២០ដើម យើងបានចាប់ផ្ដើមវាយទីតាំងណាដែលមានទ្រង់ទ្រាយធំបន្តិច។ ក្នុងពេលប្រយុទ្ធគ្នាដំបូងៗ ខ្ញុំមិនទាន់ឃើញមានយន្តហោះទម្លាក់គ្រាប់បែកនោះទេ។ យោធាទាំងអស់ត្រូវប្រយុទ្ធដោយថ្មើរជើង។ ខ្ញុំធ្លាប់បានត្រូវរបួសក្នុងពេលប្រយុទ្ធគ្នាដែរ។

ក្រោយមក ភូមិភាគនិរតី បានបង្កើតជាវរសេនាធំលេខ១៦ ដែលមាន តាសឿង គឺជាប្រធានកងពលទី១។ ភាពច្របូកច្របល់និងអសន្តិសុខបានកើតឡើងស្ទើរតែគ្រប់ទីកន្លែង។ យើងពិបាកក្នុងការបែងចែកណាស់ថាតើភាគីខ្មែរណាដែលល្អ ឬភាគីខ្មែរណាដែលអាក្រក់នោះ។ ប្រជាជនមួយចំនួនបានចាកចេញទៅនៅបរទេស ហើយប្រជាជនខ្លះទៀត បេះតែទ្រាំរស់ប្រឈមមុខនឹងបញ្ហាដែលបានកើតឡើងជារៀងរាល់ថ្ងៃនៅតាមតំបន់ដែលខ្លួនរស់នៅ។

នៅពេលដែលខ្ញុំចូលរួមធ្វើសង្គ្រាមប្រឆាំងនឹងរបប លន់ នល់ ខ្ញុំបានគ្រប់គ្រងកងអនុសេនាតូចដែលមានយោធាចំនួន ៣៦នាក់។ នៅពេលនោះ ខ្មែរក្រហមបានទទួលការជួយច្បាំងពីកងទ័ពវៀតណាម ថែមទាំងទទួលបានជំនួយសព្វាវុធពីប្រទេសចិនតាមរយៈកងទ័ពវៀតណាមដែរ។ ខ្ញុំធ្លាប់បានធ្វើការជាមួយនឹងកងទ័ពវៀតណាមបានរយៈពេលប្រហែលជិត១ឆ្នាំ។

ក្នុងឆ្នាំ១៩៧៣ ខ្មែរក្រហម បានបណ្ដេញកងទ័ពវៀតណាមឲ្យត្រឡប់ទៅប្រទេសវៀតណាមវិញ។ បន្ទាប់មក កងកម្លាំងចលនាស្នេហាជាតិក៏បានចាប់ផ្ដើមផុសឡើង។ ខ្មែរក្រហម បានទទួលជំនួយអាវុធពីប្រទេសចិនជាច្រើន ដូច្នេះយើងអាចបង្កើតជាកងពលធំៗបាន។

ក្រុមរបស់ខ្ញុំ បានវាយចូលទៅក្នុងទីក្រុងភ្នំពេញម្ដុំពោធិ៍ចិនតុង នៅម៉ោងប្រហែល ៧ព្រឹក ដោយចាប់ផ្ដើមបោសសម្អាតទាហាន លន់ នល់ នៅទីនោះ។ ខ្ញុំបានដើរប្រមូលទាហាន លន់ នល់ ទុកមួយកន្លែង។ បន្ទាប់មក ខ្ញុំក៏ចាប់ផ្ដើមវាយបន្ទាយនៅម្ដុំពោធិ៍ចិនតុង។ បន្ទាប់ពីវាយបន្ទាយបានហើយ ខ្ញុំបានចាប់ផ្ដើមដកកម្លាំងទាហានតាមបន្ទាយនិងដកយកវិទ្យុទាក់ទង។ ខ្ញុំបានចូលទៅក្នុងបន្ទាយទាហានរួចយកឧបករណ៍ស្រែកឲ្យទាហានដែលនៅខាងក្នុងបន្ទាយលើកទង់សឡើង រួចប្រមូលកាំភ្លើងទុកមួយកន្លែង។ បន្ទាប់មក ក្រុមយោធារបស់ខ្ញុំបានចូលដកកាំភ្លើងទុក និង នាំយកទាហានទាំងអស់នោះចេញពីបន្ទាយទាំងអស់ឲ្យដើរជាជួរៗនិងលើកដៃឡើង។ ទាហាន លន់ នល់ ទាំងអស់ត្រូវនាំចេញទៅ ប៉ុន្តែខ្ញុំមិនដឹងថាយោធាខ្មែរក្រហម បាននាំទាហានទាំងអស់នោះយកទៅទីណានោះទេ។ ខ្ញុំនិងក្រុមរបស់ខ្ញុំ គឺគ្រាន់តែជាអ្នកបញ្ចេញទាហានចេញពីទីតាំងឲ្យអស់ រួចមកមានក្រុមយោធាខ្មែរក្រហមផ្សេងទៀត នាំយកទាហាន លន់ នល់ចេញទៅ។ នៅពេលនោះ កិច្ចការរបស់ខ្ញុំ គឺត្រូវរៀបចំទីក្រុងភ្នំពេញ ហើយបន្ទាប់ពីរយៈពេលពីរថ្ងៃក្រោយពេលដែលក្រុមរបស់ខ្ញុំបានប្រមូលទាហានចេញអស់ យើងក៏បានឲ្យប្រជាជនចាកចេញជាបន្តបន្ទាប់។

## នៅពេលដែលខ្មែរក្រហមទទួលបានអំណាច

បន្ទាប់ពីខ្ញុំបានចូលបោសសម្អាតទីក្រុងភ្នំពេញរួចរាល់ ហើយប្រជាជនបានចាកចេញពីទីក្រុងភ្នំពេញអស់ ខ្ញុំបានត្រឡប់មករៀបចំកងកម្លាំងនៅឯកំបូល។ ខ្ញុំឈរជើងនៅម្ដុំកំបូល ដែលជាទីតាំងបន្ទាយទាហាន។ ខ្ញុំរស់នៅឯកំបូលបានកន្លះខែ អង្គភាពបានឲ្យក្រុមយោធារបស់ខ្ញុំទៅធ្វើផ្លូវជាតិលេខ៣ឡើងវិញ។ យើងបាននាំគ្នាកសាងផ្លូវ ដែលយើងបានធ្វើឲ្យខូចខាតនៅពេលប្រយុទ្ធ



ស្ទឹងនៅក្នុងឃុំក្រពើពីរ ស្រុកវាលវែង ខេត្តពោធិ៍សាត់។ (អ៊ូ ឧត្តមបញ្ញាវុឌ្ឍ/មជ្ឈមណ្ឌលឯកសារកម្ពុជា)។

គ្នានោះរហូតដល់រួចរាល់។ ក្រោយមក ក្រុមរបស់ខ្ញុំបានទៅបន្តធ្វើផ្លូវរថភ្លើងនៅឯផ្សារត្រាចបន្តទៀត។ ក្រោយសាងសង់ផ្លូវរថភ្លើងរួចអស់ ខ្ញុំបានត្រឡប់មកបន្ទាយនៅឯកំបូលវិញ។ ខ្ញុំមករស់នៅកំបូល បានរយៈពេលប្រហែលជា១ខែ អង្គភាពរបស់ខ្ញុំបានបញ្ជូនខ្ញុំឲ្យមកស្រែអំបិល។

ក្នុងខែកញ្ញា ឆ្នាំ១៩៧៥ ខ្ញុំមកឈរជើងនៅម្តុំថ្នល់បែកគូស ស្រែចាម និងស្រែអំបិល។ ប្រធានកងពលរបស់ខ្ញុំឈ្មោះ បង ឡូញ។ បង ឡូញ គឺជាគណៈតំបន់នៅស្រែអំបិល ចំណែកខ្ញុំធ្វើការនៅក្នុងឃុំ។ អង្គការបានបញ្ជូនខ្ញុំចូលឲ្យមកដើម្បីពង្រឹងនៅស្រែអំបិល ដែលកំពុងតែកើតមានបញ្ហាផ្ទៃក្នុងខ្លះៗ។ នៅពេលដែលខ្ញុំធ្វើជាមេឃុំនៅស្រែអំបិល ប្រជាជនមិនមានការហូបចុកខ្វះខាត និងជួបការលំបាកនោះទេ។ នៅទីនេះ ទើបតែមានការរៀបចំជាសហករណ៍ហើយការហូបចុកនៅគ្រប់គ្រាន់នៅឡើយ។ ជារឿយៗនៅស្រែអំបិល មានក្រុមខ្មែរសមកអុកឡុកសុំអង្ករប្រជាជននៅពេលយប់។ ខ្ញុំធ្លាប់ទទួលបានការអនុញ្ញាតពីអង្គការឲ្យទៅលេងស្រុកកំណើតម្តង។ នៅពេលដែលខ្ញុំបើកឡានមកដល់ផ្ទះ ខាងសហករណ៍នៅឯស្រុកកំណើតរបស់ខ្ញុំ បានយកសាច់គោឲ្យខ្ញុំហូបគគ្រឹកគគ្រេងណាស់។ ខ្ញុំទៅលេងស្រុកកំណើតរបស់ខ្ញុំជាមួយនឹងអង្គរក្សពីរនាក់ទៀតរបស់ខ្ញុំ ដោយជិះឡានហ្ស៊ីបរបស់អាមេរិក។ បងប្អូនរបស់ខ្ញុំនៅក្នុងជំនាន់នោះ ចូលធ្វើជាយោធាចំនួន ៣នាក់ និងបងប្អូនរបស់ខ្ញុំផ្សេងទៀតរស់នៅក្នុងសហករណ៍។ ខ្ញុំធ្វើការនៅស្រែអំបិលបានត្រឹមតែរយៈពេលពីរខែតែប៉ុណ្ណោះ។ បន្ទាប់មក អង្គភាពរបស់ខ្ញុំបានឲ្យខ្ញុំទៅរស់នៅឯកំពង់សោម។

## ការចាត់គ្រប់គ្រងកប៉ាល់នេសាទនៅកំពង់សោម

ខ្ញុំបានទៅដល់កំពង់សោមក្នុងឆ្នាំ១៩៧៥។ ពេលនោះ ខ្ញុំមិនទាន់មានប្រពន្ធទេ។ បង ឡូញ បានចេញពីគណៈតំបន់ ហើយយកខ្ញុំទៅកំពង់សោមជាមួយនឹងគាត់។ បង ឡូញ គឺជាអ្នកទទួលខុសត្រូវក្នុងផ្នែកពាណិជ្ជកម្មរដ្ឋនៅកំពង់សោម។ គាត់ទៅទទួលខុសត្រូវរួមខាងពាណិជ្ជកម្មរដ្ឋជាមួយនឹង មាស មុត។ ចំណែកខ្ញុំធ្វើការនៅខាងផ្នែកនេសាទ



ផ្លូវលំនៅក្នុងឃុំក្រពើពីរ ស្រុកវាលវែង ខេត្តពោធិ៍សាត់។ (អ៊ូ ឧត្តមបញ្ញាវុឌ្ឍ/មជ្ឈមណ្ឌលឯកសារកម្ពុជា)។

រដ្ឋ។ អង្គភាពរបស់ខ្ញុំ បានឲ្យខ្ញុំគ្រប់គ្រងកប៉ាល់នេសាទ ដែលមានប្រជាជនប្រហែលជាង២៥០នាក់ នៅក្នុងកងនេសាទ ក្នុងនោះមានមនុស្សស្រីប្រហែល ៣០នាក់ ជួយធ្វើការងារខាងប្រឡាក់ត្រីងៀត។

នៅពេលនោះ ចិនបានផ្ដល់ជំនួយកប៉ាល់ចំនួន ១២ គ្រឿង មកឲ្យខ្មែរក្រហម។ ចិនបានមកបង្រៀនយើងពីរបៀបបើកកប៉ាល់អស់រយៈពេលប្រហែល១ឆ្នាំដែរ។ កប៉ាល់នោះធំៗណាស់ និងមានចំណុះរាប់តោន។ កប៉ាល់ទាំងអស់ គឺយកមកសម្រាប់ចុះនេសាទត្រីនៅក្នុងសមុទ្រ។ កប៉ាល់នីមួយៗ ត្រូវចេញទៅនេសាទ ហើយរយៈពេលប្រហែល ៣ខែ ទើបត្រឡប់មកវិញម្ដង។ ប៉ុន្តែក៏មានកប៉ាល់ខ្លះបានត្រឡប់មកដែមុនដែរ ព្រោះតែរកត្រីបានគ្រប់ចំនួនមុនពេលកំណត់។ ត្រីនិងគ្រឿងសមុទ្រទាំងអស់ដែលរកបាន គឺលក់ទៅឲ្យប្រទេសថៃនិងប្រទេសសាំងហ្គាពួ ហើយបរិមាណត្រីដែលលក់ចេញម្ដងៗមានចំនួនរាប់ម៉ឺនតោន។ ក្រៅពីនាំចេញត្រីស្រស់ក៏មាននាំចេញទឹកត្រី ត្រីងៀត មឹក បង្គា ក្នុងចំនួនយ៉ាងច្រើនដែរ ។ កប៉ាល់មកពីប្រទេសថៃនិងប្រទេសសាំងហ្គាពួ បានបើកចូលមកយកត្រីនៅម្ដុំកោះស្ដេច ដែលស្ថិតក្នុងខេត្តកោះកុង។ ទន្ទឹមគ្នានោះដែរ យើងបាននាំទំនិញមួយចំនួនចូលមកប្រើប្រាស់រួមមាន ខ្សែភ្លើង ចប ម៉ូទ័រ គោយន្ត និងសម្ភារមួយចំនួនផ្សេងទៀត។ ខ្ញុំធ្វើការនេសាទត្រីនៅឯកំពង់សោមរហូតដល់កងទ័ពវៀតណាមវាយចូលមកក្នុងប្រទេសកម្ពុជា។

នៅពេលដែលកងទ័ពវៀតណាមចូលមកប្រទេសកម្ពុជាក្នុងឆ្នាំ១៩៧៩ ខ្ញុំបានចាកចេញពីកំពង់សោម

ហើយបានឡើងមកប្រយុទ្ធជាមួយកងទ័ពវៀតណាមៗ ក្នុងពេលនោះ ប៉ុល ពត បានឲ្យខ្ញុំបើកកប៉ាល់ចាកចេញទៅប្រទេសចិន ប៉ុន្តែខ្ញុំមិនទៅទេ។

នៅក្នុងឆ្នាំ១៩៧៩ដដែល ខ្ញុំបានជិះកប៉ាល់មកកម្ពុចចោលនៅដងទន្លេ។ បន្ទាប់មក ខ្ញុំបានរៀបចំដេរទៃដើម្បីប្រកអន្តរជាមួយនឹងយោធាមួយចំនួនទៀត។ យើងក៏បានប្រកគ្រាប់រំសេវ និងបើកកាំភ្លើងធំមកច្បាំងជាមួយនឹងកងទ័ពវៀតណាមនៅខេត្តកំពង់ស្ពឺ។ យើងបានច្បាំងគ្នាជាមួយនឹងកងទ័ពវៀតណាមខ្លាំងណាស់ ច្បាំងទាំងយប់ទាំងថ្ងៃ មិនឃើញឈ្នះចាញ់ រហូតទាល់តែអស់គ្រាប់បាញ់ បានយើងនាំគ្នារត់ឡើងទៅលើភ្នំ។ ក្រោយមកយោធាខ្មែរក្រហមមួយចំនួន បាននាំគ្នារត់ភៀសខ្លួនចូលទៅស្នាក់អាស្រ័យលើទឹកដីថៃ ប៉ុន្តែខ្ញុំនៅបន្តរស់នៅក្នុងទឹកដីរបស់យើង។

## នៅតែតស៊ូដើម្បីការពារខ្លួន

រហូតដល់ឆ្នាំ១៩៨០ ខ្ញុំបានភ្ជាប់ខ្សែរយៈជាមួយយោធាខ្មែរក្រហមវិញ។ ខ្មែរក្រហមបានដើរប្រមូលគ្នីគ្នានៅតាមភូមិ។ ពេលនោះ យោធាខ្មែរក្រហមម្នាក់ៗមានរូបរាងស្គមស្លេកស្លាំង ព្រោះតែខ្វះខាតអាហារ។ យើងចេះតែដើរជីកមើមក្តួច មើមដំឡូង យកមកស្ងោរហូប ដោយគ្មានអំបិលស្ករអ្វីសម្រាប់បន្ថែមឲ្យមានរសជាតិនោះទេ។ យើងគ្មានកន្លែងស្នាក់អាស្រ័យឡើយ។ នៅពេលដែលមានភ្លៀងធ្លាក់ម្តងៗ យើងនាំគ្នារត់ទៅនៅក្រោមផ្ទាំងថ្មដ៏ធំៗ ដើម្បីជ្រកភ្លៀង។ ពេលនោះ គឺជាពេលវេលាមួយដែលខ្ញុំពិបាកបំផុត។ ខ្ញុំគ្មានអាហារហូបគ្រប់គ្រាន់ ខ្វះជីវជាតិ ហើយនៅពេលដែលខ្ញុំក្រោកដើរគឺតែងតែវិលមុខរកដួល។ ចំណែកឯ កាំភ្លើងរបស់យើងក៏អស់គ្រាប់ សូម្បីតែសត្វក៏យើងគ្មានឧបករណ៍អ្វីសម្រាប់បាញ់យកមកហូបដែរ។ យើងនាំគ្នាជីកត្រាវស្ងោរហូបនៅក្នុងឆ្នាំងដែលកងទ័ពវៀតណាម ជាន់បោះចោលនៅក្នុងព្រៃដើម្បីចម្អែតក្រពះ។

នៅក្នុងឆ្នាំ១៩៨១ យើងបានរៀបចំសកម្មភាពសារឡើងវិញ។ ខ្ញុំចូលទៅនៅជាមួយកងតាវ៉ែន នៅគណៈប្រក។ មុនដំបូងខ្ញុំនៅជាប់ជាមួយតា វ៉ែន ប៉ុន្តែក្រោយមកនៅពេលដែលមានការរៀបចំកងពល១៨ ដែលគ្រប់គ្រងដោយ កែវ ពង្ស ខ្ញុំបានទៅប្រយុទ្ធនៅឯខេត្តកំពង់ស្ពឺវិញ។ ខ្ញុំទៅឈរជើងប្រចាំនៅខេត្តកំពង់ស្ពឺ និងខេត្តកំពង់ឆ្នាំង។ ក្រៅពីនោះ ខ្ញុំក៏បានធ្វើសកម្មភាពផ្សេងៗឡើងចុះទៅប្រទេសថៃ ហើយរាល់ពេលធ្វើដំណើរម្តងៗយើងតែងតែប៉ះទង្គិចជាមួយនឹងកងទ័ពវៀតណាម។ យើងប្រយុទ្ធជាមួយកងទ័ពវៀតណាម រួចហើយក៏បន្តដំណើរទៅមុខទៀត ចំណែកឯយោធាណាត្រូវរបួសត្រូវសែងត្រឡប់ទៅក្រោយវិញ។ តាមអ្វីដែលខ្ញុំដឹងកងទ័ពវៀតណាមមានគ្រោះថ្នាក់ច្រើនណាស់ ព្រោះវៀតណាម បានយកសិស្សសាលាមកវាយដោយមិនទាន់ចេះពីរបៀបកាន់កាំភ្លើងផង។ ខ្ញុំឃើញមានកងទ័ពវៀតណាមស្លាប់ជាច្រើន និងស្រែកយំពាសពេញព្រៃហើយក៏មានកងទ័ពវៀតណាមមួយចំនួនទៀតវង្វេងព្រៃអត់បាយអត់ទឹក។ កងទ័ពវៀតណាម ដែលស្លាប់ច្រើនជាងគេគឺនៅម្តុំអន្លង់វាប។

កងទ័ពវៀតណាមបានដកទ័ពឈប់បាញ់មុនពេលដែលមានការបង្កើតអនុសញ្ញាទីក្រុងប៉ារីសនៅក្នុងឆ្នាំ១៩៩១។ ក្នុងឆ្នាំ១៩៩២ អ៊ុនតាក់ បានចូលមកដល់ម្តុំតាសាញ។ នៅពេលនោះ ប្រពន្ធរបស់ខ្ញុំឈឺធ្ងន់ណាស់ ហើយទទួលបានការជួយសង្គ្រោះពីពេទ្យអ៊ុនតាក់ ទើបបានរស់នៅរហូតដល់សព្វថ្ងៃនេះ។ ថ្វីត្បិតពេលនោះ មានវត្តមានអ៊ុនតាក់ ក៏ដោយ ប៉ុន្តែភាគីខ្មែរក្រហមនៅមិនទាន់បោះបង់នៅឡើយទេ។ ខ្ញុំបានឡើងមកពីថៃរួចបោះជំរំនៅម្តុំអូរតាទៀក រៀបចំប្រព័ន្ធយោធាឡើងវិញដើម្បីការពារខ្លួន។ យើងនៅតែបន្តមានការប្រុងប្រយ័ត្នជាប់ជានិច្ច។

ចុងក្រោយ ខ្ញុំបានសម្រេចចិត្តត្រឡប់មករស់នៅភូមិក្រពើពីរជាមួយនឹងក្រុមយោធាខ្មែរក្រហមរបស់ខ្ញុំ។ ក្រុមរបស់ខ្ញុំ គឺសុទ្ធតែជាកងកម្លាំងផ្តាច់ខ្លួនមកធ្វើជាយោធាខ្មែរក្រហម ហើយបានបែកចេញពីឪពុកម្តាយតាំងពីអាយុ១៨ឬ១៩ឆ្នាំមកម្ល៉េះ។ យើងបានបែកចេញពីសាច់ញាតិជាយូរណាស់មកហើយ ដូច្នេះយើងគ្មានសង្ឃឹមថា នឹងអាចទទួលបានដីធ្លីសម្រាប់រស់នៅឯស្រុកកំណើតវិញនោះទេ។ ដូច្នេះ ក្រុមរបស់ខ្ញុំបានរួបរួមគ្នាចាប់យកដីធ្លីនៅឯតំបន់ក្រពើពីររស់នៅរហូតដល់សព្វថ្ងៃនេះ។

# ឡុង យំ៖ រៀបរាប់រឿងរ៉ាវក្នុងរបបខ្មែរក្រហម

គាត ស្រីឡែន

ឡុង យំ ភេទស្រី អាយុ៧២ឆ្នាំ ជាជនជាតិស្ទៀង រស់នៅក្នុងភូមិស្រែតាពិជ ឃុំដាំតាម៉ៅ ស្រុកមេមត់ ខេត្តត្បូងឃ្មុំ បានរៀបរាប់បទពិសោធន៍ជីវិតដែលបានឆ្លងកាត់សម័យសង្រ្គាម និងរបបខ្មែរក្រហម (ពីឆ្នាំ១៩៧៥-១៩៧៩) ដូចខាងក្រោម៖

ខ្ញុំមានស្រុកកំណើតនៅភូមិទន្លូង ឃុំទន្លូង ស្រុកមេមត់ ខេត្តកំពង់ចាម។ ឪពុករបស់ខ្ញុំឈ្មោះ ឡុង និងម្តាយឈ្មោះ ប្រាញ់។ ខ្ញុំមានបងប្អូន៣នាក់ ស្រី២ ប្រុស ១ ប៉ុន្តែម្នាក់ស្លាប់ក្នុងរបបខ្មែរក្រហម។ ខ្ញុំមានប្តីឈ្មោះ ម៉ម និងមានកូន៨នាក់ ស្រី៧ ប្រុស១។ សព្វថ្ងៃខ្ញុំនៅសល់តែកូនស្រីម្នាក់ ចំណែក៧នាក់ទៀតបានស្លាប់តាំងពីតូចៗ និងក្នុងរបបខ្មែរក្រហម។ កាលពីនៅក្មេងខ្ញុំបានរៀនតិចតួច ពីព្រោះគ្មានសាលារៀន និងមិនមានគ្រូរស់នៅក្នុងភូមិទន្លូង គឺមានតែគ្រូមកពីស្រុកផ្សេងមកបង្រៀនសិស្សនៅក្នុងភូមិ។ ដោយសារការខ្វះខាតទាំងសាលារៀន និងគ្រូបង្រៀននេះហើយ ទើបខ្ញុំ និងក្មេងៗដ៏ទៃទៀតមិនបានរៀនសូត្រ។ ខ្ញុំរៀនបានត្រឹមថ្នាក់ទី១ ក៏ឈប់រៀនមកជួយធ្វើការងារឪពុកម្តាយ ដូចជាធ្វើស្រែ ចម្ការ ដាំដំណាំផ្សេងៗ និងជួយមើលប្អូនៗនៅផ្ទះ។

នៅពេលខ្ញុំមានអាយុ១៥ឆ្នាំ ឪពុកម្តាយបានផ្សំផ្គុំឲ្យរៀបការ។ នៅពេលរៀបការរួច ខ្ញុំ និងប្តីបានប្រកបរបរធ្វើស្រែចម្ការដូចដែលយើងធ្លាប់បានធ្វើពេលរស់នៅជាមួយឪពុកម្តាយដែរ។

កាលពីក្មេងខ្ញុំមិនធ្លាប់បានឃើញជនជាតិបារាំងទេ ប៉ុន្តែខ្ញុំធ្លាប់ឮចាស់ៗនៅក្នុងភូមិនិយាយថា កាលជំនាន់គាត់នៅក្មេងមានជនជាតិបារាំងជាច្រើនបានមកធ្វើចម្ការ



ឡុង យំ អាយុ៧២ឆ្នាំ ជនជាតិស្ទៀង រស់នៅក្នុងភូមិស្រែតាពិជ ឃុំដាំតាម៉ៅ ស្រុកមេមត់ ខេត្តត្បូងឃ្មុំ។ (គាត ស្រីឡែន/មជ្ឈមណ្ឌលឯកសារកម្ពុជា)

កៅស៊ូនៅក្បែរៗភូមិកំណើតរបស់ខ្ញុំ។ ជនជាតិបារាំងទាំងនេះមានមាឌធំ និងមានស្បែកសៗ។ នៅក្នុងរបបសង្គមរាស្ត្រនិយម ខ្ញុំធ្លាប់ឃើញចម្ការកៅស៊ូរបស់បារាំងដែលមានដើមធំៗ និងមានមនុស្សជាច្រើននាំគ្នាចូលធ្វើជាកម្មករចៀរជ័រកៅស៊ូ។ កម្មករទាំងនោះភាគច្រើនគឺជាជាតិជនវៀតណាម និងមួយចំនួនទៀតគឺជាជនជាតិចាម និងជនជាតិខ្មែរ។ ខ្ញុំធ្លាប់ឮចាស់ៗហៅយួន ពេលនោះសំដៅទៅលើ យួនវ៉ើបុ យួនមានធ្មេញខ្មៅដូចធ្យូង។ ចម្ការ

កៅស៊ូទាំងនោះមានទីតាំងនៅភូមិខ្នាយ និងស្វា ដែលមានចម្ងាយប្រមាណ៤ទៅ៥គីឡូម៉ែត្រប៉ុណ្ណោះ ពីភូមិរបស់ខ្ញុំ។ នៅពេលខ្ញុំជិះកង់ទៅផ្សារដើម្បីទិញឥវ៉ាន់ និងម្ហូបអាហារនៅមេមត់ ខ្ញុំតែងតែជិះកាត់ចម្ការនោះ ប៉ុន្តែខ្ញុំមិនហ៊ានចូលទៅលេង ឬចូលទៅមើលនៅក្នុងចម្ការនោះទេ។ ខ្ញុំបានឃើញកម្មករចៀរជ័រកៅស៊ូជាច្រើនបានទៅផ្សារនៅមេមត់។ កម្មករទាំងនោះធ្លាប់និយាយជាមួយអ្នកភូមិថា ធ្វើកម្មករចៀរជ័រ គឺជារបររកស៊ីទៀងត្រង់ និងមានប្រាក់ខែបើករៀងរាល់សប្តាហ៍។ ជាទូទៅកម្មករចៀរជ័រកៅស៊ូទាំងនោះនាំគ្នាដើរលេង និងទៅផ្សារនៅមេមត់យ៉ាងសប្បាយនៅពេលបើកប្រាក់ខែម្តងៗ និងថែមទាំងមានឡានសម្រាប់ដឹកកម្មករពីចម្ការកៅស៊ូទៅផ្សារមេមត់ទៀតផង។

នៅថ្ងៃទី១៨ ខែមីនា ឆ្នាំ១៩៩៧០ សេនាប្រមុខ លន់ នល់ បានធ្វើរដ្ឋប្រហារទម្លាក់សម្តេចព្រះ នរោត្តម សីហនុ។ ប្តីរបស់ខ្ញុំ និងប្រជាជនផ្សេងទៀតបានទៅចូលរួមធ្វើបាតុកម្មនៅផ្សារមេមត់។ នៅពេលនោះមានភាពច្របូលច្របល់ប្រតាយប្រតប់គ្នាហើយប្តីរបស់ខ្ញុំបានវង្វេងអាវខោទាំងមិនដឹងខ្លួន។ ចំណែកខ្ញុំមិនបានទៅចូលរួមធ្វើបាតុកម្មទេ ព្រោះខ្ញុំទើបនឹងសម្រាលកូនទី ៣ គឺនៅសសៃខ្ចី។

នៅក្នុងឆ្នាំ១៩៧០ ដដែល ទាហានអាមេរិកបានចូលមកក្នុងភូមិរបស់ខ្ញុំ ដើម្បីស្វែងរកកងទ័ពវៀតកុង។ នៅអំឡុងពេលទាហានអាមេរិកចូលមកដល់ភូមិក៏មានការទម្លាក់គ្រាប់បែកពីលើអាកាសច្រើនដែរ។ នៅពេលឃើញមានយន្តហោះទម្លាក់គ្រាប់បែកហោះមកម្តងៗ ខ្ញុំមានអារម្មណ៍ភ័យខ្លាចយ៉ាងខ្លាំង ឪពុកម្តាយរបស់ខ្ញុំតែងតែឲ្យខ្ញុំរត់ចូលក្នុងរណ្តៅត្រង់សេ និងកើបដីគ្របដូចផ្នូរខ្មោច ដើម្បីកុំឲ្យអំបែងខ្ទាតចូល។ ពេលនោះខ្ញុំគិតថាខ្ញុំមិនរស់ទេ ព្រោះគ្រាប់ផ្លោងធ្លាក់មកឮសូរសន្ធឹកគ្រាំងៗ។ ការទម្លាក់គ្រាប់បែកនោះ បានបណ្តាលឲ្យឆេះផ្ទះប្រជាជនក្នុងភូមិរបស់ខ្ញុំអស់ចំនួន ២ខ្នង ប៉ុន្តែមិនមានប្រជាជនណាត្រូវរបួស ឬស្លាប់ឡើយ។ នៅអំឡុងពេលមានសង្គ្រាម កងទ័ពវៀតកុង ក៏បានចូលមកក្នុងភូមិរបស់ខ្ញុំដើម្បីយកអង្រឹងមកដូរជាមួយអង្ករ ឬសត្វឆ្កែទៅហូប ព្រោះកងទ័ពវៀតកុងហូបសាច់ឆ្កែ។ ម៉្យាងទៀតកងទ័ពវៀតកុងមិនចង់ឲ្យមានឆ្កែព្រុសពេលចូលក្នុងភូមិ បើមានឆ្កែព្រុសកងទ័ពវៀតកុងខ្លាចឮដល់ទាហានអាមេរិក ហើយទាហានអាមេរិកអាចចូលមកក្នុងភូមិ ឬក៏បញ្ជូនឲ្យយន្តហោះមកទម្លាក់គ្រាប់បែក។ ដោយសារមានការទម្លាក់គ្រាប់ច្រើនលើកច្រើនសារ ខ្ញុំនិងក្រុមគ្រួសាររួមជាមួយអ្នកភូមិដ៏ទៃទៀតបានចាកចេញពីភូមិទន្លូងមករស់នៅក្នុងភូមិជាំផ្តិន ឃុំជាំតាម៉ៅវិញ។

បន្ទាប់មកខ្ញុំ និងក្រុមគ្រួសារត្រូវបានចាត់តាំងឲ្យចូលធ្វើការងារស្រែចម្ការក្នុងក្រុមប្រវាស់ដៃដោយឪពុករបស់ខ្ញុំធ្វើជាប្រធានភូមិជាំផ្តិន។ នៅក្រោយពេលខ្មែរក្រហមឡើងកាន់អំណាចនៅឆ្នាំ១៩៧៥ ប្រជាជននៅភូមិជាំផ្តិនត្រូវបានខ្មែរក្រហមបង្ខំឲ្យធ្វើពលកម្មរួម និងហូបបាយរួមតាមរោងបាយសហករណ៍។ នៅឆ្នាំ១៩៧៦ ក្រុមគ្រួសាររបស់ខ្ញុំ និងអ្នកភូមិជាំផ្តិនមួយចំនួនត្រូវបានខ្មែរក្រហមជម្លៀសឲ្យមករស់នៅភូមិអន្លង់ ក្នុងឃុំជាំក្រវៀនវិញ។ ដោយសារខ្ញុំមានកូននៅតូចៗ ខ្មែរក្រហមបានចាត់តាំងឲ្យខ្ញុំមើលកូននៅកន្លែងកងកុមារតូចៗ។ ចំណែកប្តីរបស់ខ្ញុំត្រូវចាត់តាំងឲ្យលើកប្រព័ន្ធភ្លឺស្រែ និងសង់អាងទឹកនៅបឹងក្រចាប់នៅជិតស្ពានមាត់ខ្នង ក្នុងស្រុកត្បូងឃ្មុំ។ នៅពេលនោះខ្មែរក្រហមក៏បានជម្លៀសប្រជាជន ១៧មេសា ពីកន្លែងផ្សេងៗឲ្យមករស់នៅក្នុងភូមិអន្លង់ដែរ។ ប្រជាជន ១៧មេសា ភាគច្រើនគឺជាកូនចៅចិនមានស្បែកសៗ និងភ្នែកតូចៗ។ ខ្មែរក្រហមបានចាត់តាំងឲ្យប្រជាជន ១៧មេសា ធ្វើស្រែចម្ការដូចប្រជាជនមូលដ្ឋានដែរ ប៉ុន្តែប្រជាជន ១៧ មេសា ភាគច្រើនបានស្លាប់ដោយសារគ្រុនចាញ់ (ចាញ់ទឹកចាញ់ដី) និងមិនមានអាហារហូបចុកគ្រប់គ្រាន់។ គ្រួសារប្រជាជន ១៧មេសាខ្លះ បានស្លាប់ទាំងគ្រួសារតែម្តង។ មេភូមិនៅភូមិអន្លង់មានឈ្មោះ ជា បានស្លាប់ដោយសារអត់បាយ ពេលដែលខ្មែរក្រហមជម្លៀសទៅខេត្តក្រចេះ។ គណៈឃុំជាំក្រវៀនមានឈ្មោះ តាដួ។

នៅឆ្នាំ១៩៧៨ ខ្មែរក្រហមបានជម្លៀសប្រជាជនទាំងអស់ចេញពីភូមិអន្លង់ឲ្យទៅតំបន់ក្រចេះ។ ខ្មែរក្រហមបានឃោសនាថា ខ្មាចវៀតណាមចាប់ប្រជាជនវះពោះប្រហុកស្មោរ។ ប្រជាជនមានការភ័យខ្លាចក៏ធ្វើដំណើរទៅតាមខ្មែរក្រហម។ ពេលទៅដល់ខេត្តក្រចេះ ខ្ញុំត្រូវបានខ្មែរក្រហមចាត់តាំងឲ្យទៅនៅក្នុងកងចល័ត ធ្វើការងារលើកភ្លឺស្រែ និងជួយស្ទូង។ ចំពោះការហូបចុក ខ្ញុំមានការខ្វះខាតយ៉ាងខ្លាំង។ ប្រជាជនខ្លះបានដួលស្លាប់នៅខណៈពេលកំពុងធ្វើការងារ។ ប្អូនរបស់ខ្ញុំម្នាក់បានស្លាប់នៅខេត្តក្រចេះ ដោយសារខ្មែរក្រហមបង្ខំឲ្យធ្វើយោធា។ ក្នុងរយៈពេលមួយខែដែលខ្ញុំនិងក្រុមគ្រួសាររស់នៅខេត្តក្រចេះ គឺមានប្រជាជនជាច្រើនបានស្លាប់រួមទាំងសាច់ញាតិ និងក្មួយៗខ្ញុំជាច្រើននាក់ទៀត។

បន្ទាប់មក ខ្ញុំនិងក្រុមគ្រួសារ ត្រូវបានខ្មែរក្រហមជម្លៀសបន្តទៅនៅស្រុកចំការលើ ក្នុងភូមិភាគកណ្តាល ដោយជិះកាណូតឆ្លងមកស្រុកស្ទឹងត្រង់។ ខ្ញុំ និងក្រុមគ្រួសារបានស្នាក់នៅក្នុងស្រុកចំការលើបានមួយរយៈ ទើបកងទ័ពស្ម័គ្រចិត្តវៀតណាមចូលមកដល់ ហើយខ្មែរក្រហមក៏រត់គេចខ្លួនអស់។ ខ្ញុំ និងក្រុមគ្រួសារ រួមជាមួយប្រជាជនផ្សេងៗទៀតបានត្រឡប់មកស្រុកកំណើតវិញ ដោយជិះរថយន្តរបស់កងទ័ពវៀតណាម បន្ទាប់មកបានធ្វើដំណើរដោយថ្មើរជើង។ ពេលមកដល់ស្រុក ខ្ញុំ និងក្រុមគ្រួសារមិនបានរស់នៅក្នុងភូមិជាំផ្តិនទេ ដោយសារមិនមានដីស្រែគ្រប់គ្រាន់សម្រាប់ធ្វើស្រែ។ គ្រួសារខ្ញុំ និងអ្នកភូមិផ្សេងទៀតបានផ្លាស់មករស់នៅភូមិស្រែតាពិជវិញ ព្រោះមានដីស្រែធំទូលាយ។ ខ្ញុំនិងគ្រួសារបានរស់នៅភូមិស្រែតាពិជរហូតមកដល់សព្វថ្ងៃ ដោយប្រកបរបបស្រែចម្ការ និងមានជីវភាពល្អប្រសើរជាងកាលពីរបបខ្មែរក្រហម។




សាលាបឋមសិក្សាស្រែតាពេជ្រ ស្ថិតនៅក្នុងឃុំជាំតាម៉ៅ ស្រុកមេមត់ ខេត្តត្បូងឃ្មុំ។ (សុខ វណ្ណៈ/មជ្ឈមណ្ឌលឯកសារកម្ពុជា)

# ខ្មែរក្រហម និង ថៃក្រហម

សួត វិចិត្រ



រូបខាងស្តាំ៖ ឡុប ចំរើន អាយុ៧០ឆ្នាំ រស់នៅភូមិត្រពាំងតាវចាស់ ឃុំត្រពាំងតាវ ស្រុកអន្លង់វែង ខេត្តឧត្តរមានជ័យ។ (សួត វិចិត្រ/មជ្ឈមណ្ឌលឯកសារកម្ពុជា)

ឡុប ចំរើន ភេទប្រុស អាយុ៧០ឆ្នាំ មានទីកន្លែងកំណើតនៅភូមិត្រពាំងតាវចាស់ ឃុំត្រពាំងតាវ ស្រុកអន្លង់វែង ខេត្តឧត្តរមានជ័យ។ ចំរើន បានរៀបរាប់ពីជីវិតតស៊ូរបស់ខ្លួនតទល់ជាមួយនឹងទាហាន លន់ នល់ និងទំនាក់ទំនងជាមួយកងទ័ពថៃក្រហមនៅតាមបណ្តោយព្រំដែនជួរភ្នំដងរែក ដូចខាងក្រោម៖

នៅដើមឆ្នាំ១៩៧០ កងទ័ពខ្មែរក្រហម និងវៀតកុងបានចូលមកដល់តំបន់អន្លង់វែង។ នៅពេលនោះ ប្រជាជននៅក្នុងភូមិត្រពាំងតាវចាស់ ជឿជាក់ថា កងទ័ពដែលចូលមកនោះ គឺជាកងទ័ពរំដោះជាតិរបស់សម្តេចព្រះនរោត្តម សីហនុ ដែលបានផើបបះបោរ បន្ទាប់ពីមានព្រឹត្តិការណ៍រដ្ឋប្រហារ ថ្ងៃទី១៨ ខែមីនា ឆ្នាំ១៩៧០ ដោយសេនាប្រមុខ លន់ នល់។ ប្រជាជននៅក្នុងតំបន់ដាច់ស្រយាលទាំងនោះទទួលការអូសទាញយ៉ាងខ្លាំងឲ្យចូលរួមក្នុងចលនាខ្មែរក្រហម និងវៀតកុងតាមរយៈការឃោសនាឲ្យមានការស្អប់ខ្ពើមរបប លន់ នល់ និងអំពីស្នាវតីតស៊ូបម្រើជាតិមាតុភូមិ។ អាស្រ័យហេតុនេះហើយ ប្រជាជននៅភូមិត្រពាំងតាវចាស់ ប្រមាណ៣០គ្រួសារ រួមទាំងខ្ញុំផង បាន

ចូលនៅក្នុងចលនាខ្មែរក្រហម។

រហូតដល់ឆ្នាំ១៩៧២ បន្ទាប់ពីមានការប្រយុទ្ធគ្នានៅតាមសមរភូមិរួចមក ទាហាន លន់ នល់ មួយចំនួនត្រូវបានចាប់ខ្លួនបន្ទាប់ពីត្រូវបានហ៊ុមព័ទ្ធដោយកងកម្លាំងរំដោះខ្មែរក្រហម។ ទាហាន លន់ នល់ ទាំងនោះបាននាំគ្នាទម្លាក់អាវុធចុះ ហើយចូលខ្លួនមកសារភាពជាមួយកងកម្លាំងរំដោះ។ ទោះបីជាយ៉ាងនេះក្តីឈ្លើយសឹកទាំងនោះមិនត្រូវបានសម្លាប់ឡើយ ដោយទុកឱកាសឲ្យប្តេជ្ញាចិត្តឈប់បម្រើទាហាន លន់ នល់ ទៀត ហើយកុំឲ្យកងកម្លាំងរំដោះចាប់ខ្លួនបានជាលើកទីពីរឲ្យសោះ បើមិនដូច្នោះទេ កងកម្លាំងរំដោះនឹងសម្លាប់ចោលតែម្តង។ ចំណែកឯជម្រើសមួយទៀត គឺឈ្លើយសឹកត្រូវស្ម័គ្រចិត្តចូលរួមបម្រើការតស៊ូជាមួយកងកម្លាំងរំដោះ ឬ កម្លាំងប្រដាប់អាវុធរំដោះជាតិ ឬត្រូវវិលត្រឡប់ទៅកាន់ស្រុកភូមិកំណើតវិញ ។

ក្រោយមក កងទ័ពវៀតកុងបានដកចេញពីប្រទេសកម្ពុជា ហើយមេដឹកនាំខ្មែរក្រហមបានបញ្ជូនខ្ញុំ និងកងកម្លាំងផ្សេងទៀតឲ្យទៅឈរជើងនៅសមរភូមិបុស្ស និងសមរភូមិខ្នារ ក្នុងស្រុកចុងកាល់ ខេត្តឧត្តរមានជ័យ។ យើងបានប្រឈមមុខដាក់គ្នាសាជាថ្មីជាមួយទាហាន លន់ នល់។ សភាពការណ៍នៅពេលនោះ គឺអសន្តិសុខ និងគ្រោះថ្នាក់ដោយសារការបាញ់ផ្លោងដាក់គ្នា។ ការវាយប្រយុទ្ធគ្នាបន្តឲ្យយុទ្ធមិត្តរបស់ខ្ញុំជាច្រើនបានដេកស្លាប់លើដី។ ការរាំងស្ទះដ៏ធំនៃការដឹកជញ្ជូនគ្រឿងសព្វាវុធរបស់កងកម្លាំងរំដោះពីសមរភូមិខាងក្រោយ មិនបានទាន់ពេលវេលា បានបន្តភាពខ្វះខាតសម្រាប់កងកម្លាំងរំដោះ។ ខណៈពេលដែលកងទ័ពរបស់ លន់ នល់ ដឹកជញ្ជូនគ្រាប់រំសេវ និងគ្រឿងសព្វាវុធតាមរថយន្ត កងកម្លាំងរំដោះខ្មែរក្រហមដឹកជញ្ជូនស្បៀង និងគ្រាប់រំសេវដោយថ្មើរជើង និងអាក់ខានជាច្រើនដំណាក់កាលដោយសារការស្ទាក់ និងកាត់ផ្តាច់ផ្លូវពីកងទ័ព លន់ នល់។ ទោះបីជាយ៉ាងនេះក្តី កងកម្លាំងរំដោះនៅតែក្លាហាន និងមិនដកថយពីសមរភូមិឡើយ។ យុទ្ធមិត្តនៃកងកម្លាំងរំដោះម្នាក់ បានបន្តនៅក្នុងព្រៃ និងនៅបន្តការប្រយុទ្ធ។



អតីតកងកម្លាំងខ្មែរក្រហមនៅតំបន់អន្លង់វែង បានធ្វើសមាហរណកម្មចុះចូលជាមួយរាជរដ្ឋាភិបាលកម្ពុជា នៅដើមឆ្នាំ១៩៩៩។ (បណ្ណសារមជ្ឈមណ្ឌលឯកសារកម្ពុជា)

ស្របពេលនោះ ក៏មានការចូលរួមពីប្រជាជននៅទីជនបទដាច់ស្រយាល និងគ្រប់ទិសទីដូច្នេះបានធ្វើឲ្យកងកម្លាំងរំដោះខ្មែរក្រហមកាន់តែមានប្រៀបលើកងទ័ព លន់ នល់ និងទទួលជោគជ័យជាបន្តបន្ទាប់។

នៅថ្ងៃទី១៧ ខែមេសា ឆ្នាំ១៩៧៥ តំបន់អន្លង់វែងហាក់ត្រូវបានផ្លាស់ប្តូរការរស់នៅបន្តិចម្តងៗ ហើយក្រោយមកបង្កើតទៅជាសហករណ៍រស់នៅរួម និងធ្វើការងាររួម។

នៅដើមឆ្នាំ១៩៧៧ ខ្មែរក្រហមបានជម្លៀសប្រជាជនក្នុងតំបន់អន្លង់វែងទាំងអស់ ទៅកាន់ស្រុកក្រឡាញ់ ខេត្តសៀមរាប។ ប្រជាជនជម្លៀសទាំងនោះត្រូវរស់នៅ និងធ្វើការងាររួមនៅក្នុងសហករណ៍។ ចំណែកតំបន់អន្លង់



វែងទាំងមូល បានស្ថិតនៅក្រោមការគ្រប់គ្រងរបស់កងយោធាខ្មែរក្រហម និងមានវត្តមានរបស់កងទ័ពថៃក្រហមនៅទីនោះដែរ។

កងទ័ពថៃក្រហម គឺសំដៅទៅក្រុមតស៊ូរបស់ថៃកុម្មុយនីស្ត។ ប្រវត្តិនៃការតស៊ូរបស់ចលនាថៃក្រហមហាក់ទំនងមានលំហូរ ឬកើតចេញពីប្រទេស ឡាវ ឬតំបន់មួយចំនួននៅតាមបណ្តោយព្រំដែនជួរភ្នំដងរែក។ កងទ័ពទាំងនោះមានឯកសណ្ឋាន ពណ៌ខៀវ និងមានមួកស្រដៀងទៅនឹងកងទ័ពវៀតកុង។ កងទ័ពទាំងនោះ បានប្រដាប់ទៅដោយគ្រឿងសព្វាវុធដែលនាំចូលពីប្រទេសចិន ដូចជាកាំភ្លើងអាកា (AK), គ្រាប់បេ៤០, គ្រាប់បេ៤១ និងប្រភេទកាំភ្លើង៨០មីលីម៉ែត្រជាដើម។ ក្រុមតស៊ូថៃក្រហមទាំងនេះមានការផ្គត់ផ្គង់ស្បៀងអាហារ ឬគ្រឿងសព្វាវុធមួយផ្នែកធំដោយក្រុមខ្មែរក្រហម។ ថ្នាក់ដឹកនាំរបស់ថៃក្រហមទាំងនោះ រួមមាន គឿន, ផាយុង និង ប្រាចាន់ ដែលខ្ញុំធ្លាប់បានស្គាល់។ អ្នកទាំងនោះអាចនិយាយភាសាខ្មែរបានស្ទាត់ និងមានភាពស្និទ្ធស្នាលជាមួយយោធាខ្មែរក្រហម។

កងទ័ពប្រមាណ ពីបួនពាន់នាក់ ទៅប្រាំពាន់នាក់នៃកម្លាំងតស៊ូរបស់ថៃក្រហម ដែលក្នុងនោះក៏មានកងទ័ពនារីដែរ។ កងទ័ពថៃក្រហមទាំងនោះបានទទួលយកគំនិតរួមគ្នានៃមនោគមវិជ្ជាអូសទាញរបស់មេបដិវត្តន៍ថៃក្រហម។ យុទ្ធជនថ្មីថ្មោងនៃចលនាតស៊ូនេះ មានប្រវត្តិជាសិស្ស និងនិស្សិតដែលបានធ្វើដំណើររាប់សិបគីឡូម៉ែត្រពីទីក្រុងថេប ឬបាងកក ប្រទេសថៃ។

ថ្នាក់ដឹកនាំនៃចលនាថៃក្រហម បានដាក់ចេញនូវគោលការណ៍នៅក្នុងដំណាក់កាលដំបូង ដែលឲ្យកងកម្លាំងយុទ្ធមិត្តតស៊ូថ្មីថ្មោងត្រូវប្រដាប់ដោយកាំភ្លើងខ្លីជាជាងប្រភេទអាវុធផ្សេងៗ ដោយហេតុថា ការប្រើប្រាស់កាំភ្លើងខ្លី បានបង្ហាញឲ្យឃើញពីភាពបត់បែនយ៉ាងឆាប់រហ័ស និងការរំដោះខ្លួនចេញពីទីកន្លែងមានអាសន្ន គេចចេញពីខ្មាំងសត្រូវ ឬបាញ់តបទៅលើខ្មាំងសត្រូវនៅពេលអ្នកទាំងនោះមកក្បែរខ្លួន។

នៅពេលនោះ ខ្មែរក្រហមបានបញ្ជូនខ្ញុំទៅរស់នៅក្នុងមន្ទីរមួយ ហៅថា «មន្ទីរកងកេង»។ ក្នុងគ្រានោះ ខ្ញុំអាចនិយាយភាសាថៃបានច្រើនតាមរយៈការធ្លាប់ជួបនិយាយជាមួយកងទ័ពថៃក្រហម។ អាស្រ័យហេតុនេះហើយ ទើបមេអង្គភាពរបស់ខ្ញុំ បានចាត់តាំងខ្ញុំឲ្យទទួលបន្ទុកទៅលើការដឹកជញ្ជូនអង្ករទៅឲ្យកងទ័ពថៃក្រហម។ ក្នុងមួយលើកខ្ញុំបានដឹកអង្ករប្រមាណបីរទេះគោទៅឲ្យកងទ័ពទាំងនោះដែលមានមូលដ្ឋានឈរជើងនៅក្នុងសមរភូមិឃុំថ្កូវ, អូរត្រសេក និង អូរកំបុត ដែលស្ថិតនៅតាមបណ្តោយជួរភ្នំដងរែក។ ខ្ញុំបានធ្វើដំណើរដោយឆ្លងកាត់ព្រៃជ្រៅអស់រយៈពេលជាច្រើនម៉ោងទម្រាំទៅដល់ទីនោះ។ តាមអ្វីដែលខ្ញុំធ្លាប់បានដឹង កងទ័ពថៃក្រហម បានស្ថិតនៅរាយប៉ាយតាមព្រំដែនតាមបណ្តោយជួរភ្នំដងរែក ដែលចាប់ផ្តើមពីសមរភូមិផ្សារ ទៅដល់សមរភូមិបាក់នីម។

បន្ទាប់ពីប្រមូលកម្លាំងបានច្រើនគ្រាស់គ្រែលហើយ កងទ័ពថៃក្រហម ដែលរួមសហការជាមួយខ្មែរក្រហមបាន

វាយរំដោះយកខេត្តមួយចំនួននៃប្រទេសថៃ ដែលរួមមានខេត្តសុរិន្ទ ឬខេត្តមួយចំនួនទៀតដែលនៅជាប់ព្រំដែន។ ព្រឹត្តិការណ៍នៃការវាយរំដោះនេះ បានបង្ខំឲ្យប្រជាជនថៃនៅក្នុងតំបន់នោះ រត់ភៀសខ្លួនចូលមកទឹកដីកម្ពុជា។ ប្រជាជនដែលមានវ័យចំណាស់ជាច្រើននាក់ រួមទាំងកុមារតូចៗផង បានធ្វើដំណើរដោយថ្មើរជើង និងស្ពាយអីវ៉ាន់សំពីងសំពោងចុះពីលើខ្នងភ្នំដងរែក។ ប្រជាជនមួយចំនួនបានបីកូនតូចៗ ហើយមួយចំនួនទៀតបានបណ្តើរកង់ចាស់ៗដឹកជញ្ជូនសម្ភារប្រើប្រាស់ចាំបាច់។

រហូតដល់ដើមឆ្នាំ១៩៧៩ បន្ទាប់ពីកងទ័ពរណសិរ្សសាមគ្គីសង្គ្រោះជាតិកម្ពុជា និងកងទ័ពស្ម័គ្រចិត្តវៀតណាមបានវាយលុកចូលមកប្រទេសកម្ពុជា កងទ័ពថៃក្រហមបានរត់ឡើងភ្នំដងរែក រួចចូលរួមជាមួយថៃសេរីវិញ ដោយសារខ្វះការគាំទ្រផ្នែកស្បៀងអាហារ និងសម្ភារពីខ្មែរក្រហម។ កងទ័ពរបស់ខ្មែរក្រហមនៅពេលនោះខ្វះខាតស្បៀងអាហារ និងគ្រឿងសព្វាវុធដែរ បន្ទាប់ពីកងទ័ពស្ម័គ្រចិត្តវៀតណាមកាត់ផ្តាច់ផ្លូវដឹកជញ្ជូន។ កងទ័ពរបស់ខ្មែរក្រហមដែលនៅមិនឆ្ងាយពីព្រំដែនថៃបាននាំគ្នារៀបចំកម្លាំងរត់ឡើងភ្នំដងរែក និងមានបំណងឆ្លងដែនចូលក្នុងប្រទេសថៃ។ ប៉ុន្តែភ្លាមៗនោះ កងទ័ពថៃសេរីមិនអនុញ្ញាតឲ្យយោធាខ្មែរក្រហមចូលឡើយ ដោយសារធ្លាប់មានការប៉ះទង្គិចគ្នាពីមុនមក។ កងទ័ពថៃសេរីទាំងនោះ មានបំណងកាត់ផ្តាច់ទំនាក់ទំនងរវាងយោធាខ្មែរក្រហម និងថៃក្រហមទាំងស្រុង ដើម្បីកុំឲ្យមានចលនាបះបោរ និងអសន្តិសុខដល់ប្រទេសជាតិរបស់ខ្លួនតទៅទៀត។ ចាប់តាំងពីពេលនោះមក យោធារបស់ខ្មែរក្រហមបានដាច់ខ្សែរយៈបន្តិចម្តងៗពីថៃក្រហមរហូតបាត់ដំណឹងសូន្យឈឹងតែម្តង។

ចំណែកយោធាខ្មែរក្រហមនៅខាងក្នុងប្រទេសកម្ពុជា បានបន្តធ្វើសង្គ្រាម ហើយនៅក្នុងអំឡុងពាក់កណ្តាលទសវត្សរ៍ឆ្នាំ១៩៨០ ដែលភាគច្រើននៃសមរភូមិតាមបណ្តោយជួរភ្នំដងរែក ត្រូវបានគ្រប់គ្រងដោយកងទ័ពស្ម័គ្រចិត្តវៀតណាម។

ដោយសារសភាពការណ៍មិនអំណោយផល យោធាខ្មែរក្រហមបាននាំគ្នាបន្តរស់នៅលើជម្រាលភ្នំដងរែក ហើយរង់ចាំឱកាសល្អ ដើម្បីនឹងចូលទៅក្នុងដីប្រទេសថៃ។ ខ្ញុំនិងយោធាខ្មែរក្រហមបានរស់នៅដោយមិនមានស្បៀងអាហារហូបចុកគ្រប់គ្រាន់។ នៅពេលមួយ ខ្ញុំបានបង្ខំចិត្តដឹកនាំកងកម្លាំងយោធាមួយក្រុមទៅលួចដកដំឡូងមីនៅក្នុងចម្ការរបស់ថៃ ដែលនៅមិនឆ្ងាយប៉ុន្មានពីទីកន្លែងស្នាក់នៅរបស់យើង។ មួយរយៈពេលខ្លីប៉ុណ្ណោះ ចម្ការដំឡូងមីប្រហែលពីរហិចតា បានដួលរាបដល់ដី បន្ទាប់ពីយើងបានដកយកមើមទាំងអស់។

ក្រោយមក យើងក៏មានឱកាសបានចូលទៅក្នុងទឹកដីថៃ និងទទួលបានរបបអាហារ ក្រោមការផ្គត់ផ្គង់ពីអង្គការអន្តរជាតិ កាកបាទក្រហមបារាំង។

នៅក្នុងឆ្នាំ១៩៨៦ កងកម្លាំងនៅតំបន់អន្លង់វែងត្រូវបានបែកចែក។ នៅពេលនោះ ខ្ញុំបានចូលបម្រើក្នុងទាហានប៉ាវ៉ា ឬទាហានហ៊ុនស៊ិនប៉ិច នៅពេលដែលកម្លាំងនៅតំបន់អន្លង់វែង ត្រូវបានបែងចែកជាពីរ។ ខ្ញុំចូលរួមប្រយុទ្ធនៅក្នុងសមរភូមិក្តៅនៅច្រកតាទុំ។ ខ្ញុំមិនមានជម្រើសផ្សេងទេ ដែលត្រូវប្រយុទ្ធជាមួយកងកម្លាំងដែលធ្លាប់ជាមិត្តរួមអាវុធនាពេលកន្លងមក។ ប៉ុន្តែទោះយ៉ាងនេះក្តី ដើម្បីរស់រានមានជីវិត ខ្ញុំត្រូវតែបត់បែនឲ្យស្របទៅនឹងស្ថានភាពដែលខ្ញុំកំពុងជួបប្រទះ។

នៅក្នុងឆ្នាំ១៩៩៣ ខ្ញុំបានវិលត្រឡប់មកចូលរួមក្នុងកងកម្លាំងរបស់ តាម៉ុក។ យើងបានប្រយុទ្ធគ្នាជាមួយកងទ័ពរាជរដ្ឋាភិបាលកម្ពុជាជាច្រើនលើកច្រើនសា។ បន្ទាប់មក ខ្ញុំបានផ្តាច់ខ្លួន និងធ្វើសមាហរណកម្មចុះចូលជាមួយរាជរដ្ឋាភិបាលកម្ពុជានៅភូមិវាលតាដេវ ក្នុងតំបន់អន្លង់វែង នៅដើមឆ្នាំ១៩៩៩។

# កប៉ាល់របស់ចិនបានដឹកទំនិញចេញពី ឃ្លាំងរដ្ឋរបស់ខ្មែរក្រហម

*មេក វិន*



*អ៊ុន ណាម អាយុ៥៦ឆ្នាំ រស់នៅភូមិទួលសាលា ឃុំត្រពាំងប្រីយ៍ ស្រុកអន្លង់វែង ខេត្តឧត្តរមានជ័យ។ (មេក វិន/មជ្ឈមណ្ឌលឯកសារកម្ពុជា)*

អ៊ុន ណាម ភេទស្រីអាយុ៥៦ឆ្នាំ មានស្រុកកំណើតនៅភូមិដូនអុន ឃុំដូនកែវ ស្រុកពួក ខេត្តសៀមរាប។ អ៊ុន ណាម បាននិយាយរៀបរាប់អំពីការងារក្នុងក្រសួងឃ្លាំងរដ្ឋរបស់ខ្មែរក្រហមនៅក្នុងទីក្រុងភ្នំពេញ ដូចខាងក្រោមថា ៖

មុនឆ្នាំ១៩៧០ ខ្ញុំបានរស់នៅផ្ទះជួបជុំគ្រួសារ និងជួយធ្វើស្រែចម្ការឪពុកម្តាយ។ បន្ទាប់ពី លន់ នល់ បានធ្វើរដ្ឋប្រហារទម្លាក់សម្តេចព្រះ នរោត្តម សីហនុ នៅថ្ងៃទី១៨ ខែមីនា ឆ្នាំ១៩៧០ ប្រទេសជាតិក៏ចាប់ផ្តើមកើតមានសង្គ្រាម។ ភូមិដូនអុន ក៏ស្ថិតក្នុងស្ថានភាពវឹកវរ។ គ្រួសាររបស់ខ្ញុំ រួមទាំងប្រជាជនជាច្រើនទៀត ត្រូវបានជម្លៀសចេញពីស្រុកកំណើត។ មិនយូរប៉ុន្មានឪពុកខ្ញុំក៏បានចូលធ្វើយោធាខ្មែរក្រហម។

ក្នុងឆ្នាំ១៩៧៦ ខ្ញុំ ម្តាយរបស់ខ្ញុំ និងប្អូនប្រុសខ្ញុំ ម្នាក់ត្រូវបានខ្មែរក្រហមបញ្ជូនទៅទីក្រុងភ្នំពេញ។ ទិដ្ឋភាពនៅក្នុងទីក្រុងភ្នំពេញនៅពេលនោះគឺស្ងាត់ជ្រងំ និងគ្មានប្រជាជនរស់នៅទេ។ ខ្ញុំបានឃើញតែកងទ័ពខ្មែរក្រហមនៅតាមផ្លូវតែប៉ុណ្ណោះ។ នៅពេលទៅដល់ភ្នំពេញភ្លាមខ្ញុំត្រូវបានបញ្ជូនទៅក្រុងតាខ្មៅ។ ប៉ុន្តែឪពុកខ្ញុំបានស្នើសុំប្រធានកងវរសេនាតូចឲ្យខ្ញុំនៅជាមួយនារីៗ និងជួយធ្វើការងារនៅក្នុង «ក្រសួងឃ្លាំងរដ្ឋ» ដែលស្ថិតនៅត្រង់គីឡូម៉ែត្រលេខ៦ នៅតាមបណ្តោយផ្លូវជាតិលេខ៥។ ក្រសួងឃ្លាំងរដ្ឋ គឺជាកន្លែងទទួលស្បៀងអង្ករ ដឹកជញ្ជូនអំបិល អង្ករ ក្រណាត់ ស្បែកជើង សម្លៀកបំពាក់ និង សម្ភារផ្សេងៗ ដែលដឹកជញ្ជូនមកពីតាមបណ្តាភូមិភាគ បន្ទាប់មកបែងចែកទៅតាមតំបន់ និងនាំចេញទៅក្រៅប្រទេស។ ជាក់ស្តែង នៅពេលមានការដឹកអង្ករ មកពីតាមភូមិភាគ ខ្ញុំនិងអ្នកធ្វើការនៅឃ្លាំងរដ្ឋត្រូវជ្រើសរើសគ្រាប់ស្រូវចេញពីអង្ករ ដើម្បីចម្រាញ់យកអង្ករដែលមានគុណភាពល្អលេខ១ ដើម្បីនាំចេញទៅប្រទេសចិន។ ចំណែកឯអំបិលវិញ ខ្ញុំនិងអ្នកធ្វើការនៅឃ្លាំងរដ្ឋមិនសូវពិបាក ឬចំណាយពេលរើសយូរដូចអង្ករនោះទេ។ នៅពេលដែលអំបិលត្រូវបានដឹកចូលមក យើងគ្រាន់តែវែងឲ្យអស់ដី។ បន្ទាប់ យើងច្រកអំបិលទៅក្នុងបាវ ដើម្បីដឹកចេញទៅតាមភូមិភាគវិញ។ អ្នកធ្វើការនៅក្រសួងឃ្លាំងរដ្ឋ មានចំនួនមួយវរសេនាតូច ដែលមានសមាជិកទាំងអស់៧០០នាក់។ កម្លាំងទាំងអស់ត្រូវបែងចែកជាបីវេន ដើម្បីបំពេញការងារទាំងយប់ទាំងថ្ងៃ។ យើងអាចឈប់សម្រាកបានបីថ្ងៃក្នុងមួយខែ។ នៅថ្ងៃឈប់សម្រាក ប្រធានកងវរសេនាតូច បានអនុញ្ញាតឲ្យ ឡានដឹកជញ្ជូនយើងទៅសម្រាកលំហែរនៅបឹងទំពុន។ ប៉ុន្តែ យើងមិនជួបអ្នកធ្វើការប្រុសៗទេ។

បឹងទំពុន គឺជាកន្លែងសម្រាប់ដាក់ជនពិការៗ នៅទីនោះ យើងមានផ្លែឈើដាំដោយខ្លួនឯងច្រើនណាស់ៗ យើងចង់ហូបផ្លែឈើអ្វីក៏បានដែរ មានដូចជាផ្លែជម្ពូរ ទៀបបារាំង ស្វាយ ចេក និងត្របែកជាដើមៗ នៅពេលបាយថ្ងៃត្រង់ ចុងភៅដឹកបាយឲ្យយើងៗ នៅពេលល្ងាច អ្នកបើក ឡានដឹកយើងមកកន្លែងធ្វើការវិញៗ ខ្ញុំទទួលបានអាហារគ្រប់គ្រាន់ចំនួនបីពេលជារៀងរាល់ថ្ងៃៗ ប៉ុន្តែខ្ញុំបានទទួលការរៀនអក្សរចំនួន១ម៉ោង ក្នុងមួយថ្ងៃៗ ខ្ញុំចេះអានតែពាក្យ «កម្ពុជា» មួយប៉ុណ្ណោះៗ

បន្ទាប់ពីធ្វើការងាររួចរាល់ ខ្ញុំ និងយុវនារីៗដទៃទៀតតែងតែមានឱកាសនាំគ្នាគ្នាទៅមើលការសម្តែងសិល្បៈនៅវត្តភ្នំៗ ខ្ញុំក៏ធ្លាប់បានទៅមើលការចាក់បញ្ចាំងភាពយន្តនៅផ្សារដើមគរដែរៗ ភាគច្រើននៃភាពយន្តខ្មែរក្រហមបង្ហាញពីការបាញ់កាំភ្លើង និងយុទ្ធសាស្ត្រធ្វើសង្គ្រាមជាដើមៗ នៅពេលដែលកប៉ាល់របស់ចិនចូលចតនៅកំពង់ផែ ក្បែរក្រសួងឃ្លាំងរដ្ឋម្តងៗ ចិនក៏បានចាក់បញ្ចាំងភាពយន្តឲ្យមើលដែរៗ ប៉ុន្តែ នៅពេលដែលប្រធានកងវរសេនាតូចនៅក្រសួងឃ្លាំងរដ្ឋ បានដឹង យើងលែងមានឱកាសមើលភាពយន្តទៀតៗ ប្រធានកងវរសេនាតូចក៏បានប្រាប់ជនជាតិចិន ឲ្យបិទការចាក់បញ្ចាំងកុនដែរៗ

ខ្ញុំធ្វើការនៅក្រសួងឃ្លាំងរដ្ឋ ចាប់តាំងពីឆ្នាំ១៩៧៦ រហូតដល់ចុងឆ្នាំ១៩៧៨ៗ មុនពេលដែលវៀតណាមវាយលុកចូលមកក្នុងប្រទេសកម្ពុជា ស្ថានភាពនៅឃ្លាំងរដ្ឋក្នុងទីក្រុងភ្នំពេញ មានសភាពកាន់តែមមាញឹកឡើង ដោយឃើញមានការចេញចូលរបស់កប៉ាល់ជាច្រើនៗ សមាជិកទាំង៧០០នាក់ នៃកងវរសេនាតូចរបស់ខ្ញុំ ត្រូវបានប្រាប់ឲ្យចាកចេញពីកន្លែងស្នាក់នៅចំនួន៣ថ្ងៃ នឹងធ្វើដំណើរ



អ៊ុន ណម និង កូនស្រីៗ (មេក វិន/មជ្ឈមណ្ឌលឯកសារកម្ពុជា)

ទៅតាមផ្លូវឆ្ពោះទៅពោធិ៍ចិនតុងជាបណ្តោះអាសន្នសិនៗ ដោយសារយើងមិនអាចដើរចេញផុតពីភ្នំពេញ ក្នុងរយៈពេលមួយយប់បាន យើងក៏បានសម្រេចចិត្តឈប់សម្រាកនៅតាមផ្លូវៗ ពេលរាត្រីដ៏សែនត្រជាក់ គួបផ្សំជាមួយសំឡេងរថក្រោះជាច្រើនគ្រឿង ដែលកំពុងបើកសំដៅចូលក្នុងទីក្រុងភ្នំពេញវិញ ខ្ញុំមិនអាចដេកលក់ឡើយនៅក្នុងយប់នោះៗ លុះព្រឹកឡើង ឡានអង្គភាពបានមកទទួលយើងនិងបើកសំដៅទៅនៅខាងខដុង្គៗ

ការវាយលុករបស់កងទ័ពវៀតណាម នៅក្នុងឆ្នាំ១៩៧៩ បានបង្កឲ្យមានភាពវឹកវរកាន់តែខ្លាំងឡើងៗ ខ្ញុំក៏បានបែកពីឪពុកម្តាយ និងប្អូនប្រុស ខ្ញុំជារៀងរហូតៗ បន្ទាប់មក ខ្ញុំក៏ត្រូវចាកចេញពីខដុង្គទៅកាន់តំបន់ព្រំដែនខ្មែរថៃៗ នៅពេលទៅដល់តំបន់ភ្នំបេង យើងបានធ្វើដំណើរថ្មើរជើងឆ្ពោះទៅកាន់ព្រំដែនបន្តទៀតៗ ប្រធានវរសេនាតូចបានប្រកាសប្រាប់ឲ្យយើងស្នាក់នៅតាមព្រំដែនខ្មែរ-ថៃមួយរយៈពេលសិនៗ មិនយូរប៉ុន្មាន ក៏មានការប្រជុំដើម្បីអនុញ្ញាតឲ្យយើងជ្រើសរើសរវាងការចូលទៅរស់នៅក្នុងជំរុំក្នុងទឹកដីថៃ និងការវិលត្រឡប់ទៅរស់នៅខាងភូមិភាគឧត្តរៗ បន្ទាប់ពីការប្រជុំនោះ មីងៗភាគច្រើនបានជ្រើសរើសយកការវិលទៅភូមិភាគឧត្តរៗ ខ្ញុំក៏បានសម្រេចចិត្តមកនៅភូមិភាគឧត្តរតាមមីងៗដែរៗ ក្នុងពេលធ្វើដំណើរទៅភូមិភាគឧត្តរ យើងបានចាកចេញនៅម៉ោង៧យប់តាមរថយន្តជាច្រើនគ្រឿង និងបានទៅដល់ភូមិភាគឧត្តរ (៨០៨) នៅវេលាម៉ោង៤ទាបភ្លឺៗ នៅទីនោះ ខ្ញុំបានរស់នៅជាមួយបងនារីៗៗ កិច្ចការរបស់ខ្ញុំគឺដឹកជញ្ជូនគ្រាប់ដែលស្ថិតនៅក្បែរកន្លែងស្នាក់នៅ ដោយសារខ្ញុំមិនបានចូលជាកងនារីដឹកជញ្ជូនៗ

ខ្ញុំបានរៀបការនៅក្នុងឆ្នាំ១៩៨៤ៗ ក្រោយមក ខ្ញុំទទួលភារកិច្ចបិតចំរូងនៅមូលដ្ឋានក្រោយវិញៗ ខ្ញុំបានរស់នៅជំរំរហូតដល់ឆ្នាំ១៩៩០ តាម៉ុក ក៏បញ្ជូនឲ្យយើងចុះមកតំបន់អន្លង់វែងៗ នៅក្នុងឆ្នាំ១៩៩៣ អ៊ុនតាក់ក៏ចូលមកដល់ៗ គ្រួសារខ្ញុំ និងប្រជាជនជាច្រើននាក់ទៀតត្រូវភៀសខ្លួនទៅជំរំភូណោយក្នុងប្រទេសថៃសាជាថ្មីៗ ខ្ញុំបានរស់នៅក្នុងជំរំរហូតដល់កម្លាំងខ្មែរក្រហមនៅតំបន់អន្លង់វែងធ្វើសមាហរណកម្មចូលក្នុងសង្គមជាតិវិញក្នុងឆ្នាំ១៩៩៨ៗ ខ្ញុំ និងគ្រួសារបានចុះពីភ្នំមកនៅក្នុងភូមិទួលសាលារហូតដល់សព្វថ្ងៃនេះៗ













# ការិយាល័យ ព័ត៌មានសាធារណៈ

«ការិយាល័យព័ត៌មានសាធារណៈ» របស់មជ្ឈមណ្ឌលឯកសារកម្ពុជាបានបើកបម្រើជូន និស្សិត អ្នកស្រាវជ្រាវ បុគ្គលិករាជការ និងអង្គការក្រៅរដ្ឋាភិបាល និងបុគ្គលទាំងឡាយដែលមានចំណាប់អារម្មណ៍ពីការវិវឌ្ឍន៍របស់អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា ឬសាលាក្តីខ្មែរក្រហម។

មជ្ឈមណ្ឌលឯកសារកម្ពុជាជាកន្លែងប្រមូលផ្តុំ និងចងក្រងឯកសារអំពីរបបកម្ពុជាប្រជាធិបតេយ្យបានច្រើនបំផុត។ ឯកសារនៅមជ្ឈមណ្ឌលឯកសារកម្ពុជាមានប្រាំប្រភេទ។ ប្រភេទឯកសារទីមួយគឺឯកសារជាក្រដាសសន្លឹកដែលមានចំនួនជិតមួយលានទំព័រ។ ប្រភេទឯកសារទីពីរ គឺជាបទសម្ភាសន៍ដែលបុគ្គលិកមជ្ឈមណ្ឌលឯកសារកម្ពុជាចុះទៅធ្វើសម្ភាសន៍ជាមួយជនរងគ្រោះ និងអតីតកម្មាភិបាលខ្មែរក្រហម។ ប្រភេទឯកសារទីបីគឺជារូបថតទាក់ទងទៅនឹងសម័យខ្មែរក្រហម។ ប្រភេទឯកសារទីបួនគឺជាឯកសារទាក់ទងទៅនឹងការធ្វើផែនទីរណ្តៅសាកសព និងទីតាំងសម្លាប់របស់ខ្មែរក្រហម និងឯកសារទីប្រាំគឺជាខ្សែភាពយន្តឯកសារដែលបានផលិតឡើងក្នុងរបបខ្មែរក្រហម និងសម័យក្រោយមកទៀត។

តាមរយៈការិយាល័យព័ត៌មានសាធារណៈ សាធារណជនអាចនឹងស្រាវជ្រាវឯកសារទាំងនេះបាន។ ឯកសារខ្លះទៀតរួមមាន៖ ប្រវត្តិរូបកម្មាភិបាលខ្មែរក្រហម ចម្លើយសារភាពកំណត់ហេតុរបស់បក្សទូរលេខឆ្លើយឆ្លងព័ត៌មានដែលបានមកពីការសម្ភាសន៍ជាមួយអតីតកម្មាភិបាលខ្មែរក្រហម និងទិន្នន័យគន្ថនិទ្ទេសបង្ហាញពីរណ្តៅសាកសព ទីតាំងគុក និងបូជនីយដ្ឋានប្រល័យពូជសាសន៍។

ការិយាល័យព័ត៌មានសាធារណៈមានទីតាំងនៅអគារលេខ៦៦ មហាវិថីព្រះសីហនុ សង្កាត់ទន្លេបាសាក់ ខណ្ឌចំការមន រាជធានីភ្នំពេញ។ ការិយាល័យរបស់យើងបើកជូនសាធារណជនចាប់ពីថ្ងៃចន្ទដល់ថ្ងៃសុក្រ ពេលព្រឹកពីម៉ោង ៨៖០០ ដល់ម៉ោង ១២៖០០ និងពេលរសៀលពីម៉ោង ២៖០០ ដល់ម៉ោង ៥៖០០។ ប្រសិនបើអស់លោកអ្នកមានចម្ងល់ ឬចង់រៀបចំព្រឹត្តិការណ៍ជាក្រុមណាមួយ សូមទាក់ទងបុគ្គលិករបស់យើង ស៊ាង ចិន្តា អ្នកសម្របសម្រួល តាមរយៈទូរសព្ទលេខ៖ ០១២ ៦៦៣ ៦១១ ឬ អ៊ីម៉ែល៖

truthchenda.s@dccam.org

សូមអរគុណ!












# សាលក្រមសំណុំរឿង០០២/០២

## ដកស្រង់ចេញពីឯកសារដែលបានផ្សព្វផ្សាយជាសាធារណៈរបស់សាលាក្តីខ្មែរក្រហម

**ដារ៉ាវុឌ្ឍ មេត្តា**

(តពីលេខមុន)

...ពលទ័ពចំនួន៥.៣៦៩នាក់ នៅក្នុងខែមីនា ឆ្នាំ១៩៧៧។

**៥.៣.១.២.១.៨. កងពល ៨០១**

**៩៤០.** កងពលមជ្ឈិម៨០១ ពីមុនមកគឺជាកងពលលេខ ១៤ របស់ភូមិភាគពិសេសដែលត្រូវបានរំលាយបន្ទាប់ពីការកាន់កាប់ទីក្រុងភ្នំពេញ នៅក្នុងខែមេសា ឆ្នាំ១៩៧៥។ កងពលនេះត្រូវបានបញ្ជូនទៅភូមិភាគឦសាន (ខេត្តរតនគិរី) ឈរជើងនៅស្រុកបានលុងមួយរយៈពេលខ្លីមុនពេលផ្លាស់ទៅស្រុកវ៉ឺនសៃ នៅក្នុងខែវិច្ឆិកា ឬ ខែធ្នូ ឆ្នាំ១៩៧៥។ កងពលនេះដឹកនាំដោយ សូ សារឿន ហៅ តា០៥ ហៅ រឿន នៅពេលអំឡុងកម្ពុជាប្រជាធិបតេយ្យ។ មេបញ្ជាការរងគឺតាសាន ហៅតា ០៦ និង តា ឡី ដែលបានកាន់តំណែងនៅទីនេះរហូតដល់ពាក់កណ្តាលឆ្នាំ១៩៧៧ នៅពេលនោះពួកគាត់ត្រូវបានចាត់តាំងឲ្យទៅធ្វើការនៅកងពល៩២០ នៅក្នុងតំបន់ ១០៥ (ខេត្តមណ្ឌលគិរី)។ អតីតមេបញ្ជាការកងវរសេនាធំនៃកងពលលេខ១១៤ គឺ អ៊ុង វ៉ែន និង កែវ សារឿន ដែលបានកាន់កាប់តំណែងជាមេបញ្ជាការរងរបស់កងពល ៨០១ ក្នុងរយៈពេលខ្លីនៅដើមឆ្នាំ ១៩៧៧ ដល់ពាក់កណ្តាលឆ្នាំ១៩៧៧។ ក្រោយមកតំណែងនេះមិនត្រូវបានគេដាក់ជំនួស ឬចាត់តាំងបុគ្គលណាជាបន្តនោះទេ។

**៥.៣.១.២.១.៩. កងពល៩២០**

**៩៤១.** កងពលមជ្ឈិម៩២០ មានវត្តមាននៅក្នុងតំបន់ ១០៥(តំបន់មណ្ឌលគិរី) តាំងពីឆ្នាំ១៩៧៥ មកម្ល៉េះដែលដំបូងឡើយ កងពលនេះស្ថិតក្រោមការបញ្ជាការរបស់ មាស ម៉េង ហៅ ឈិន អម ដោយមេបញ្ជាការរងដែលមានឈ្មោះ អ៊ា ជី ហៅ សយ។ បន្ទាប់ពីពួកគាត់ត្រូវបានចាប់ខ្លួននិងយកទៅឃុំនៅក្នុងមន្ទីរសន្តិសុខស-២១ នៅខែកុម្ភៈ និងខែមីនា ឆ្នាំ១៩៧៧ កងពលនេះស្ថិតក្រោមការបញ្ជាការរបស់អតីតមេបញ្ជាការរងនៃកងពល ៨០១ គឺ សាន ហៅតា ០៦ ហៅ តា ឡី។ ចាន់ គង់ ហៅ គីម គឺជាអនុប្រធាននៃកងពល ៩២០ យ៉ាងហោចណាស់រហូតដល់ពេលដែលគាត់ត្រូវបានបញ្ជូនទៅមន្ទីរសន្តិសុខស-២១ នៅក្នុងខែធ្នូ ឆ្នាំ១៩៧៨។ ដោយមានទីបញ្ជាការដែលមានចម្ងាយប្រមាណប្រាំពីរគីឡូម៉ែត្រពីខាងត្បូងភ្នំក្រោល កងពលនេះបានបញ្ចូលកងវរសេនាតូចចំនួនបី (កងវរសេនាតូច ៩១,៩២ និង ៩៣) ទៅដាក់នៅតំបន់ ១០៥ ទាំងមូលដើម្បីល្បាតនិងការពារព្រំដែនខ្មែរជាប់ជាមួយវៀតណាម ហើយកងពលនេះមានកងទ័ពចំនួន ៣.៥២៨នាក់ នៅត្រឹមខែមីនា ឆ្នាំ១៩៧៧។ កងពល ៩៣០ គឺជាកងពលមជ្ឈិមដែលតូចជាងគេ។

**៥.៣.១.២.១.១០. កងវរសេនាធំឯករាជ្យ**

**៩៤២.** អង្គជំនុំជម្រះយល់ឃើញថា ក្នុងអំឡុងរបបកម្ពុជាប្រជាធិបតេយ្យ កងវរសេនាធំឯករាជ្យស្ថិតនៅក្រោមការគ្រប់គ្រងផ្ទាល់របស់សេនាធិការ រួមមាន កងវរសេនាធំ ៧៥, កងវរសេនាធំ ១៥២,កងវរសេនាធំ ៣៧៧, កងវរសេនាធំ ៤៨៨, មន្ទីរ ៦២, មន្ទីរ ៦៣ និងមន្ទីរសន្តិសុខស-២១។ អង្គជំនុំជម្រះកត់សម្គាល់ឃើញថា នៅពេលខ្លះកងពលសេនាធំទាំងអស់នេះត្រូវបានគេហៅថាកងពល។ លើសពីនេះទៀត អង្គជំនុំជម្រះយល់ឃើញថា ការសន្និដ្ឋានដែលថាអង្គភាពទាំងប្រាំពីរនេះអត្ថិភាព

នោះ មិនបានប្រាប់ច្បាស់លាស់ទេ។ ក្រៅពីសមាសភាពដែលថាចំនួននៃកងវរសេនាធំឯករាជ្យអាចមានច្រើនជាងចំនួនដែលភស្តុតាងបានបង្ហាញនៅក្នុងសំណុំរឿងនេះឡើយ។

**៤៤៣.** កងវរសេនាធំឯករាជ្យ៧៥ គឺជាកងកាត់ដេរ។ សមមិត្ត វ៉ន គឺជាលេខាវរសេនាធំ ៧៥ ។ ជុំ គូ គឺជាអនុប្រធានរបស់សមមិត្ត វ៉ន យ៉ាងហោចណាស់រហូតដល់ថ្ងៃទី២៨ ខែសីហា ឆ្នាំ១៩៧៧ គឺនៅពេលដែលគាត់ត្រូវបានបញ្ជូនទៅមន្ទីរសន្តិសុខ ស-២១។

**៤៤៤.** កងវរសេនាធំឯករាជ្យ១៥២ គឺជាកងទ័ពជើងទឹក។ លេខាកងពលវរសេនាធំ១៥២ គឺសមមិត្ត ស៊ឹម។ អនុលេខាគឺ ហុក ថា។ កងវរសេនាធំ១៥២ ឈរជើងនៅខាងត្បូងតំបន់ភ្នំពេញ នៅតាមបណ្តោយទន្លេមេគង្គ។ នៅក្នុងខែមីនា ឆ្នាំ១៩៧៧ កងវរសេនាធំមានកងទ័ព ១.៨៥២ នាក់។

**៤៤៥.** កងវរសេនាធំឯករាជ្យ ៣៧៧ គឺជាកងកាំភ្លើងធំ។ សមមិត្ត ណៃ គឺជាលេខាកងវរសេនាធំ។ សមមិត្ត ហ៊ិន គឺជាអនុលេខា។ ផ្អែកលើកំណត់ត្រានៅក្នុងខែមីនា ឆ្នាំ១៩៧៧កងវរសេនាធំនេះគឺជាកងវរសេនាធំតូចមួយដែលមានកងទ័ពចំនួនតែ ៧៩១ នាក់។

**៤៤៦.** មុខងាររដ្ឋបាលរបស់កងវរសេនាធំឯករាជ្យ ៤៨៨ មិនមានភាពច្បាស់លាស់នោះទេទោះបីជាយ៉ាងណាក្តី កងវរសេនាធំនេះត្រូវបានលើកឡើងនៅក្នុងឯកសារជាច្រើន។ សមមិត្ត ភាព គឺជាលេខាកងវរសេនាធំនេះ។ កងវរសេនាធំនេះមានទ័ពចំនួន ១.១៣៨នាក់ នៅក្នុងខែមីនា ឆ្នាំ១៩៧៧។

**៤៤៧.** មន្ទីរ ៦២ គឺជាកងវរសេនាធំឯករាជ្យ។ មន្ទីរនេះគឺជាអង្គភាពភស្តុភាររបស់សេនាធិការ។ ប្រធានមន្ទីរ៦២ គឺ ពេជ ឆន ហៅ សមមិត្ត សោម។ សោម កាន់តំណែងនេះរហូតចុងខែធ្នូ ឆ្នាំ១៩៧៦។ គាត់ត្រូវបានគេចោទសម្អាតបន្ទាប់មកបញ្ជូនទៅមន្ទីរសន្តិសុខ ស-២១។ ភស្តុតាងនៅក្នុងសំណុំរឿងនេះមិនបានបង្ហាញអំពីអ្នកដែលកាន់តំណែងជំនួសបុគ្គលរូបនេះនោះទេ។ នៅក្នុងខែមីនា ឆ្នាំ១៩៧៧ មានមនុស្សចំនួន១.៣៨៥ នាក់ ត្រូវបានគេកត់ត្រាថាមានទំនាក់ទំនងជាមួយមន្ទីរ៦២។



*កងទ័ពបដិវត្តន៍ខ្មែរក្រហមកំពុងប្រយុទ្ធជាមួយកងទ័ពសាធារណរដ្ឋខ្មែរ នៅសមរភូមិពាយ័ព្យ នៅខែមេសា ឆ្នាំ១៩៧៤។ (បណ្ណសារមជ្ឈមណ្ឌលឯកសារកម្ពុជា)*

**៤៤៨.** មន្ទីរ ៦៣ ក៏ជាកងវរសេនាធំឯករាជ្យដែរ។ ហត ហេង ហៅ ឆួន គឺជាប្រធានមន្ទីរ៦៣ យ៉ាងហោចណាស់ រហូតដល់ពេលដែលគាត់ត្រូវបានបញ្ជូនទៅមន្ទីរ ស-២១ នៅថ្ងៃទី០៥ ខែមីនា ឆ្នាំ១៩៧៧។ ភស្តុតាងនៅក្នុងសំណុំរឿងនេះ មិនបានបង្ហាញអំពីអ្នកដែលកាន់តំណែងជំនួសបុគ្គលរូបនេះទេ។ មន្ទីរ៦៣ គឺជាអង្គភាពដ៏ធំមួយ។ នៅក្នុងខែមីនា ឆ្នាំ១៩៧៧ មានកំណត់ត្រាដែលថាមានមនុស្ស៣.២០១ នាក់ជាប់ទាក់ទង និងមន្ទីរ៦៣។

**៤៤៩.** នៅចំពោះមុខអង្គជំនុំជ្រះ មានទូរលេខមួយដែលសមមិត្ត សោម នៅមន្ទីរ៦២ ក្នុងនាម កងពលមជ្ឈិម ៧០៣ ផ្ញើជូនមន្ទីរ៦៣ ដោយស្នើសុំឲ្យបើកប្រេងឲ្យកងពល៧០៣ ។ សក្ខីកម្មរបស់ឌុច ក៏បានបញ្ជាក់ផងដែរថា មន្ទីរ៦២ និងមន្ទីរ៦៣ គឺជាអង្គភាពភស្តុភារ។ លើសពីនេះទៀត មន្ទីរ៦៣ ត្រូវបានចម្លងជូននៅក្នុងឯកសារដែលរៀបរាប់ពីស្ថិតិកងទ័ពបដិវត្តន៍កម្ពុជា។

**៤៥០.** មន្ទីរសន្តិសុខ ស-២១ គឺជាកងវរសេនាធំឯករាជ្យដែលស្ថិតក្រោមការគ្រប់គ្រងផ្ទាល់របស់សេនាធិការចំពោះតែបញ្ហាភស្តុភារប៉ុណ្ណោះ។ អង្គជំនុំជម្រះនឹងពិភាក្សាអំពីរចនាសម្ព័ន្ធអង្គភាពនេះ និងការរាយការណ៍របស់មន្ទីរសន្តិសុខ ស-២១ នៅក្នុងផ្នែកពាក់ព័ន្ធនៅក្នុងសាលក្រមនេះ។

## ៥.៣.១.២.១.១១. ទីបញ្ជាការសមរភូមិក្នុងភូមិភាគបូព៌ា

**៤៥១.** ប.ក.ក. បានបង្កើតទីបញ្ជាការសមរភូមិពីរកន្លែងនៅក្នុងភូមិភាគបូព៌ា នៅក្នុងអំឡុងឆ្នាំ១៩៧៧ ដើម្បីធានាដល់ការចល័តកងទ័ព នៅពេលដែលការបោសសម្អាតផ្ទៃក្នុងមានការកើនឡើងនិងជម្លោះប្រដាប់អាវុធជាមួយនឹងវៀតណាមកាន់តែមានភាពតានតឹង។ ចំពោះទីបញ្ជាការសមរភូមិទី១ អង្គជំនុំជម្រះយល់ឃើញថា ប៉ុល ពតបានចាត់តាំង សុន សេនឲ្យដឹកនាំសមរភូមិមុខនៅតាមផ្លូវជាតិលេខ១ (ស្វាយរៀង) ដែលមានសមិត្ត វ៉ែន ជាអនុប្រធាន។ ចំពោះទីបញ្ជាការសមរភូមិទី២ អង្គជំនុំជម្រះយល់ឃើញថា កែ ពក ដែលមកពីសមរភូមិភាគកណ្តាល (ភូមិភាគឧត្តរចាស់) បានឈរជើងនៅផ្លូវជាតិលេខ៧ (នៅពេលនោះគឺខេត្តកំពង់ចាម) ដើម្បីដឹកនាំសមរភូមិមុខ ក្រោមការបញ្ជាពីទីបញ្ជាការនៅសួងៗ សោ ភឹម ដែលជាលេខាភូមិភាគបូព៌ា គឺជាមេបញ្ជាការនៅទីបញ្ជាការសមរភូមិរហូតដល់ពេលគាត់ធ្វើអត្តឃាត ដោយមាន កែ ពក គឺជាអនុប្រធាន។ កងពលមជ្ឈិម និងកងពលភូមិភាគដែលភាគច្រើនមកពីភូមិភាគនិរតី និងតំបន់ភ្នំពេញនោះ ត្រូវបានដាក់ឲ្យឈរជើងនៅទីបញ្ជាការសមរភូមិទាំងពីរនេះ នៅក្នុងអំឡុងឆ្នាំ១៩៧៧ និងឆ្នាំ១៩៧៨។

## ៥.៣.១.២.២. កងទ័ពតំបន់

**៤៥២.** កងពលនិងកងវរសេនាធំឯករាជ្យទាំងអស់ មិនមែនសុទ្ធតែស្ថិតក្រោមការគ្រប់គ្រងផ្ទាល់របស់សេនាធិការនោះទេ។ កងពលនិងកងវរសេនាធំមួយចំនួនក្រោមការគ្រប់គ្រងរបស់ភូមិភាគឬតំបន់ស្វយ័ត។ ភស្តុតាងនៅចំពោះមុខអង្គជំនុំជម្រះមិនមានភាពច្បាស់លាស់នោះទេ



កងទ័ពបដិវត្តន៍ខ្មែរក្រហមវាយជាមួយកងទ័ពវៀតណាម នៅសរមភូមិផ្លូវជាតិលេខ១ ក្នុងស្រុក ប្រសូត្រ ខេត្តស្វាយរៀង ភូមិភាគបូព៌ា នៅខែមករា ឆ្នាំ១៩៧៨។ (បណ្ណសារមជ្ឈមណ្ឌលឯកសារកម្ពុជា)

ពាក់ព័ន្ធនឹងចំនួនកងទ័ពជាក់ស្តែងនៅក្នុងកងពលនីមួយៗ ដែលស្ថិតនៅក្រោមការគ្រប់គ្រងផ្ទាល់របស់ភូមិភាគ ឬតំបន់នោះៗ ទោះបីជាយ៉ាងណាក្តី អង្គជំនុំជម្រះជឿជាក់ថា តំបន់ស្វយ័ត៥០៥ ភូមិភាគពាយ័ព្យ ភូមិភាគនិរតី ភូមិភាគបស្ចិម និងភូមិភាគបូព៌ា សុទ្ធតែមានកងទ័ពរបស់ភូមិភាគផ្ទាល់ ពោលគឺក្នុងក្របខណ្ឌកងពលភូមិភាគៗ ឧទាហរណ៍ កងពលលេខ១ ដែលឈរជើងនៅក្នុងខេត្តកោះកុងស្ថិតក្រោមបញ្ជារបស់ភូមិភាគបស្ចិម។ ភូមិភាគពាយ័ព្យ យ៉ាងហោចណាស់ ក៏មានកងពលលេខ១ និងលេខ២។ ភូមិភាគនិរតីមានកងពលលេខ២ (ក្រោយមកប្តូរឈ្មោះទៅជាកងពល ២១០ ហើយបានបញ្ជូនទៅភូមិភាគបូព៌ា) ក្រោមការបញ្ជារបស់ សំ ប៊ិត និងកងពលលេខ៣ក្រោមការបញ្ជារបស់ មាស មុត ប៉ុន្តែក្រោយមកកងពលបដិវត្តន៍កម្ពុជាត្រូវបានកែទម្រង់នៅពាក់កណ្តាលឆ្នាំ១៩៧៥ រហូតដល់ចុងឆ្នាំ១៩៧៥ កងពលភូមិភាគនេះបានក្លាយទៅជាផ្នែកមួយនៃកងពលមជ្ឈិម ១៦៤ (កងពលជើងទឹក) ។ កងពល១១៧ ស្ថិតក្រោមការគ្រប់គ្រងរបស់តំបន់ស្វយ័ត៥០៥ ( ខេត្តក្រចេះ) ។ កងពលលេខ៣ កងពលលេខ៤ និង ពលពលលេខ៥ គឺជាកងពលរបស់ភូមិភាគ ដែលបានឈរជើងនៅក្នុងភូមិភាគបូព៌ា។

### ៥.៣.១.២.៣. កងឈ្លប

**៤៥៣.** ក្រៅពីកងទ័ពភូមិភាគ តំបន់ និងស្រុកក៏នៅមានកងឈ្លបតាមមូលដ្ឋានផងដែរដែលស្ថិតក្រោមការគ្រប់គ្រងរបស់គណៈឃុំ ដែលទទួលខុសត្រូវលើផ្នែកសន្តិសុខនិងវិន័យនៅតាមភូមិ ឃុំ និងសហករណ៍នានា។

**៤៥៤.** នៅក្នុងឃុំក៏មានកងសន្តិសុខពិសេសនានាផងដែរ។ ឧទាហរណ៍នៃកងសន្តិសុខពិសេសគឺ«ក្រុមដាវវែង» ។ ក្រុមដាវវែង ត្រូវបានបង្កើតឡើងដោយកម្មាភិបាលភូមិភាគនិរតីនៅក្នុងភូមិភាគកណ្តាល (ភូមិភាគឧត្តរចាស់) នៅក្នុងឆ្នាំ១៩៧៧ ដែលក្រុមនេះត្រូវបានរាយការណ៍ជូនលេខាឃុំពាមជីកង។ ក្រុមដាវវែងបានធ្វើប្រតិបត្តិការនៅក្នុងស្រុកកងមាស ទាក់ទងនឹងការងាររបស់មន្ទីរសន្តិសុខអូរត្រកួន។ អង្គជំនុំជម្រះនិង ពិភាក្សាបន្ថែមអំពីក្រុមនេះក្នុងផ្នែកពាក់ព័ន្ធនៅក្នុងសាលក្រមនេះ ដូចខាងក្រោម។

## ៦ របនាសម្ព័ន្ធទំនាក់ទំនងការងារ

### ៦.៦.១. មធ្យោបាយទំនាក់ទំនង

### ៦.១.១. ទូរលេខ

**៤៥៥.** ជាបញ្ហាបឋម អង្គជំនុំជម្រះកត់សម្គាល់ឃើញថា ខ្លួនមានឯកសារទំនាក់ទំនងការងារជាផ្លូវការក្នុងទម្រង់ជាទូរលេខរវាងសមាជិក ប.ក.ក. រួមមានរបាយការណ៍ផ្ញើជូនថ្នាក់លើនិងការណែនាំមកថ្នាក់ក្រោមៗ ភាគច្រើននៃឯកសារទាំងនេះត្រូវបានរកឃើញដោយអ្នកជំនាញវៀតណាមមួយក្រុម នៅក្នុងភូមិគ្រឹះមួយកន្លែងដែលមានទីតាំងស្ថិតនៅលើផ្លូវលេខ២៨០ នៅក្នុងទីក្រុងភ្នំពេញ ចន្លោះពីឆ្នាំ១៩៧៩ ដល់ឆ្នាំ១៩៨៣។ ឯកសារទំនាក់ទំនងការងារនេះត្រូវបានបញ្ជូនទៅមន្ទីរឯកសាររបស់ក្រសួងមហាផ្ទៃនៃសាធារណរដ្ឋប្រជាមានិតកម្ពុជា ដែលក្រោយមកក្លាយជាក្រសួងមហាផ្ទៃកម្ពុជា មុនពេលបញ្ជូនទៅមជ្ឈមណ្ឌលឯកសារកម្ពុជា (DC-Cam) ។ មជ្ឈមណ្ឌលឯកសារកម្ពុជារក្សាទុកសំណៅដើមនៃឯកសារទាំងនេះ។ អង្គជំនុំជម្រះសន្និដ្ឋានថា ឯកសារទាំងនេះមានតម្លៃជាភស្តុតាងយ៉ាងសំខាន់។

**៤៥៦.** នៅមុនឆ្នាំ១៩៧៥ ប.ក.ក. បានប្រើប្រាស់ទូរលេខសម្រាប់ធ្វើការទំនាក់ទំនងគ្នាទាំងនៅក្នុងប្រទេសកម្ពុជា និងក្រៅប្រទេសកម្ពុជា ដើម្បីទំនាក់ទំនងជាមួយក្រុមបណ្តាញការងារនៅក្រៅប្រទេស។ ឧទាហរណ៍ ទូរលេខត្រូវបានប្រើប្រាស់សម្រាប់បញ្ជូន និងទទួលសាររវាងភូមិភាគ និងមេដឹកនាំបក្សនៅតាមទីបញ្ជាការរបស់ពួកគេ ហើយក៏ត្រូវបានប្រើប្រាស់សម្រាប់ទំនាក់ទំនងជាមួយនឹងតំណាងនៃរណសិរ្សរួបរួមជាតិកម្ពុជា និងរាជរដ្ឋាភិបាលបង្រួបបង្រួមជាតិកម្ពុជានៅប្រទេសវៀតណាម និងប្រទេសចិនផងដែរ។

**៤៥៧.** ក្រោយពីបានកាន់កាប់ទីក្រុងភ្នំពេញ នៅថ្ងៃទី១៧ ខែមេសា ឆ្នាំ១៩៧៥ មន្ទីរទូរលេខនៃ ប.ក.ក. ត្រូវបានបង្កើតឡើងនៅក្នុងទីក្រុង។ ទូរលេខត្រូវបានបញ្ជូន និងទទួលនៅមន្ទីរ ក-១៨ ហើយត្រូវបានសរសេរជាលេខកូដ ឬបកប្រែលេខកូដទៅតាមការចាំបាច់ នៅមន្ទីរ ក-១ឬ នៅមន្ទីរមួយដែលមានទីតាំងស្ថិតនៅក្នុងសាលាសុធារស។

ភូមិភាគតំបន់ស្វយ័តតំបន់ និងកងពល នៅទូទាំងប្រទេស ក៏មានអង្គភាពទូរលេខរបស់ខ្លួនផ្ទាល់ផងដែរ។ ប្រព័ន្ធទំនាក់ទំនងនេះនៅដំណើរការរហូតដល់ពេលវៀតណាមចូលមកដល់ទីក្រុងភ្នំពេញ នៅក្នុងឆ្នាំ១៩៧៩។ ទូរលេខត្រូវបានប្រើប្រាស់ជាចម្បងសម្រាប់ទំនាក់ទំនងជាមួយតំបន់ឆ្ងាយៗ។ ជាធម្មតា មន្ទីរនានារបស់មជ្ឈិមពុំបានប្រើទូរលេខសម្រាប់ទំនាក់ទំនងគ្នានៅក្នុងទីក្រុងភ្នំពេញឡើយ ផ្ទុយទៅវិញគេប្រើប្រាស់ទូរសព្ទ ឬសំបុត្រ (បញ្ជូនដោយនីរសារ) ។

៤៥៨. ទូរលេខរបស់ ប.ក.ក. ភាគច្រើនគឺត្រូវបានសរសេរជាលេខកូដនៅមុនពេលបញ្ជូនចេញតែមិនមែនទាំងអស់នោះទេ។ ទូរលេខដែលពុំត្រូវបានសរសេរជាលេខកូដ ត្រូវបានបញ្ជូនចេញជាលេខសម្ងាត់ (Morse Code) ។ ទូរលេខសម្ងាត់ត្រូវបានសរសេរជាលេខកូដដោយយកសញ្ញាមកប្រើជំនួសអក្សរ។ ការសរសេរជាលេខកូដមួយជាន់ទៀតត្រូវបានធ្វើឡើងសម្រាប់ទូរលេខសម្ងាត់បំផុត ដូចជាសារដែលទាក់ទងផែនការនៃការធ្វើដំណើររបស់កម្មាភិបាល។ លេខកូដពិសេស ក៏ត្រូវបានប្រើដើម្បីសំដៅលើបុគ្គលទីតាំង និងមន្ទីរជាក់លាក់មួយចំនួនផងដែរ។

៤៥៩. ជាទូទៅ ទូរលេខត្រូវបានសរសេរជាលេខកូដឬបកប្រែលេខកូដ និងបញ្ជូនឬទទួលដោយបុគ្គលិកផ្សេងគ្នា។ ដូច្នេះ តាមធម្មតា ទូរលេខដែលត្រូវផ្ញើចេញ គឺត្រូវបានគេរៀបចំជាលាយលក្ខណ៍អក្សរ និងប្រគល់ទៅឲ្យ «អ្នកបំភាន់អក្ខរៈ»។ បន្ទាប់មក សារដែលត្រូវបានសរសេរជាលេខកូដ គឺត្រូវប្រគល់ទៅឲ្យអ្នកកាន់ម៉ាស៊ីនទូរលេខម្នាក់ផ្សេងទៀត ដើម្បីបញ្ជូនចេញ។ ខាងអ្នកទទួលសារវិញ ក្រោយពីបានទទួលសារដែលបានសរសេរជាលេខកូដនោះ គឺត្រូវចម្លងសារនោះឡើងវិញដោយអ្នកកាន់ម៉ាស៊ីនទូរលេខម្នាក់ទៀត មុននឹងយកទៅឲ្យ «អ្នកបកប្រែលេខកូដ» ដើម្បីធ្វើការបកប្រែលេខកូដ។ បន្ទាប់មក សារដែលបានបកប្រែលេខកូដរួចហើយនោះ គឺត្រូវបញ្ជូនទៅឲ្យអ្នកទទួលសារចុងក្រោយតាមរយៈនីរសារ។ សាក្សី នន សូផង់ ដែលជាអ្នកគ្រប់គ្រងអង្គភាពសរសេរសារជាលេខកូដ និងបកប្រែលេខកូដទូរលេខនៅសាលាសុធារស នៅក្នុងទីក្រុងភ្នំពេញពីឆ្នាំ១៩៧៥មកនោះ បានបញ្ជាក់ថាការទទួលខុសត្រូវ ទាំងនេះមានបំណងដើម្បី «រក្សាគោលការណ៍សម្ងាត់» នៅក្នុង ប.ក.ក.។

## ៦.១.២. សំបុត្រ

៤៦០. អង្គភាពនានារបស់មជ្ឈិមបក្ស ភូមិភាគ តំបន់ ស្រុក និង ឃុំ ក៏ធ្វើការទំនាក់ទំនងគ្នាតាមរយៈសំបុត្រផងដែរ។ ទោះបីជាទូរលេខត្រូវបានគេនិយមប្រើជាទូទៅសម្រាប់ទំនាក់ទំនងការងារទៅតំបន់ឆ្ងាយៗក៏ដោយ ក៏ទូរលេខ និងរបាយការណ៍ដែលមានច្រើនទំព័រទាំងនេះត្រូវបានផ្ញើតាមរយៈសំបុត្រ ដែលមាននីរសារ ចែកចាយផងដែរ។ នៅក្នុងទីក្រុងភ្នំពេញ មជ្ឈិមបក្សទទួលសំបុត្រតាមរយៈមន្ទីរ ក-៧ ដែលជាអង្គភាពនីរសារ។ ភូមិភាគ តំបន់ និងស្រុក មានបណ្ដាញនីរសាររបស់ពួកគេផ្ទាល់ផងដែរ។

## ៦.១.៣. ទូរសព្ទនិងវិទ្យុ (រលកសំឡេងខ្លី)

៤៦១. ភស្តុតាងនៅចំពោះអង្គជំនុំជម្រះបង្ហាញថា មេដឹកនាំនៅតាមមន្ទីរ និងអង្គភាពមួយចំនួនរបស់មជ្ឈិមបក្ស និងរដ្ឋាភិបាលកម្ពុជាប្រជាធិបតេយ្យ បានទំនាក់ទំនងគ្នាតាមរយៈទូរសព្ទ។ ប៉ុន្តែមិនមានន័យថា គ្រប់មន្ទីរទាំងអស់នៅក្នុងទីក្រុងភ្នំពេញសុទ្ធតែទំនាក់ទំនងគ្នាតាមរយៈទូរសព្ទនោះទេ។

៤៦២. ភស្តុតាងនៅចំពោះមុខអង្គជំនុំជម្រះ មិនបានបង្ហាញឲ្យបានច្បាស់លាស់នោះទេថាតើកម្មាភិបាលថ្នាក់ភូមិភាគ ឬតំបន់អាចធ្វើការទំនាក់ទំនងគ្នាតាមរយៈទូរសព្ទបានដែរឬទេ ។ អង្គភាពយោធាមួយចំនួន រួមទាំងកងពល១៦៤ (កងទ័ពជើងទឹក) ផងដែរនោះ ពេលខ្លះបានរាយការណ៍ជូនមជ្ឈិមបក្សតាមរយៈទូរសព្ទ។ ប៉ុន្តែនៅក្នុងកិច្ចប្រជុំជាមួយនឹងកម្មាភិបាលជាន់ខ្ពស់ក្នុងខែធ្នូ ឆ្នាំ១៩៧៦ សុន សេន បានណែនាំដល់កម្មាភិបាលយោធាមិនឲ្យប្រើទូរសព្ទ«ដោយសេរី» នោះទេដើម្បីជៀសវាង «ខ្មាំង» ស៊ើបការណ៍ពីទំនាក់ទំនងរបស់ពួកគេ។

៤៦៣. សាក្សី ព្រំ សារ៉ាត បានផ្តល់សក្ខីកម្មថា ពេលនៅលើនាវា ក្រៅពីទូរសព្ទមួយខ្សែ គេបានប្រើវិទ្យុទាក់ទងរលកសំឡេងខ្លីសម្រាប់ទំនាក់ទំនងការងារនៅក្នុងកងវរសេនាធំ ១៤០ នៃកងពល១៦៤ (កងទ័ពជើងទឹក)។ អង្គជំនុំជម្រះ

កឹមានភ័ស្តុតាងស្តីពីទំនាក់ទំនងតាមរយៈវិទ្យុទាក់ទងរលកសំឡេងខ្លី នៅទីតាំងផ្សេងទៀតទូទាំងកម្ពុជាប្រជាធិបតេយ្យផងដែរ បើទោះបីជាវិទ្យុទាក់ទងមាននៅគ្រប់ទីកន្លែងក៏ដោយ។

## ៦.១.៤. វិទ្យុផ្សាយសំឡេង

**៤៦៤.** *នៅមុនឆ្នាំ១៩៧៥ ស្ថានីយ៍វិទ្យុផ្សាយសំឡេងពុរបស់រណសិរ្សរួបរួមជាតិកម្ពុជា គឺស្ថិតនៅទីក្រុងហាណូយ ហើយបុគ្គលិកភាគច្រើនជាសមាជិក ប.ក.ក រួមទាំង អៀង ធីរិទ្ធ ផងដែរ។ ស្ថានីយ៍វិទ្យុនេះបានចាក់ផ្សាយអំពីការឃោសនាបដិវត្តន៍ជាភាសាខ្មែរ ជូនដល់ប្រជាជនកម្ពុជានៅក្នុងនិងក្រៅប្រទេសកម្ពុជា។ នៅក្នុងប្រទេសកម្ពុជា ប.ក.ក. ក៏មានអង្គភាពវិទ្យុផ្សាយសំឡេងចល័តមួយផងដែរ ដែលមានរលកសំឡេងរយៈចម្ងាយជិត ហើយផ្សព្វផ្សាយអំពីព័ត៌មានដែលស្រដៀងគ្នានឹងសារឃោសនា និងសារបដិវត្តន៍ផងដែរ។*

**៤៦៥.** *ក្រោយចូលកាន់កាប់ទីក្រុងភ្នំពេញ នៅក្នុងឆ្នាំ១៩៧៥ ប.ក.ក. បានបង្កើតស្ថាយនីយ៍វិទ្យុផ្សាយសំឡេងមួយដែលមានទីតាំងនៅស្ទឹងមានជ័យ។ ស្ថានីយ៍វិទ្យុផ្សាយសំឡេងនេះចាក់ផ្សាយនូវព័ត៌មាន ការឃោសនាបទចម្រៀង ខ្សែអាត់សំឡេងដែលមានសុន្ទរកថារបស់មេដឹកនាំជាន់ខ្ពស់នៃ ប.ក.ក. (រួមទាំង ជនជាប់ចោទ នួន ជា និង ខៀវ សំផន) និងខ្សែអាត់សំឡេងដែលជាបទសម្ភាសន៍របស់មេដឹកនាំ ប.ក.ក. (រួមទាំងជនជាប់ចោទ ខៀវ សំផន) ផងដែរ។*

**៤៦៦.** *ក្រសួងឃោសនាការនិងព័ត៌មាន ទទួលសខុសត្រូវលើការរៀបចំសម្ភារសម្រាប់ចាក់ផ្សាយក្រោមការណែនាំនិងការ ត្រួតពិនិត្យយ៉ាងហ្មត់ចត់របស់គណៈកម្មាធិការអចិន្ត្រៃយ៍។ កម្មវិធីវិទ្យុសំឡេងបានរាយការណ៍អំពីបញ្ហាមួយចំនួន ដូចជា អំពីបញ្ហាកសិកម្ម គម្រោងសាងសង់ ការចាប់ខ្លួន និងអ្នកដែលត្រូវបានគេចាត់ទុកថាជាខ្មាំង ហើយបានបញ្ចុះបញ្ចូលអ្នកស្តាប់ឲ្យប្រឹងប្រែងធ្វើការងារ ការពារប្រទេស និងដើរតាមមាគ៌ាបក្ស។ កម្មវិធីមួយត្រូវបានចាក់ផ្សាយដោយមានគោលដៅផ្តោតទៅអ្នកស្តាប់ភាសាខ្មែរ នៅកម្ពុជាក្រោម។ កម្មវិធីមួយទៀតដែលធ្វើការចាក់ផ្សាយយ៉ាងហោចណាស់ផ្នែកខ្លះជាភាសាវៀតណាមនោះ បានចាក់ផ្សាយខ្សែអាត់សំឡេងសារភាពរបស់ទាហានវៀតណាមដែលត្រូវបានចាប់ខ្លួននៅក្នុងប្រទេសកម្ពុជា។ នៅក្នុងខែមីនា ឆ្នាំ១៩៧៦ គណៈកម្មាធិការអចិន្ត្រៃយ៍បានបញ្ជាឲ្យវិទ្យុចាក់ផ្សាយឲ្យបានញឹកញាប់លើប្រធានបទ «ការបោះឆ្នោត» ដែលខិតចូលជិតមកដល់នាពេលខាងមុខ ដោយបានលើកឡើងថា «បើមិនផ្សាយសោះ ខ្មាំងថាយើងផ្តាច់ការ គ្មានលទ្ធិប្រជាធិបតេយ្យ»។*

**៤៦៧.** *ក្រសួងការបរទេស ក៏បានរៀបចំការឃោសនាសម្រាប់អ្នកស្តាប់ជាជនបរទេសផងដែរ។ កម្មកវិធីវិទ្យុមួយចំនួនដែលនិយាយអំពីស្ថានភាពរបស់របបកម្ពុជាប្រជាធិបតេយ្យ ត្រូវបានចាក់ផ្សាយជាភាសាវៀតណាម អង់គ្លេស បារាំង និងចិនផងដែរ។*

**៤៦៨.** *នៅតាមការដ្ឋានការងារមួយចំនួនក្នុងប្រទេសកម្ពុជា ខ្សែអាត់ទុស្សនតែមិនក្រោមពេលមាន? ខ្សែអាត់*




*ទស្សនាវដ្តីទង់បដិវត្ត លេខពិសេស ខែកញ្ញា ឆ្នាំ១៩៧៧។ (សារមន្ទីរឧក្រិដ្ឋកម្មប្រល័យពូជសាសន៍ទួលស្លែង/ បណ្ណសារមជ្ឈមណ្ឌលឯកសារកម្ពុជា)*

*វិទ្យុរបស់ ប.ក.ក.។ សាក្សី ឡុង ឈឿង បានផ្ដល់សក្ខីកម្មថា មេក្រុមក៏ត្រូវបានគេតម្លើងនៅពីមុខក្រសួងនីមួយៗនៅក្នុងទីក្រុងភ្នំពេញផងដែរ។ សាក្សី ជា សាយ បានរម្លឹកឡើងវិញថា លោកនិងអ្នករួមការងាររបស់គាត់បានស្ដាប់វិទ្យុមួយរួមគ្នានៅមន្ទីរ ក-១៧ ប៉ុន្តែមិនមានវិទ្យុស្ដាប់ផ្ទាល់ខ្លួននោះទេ។ ជាទូទៅ ប្រជាជនសាមញ្ញនៅក្នុងប្រទេសកម្ពុជា ពុំមានសេរីភាពទទួលបានព័ត៌មានតាមរយៈវិទ្យុនៅក្នុងរបបកម្ពុជាប្រជាធិបតេយ្យឡើយ។*

**៤៦៩.** *កម្មវិធីផ្សាយសំឡេងតាមវិទ្យុជាសាធារណៈចេញពីប្រទេសកម្ពុជា និងប្រទេសផ្សេងទៀតនៅក្នុងតំបន់ត្រូវបានពិនិត្យតាមដាន ថតសំឡេងទុក និងបកប្រែដោយបុគ្គលិករដ្ឋាភិបាលសហរដ្ឋអាមេរិកនៅក្នុងប្រទេសថៃ។ សេចក្ដីរាយការណ៍អំពីកម្មវិធីផ្សាយត្រូវបានបញ្ជូនមកស្ថានទូតនានារបស់សហរដ្ឋអាមេរិកនៅជុំវិញពិភពលោកតាមរយៈទូរលេខដែលជាផ្នែកមួយនៃ «កម្រងសារព័ត៌មាន «FBIS» ។ កម្រងសារព័ត៌មាន «FBIS» ចំនួន ៤៩ ច្បាប់ត្រូវបានដាក់នៅចំពោះមុខអង្គជំនុំជម្រះ នៅក្នុងអំឡុងការជំនុំជម្រះ។*

**៤៧០.** *ទោះបីជា អង្គជំនុំជម្រះយល់ឃើញថា សេចក្ដីរាយការណ៍របស់កម្រងឯកសារព័ត៌មាន «FBIS» គឺជាប្រតិចារឹកបកប្រែជាភាសាអង់គ្លេសចេញពីការផ្សាយជាភាសាខ្មែរដែលសំណៅដើមនៃខ្សែអាត់សំឡេងនៃការផ្សាយទាំងនេះមិនអាចរកបានយ៉ាងណាក៏ដោយ ប៉ុន្តែអង្គជំនុំជម្រះកត់សម្គាល់ឃើញថា សុន្ទរកថាជាច្រើនដែលមាននៅក្នុងសេចក្ដីរាយការណ៍របស់កម្រងសារព័ត៌មាន «FBIS» អាចយកមកប្រៀបធៀបទៅនឹងសុន្ទរកថានៅក្នុងអត្ថបទបោះពុម្ពផ្សាយរបស់កម្ពុជាប្រជាធិបតេយ្យ។ ជាងនេះទៀត សាក្សី Stephen HEDER ដែលបានយល់ដឹងអំពីប្រតិចារឹករបស់កម្រងសារព័ត៌មាន «FTST» និងដំណើរការនៃការធ្វើប្រតិចារឹកទាំងនេះបានផ្ដល់សក្ខីកម្មថាខ្លឹមសារនៅក្នុងសេចក្ដីរាយការណ៍ទាំងនេះ ត្រូវបានដកស្រង់ចេញពីការផ្សាយតាមវិទ្យុដោយផ្ទាល់នៅក្នុងសម័យកាលនោះ។ អង្គជំនុំជម្រះពិចារណាឃើញថា កម្រងសេចក្ដីរាយការណ៍របស់កម្រងព័ត៌មាន «FBIS» គឺជាភស្តុតាងដ៏សំខាន់នៃសេចក្ដីថ្លែងការណ៍ និងការឃោសនារបស់ ប.ក.ក. ដែលត្រូវបានផ្សព្វផ្សាយដល់ប្រជាជននៅក្នុងប្រទេសកម្ពុជា ព្រមទាំងសហគមន៍អន្តរជាតិ។ ប៉ុន្តែដោយសារតែភស្តុតាងនេះមានលក្ខណៈប្រយោល អង្គជំនុំជម្រះនឹងសំអាងលើឯកសារទាំងនេះតែក្នុងករណីដែលឯកសារទាំងនេះត្រូវបានបញ្ជាក់បន្ថែមដោយភស្តុតាងផ្សេងទៀតប៉ុណ្ណោះ។*

**៤៧១.** *សេចក្ដីសង្ខេប និងប្រតិចារឹកនៃការផ្សាយសំឡេងតាមវិទ្យុរបស់របបកម្ពុជាប្រជាធិបតេយ្យត្រូវបានចងក្រង បកប្រែជាភាសាអង់គ្លេស និងបោះពុម្ពផ្សាយដោយសាជីវកម្មផ្សាយសំឡេងរបស់ចក្រភពអង់គ្លេសផងដែរ* («BBC») *ដែលនេះជាផ្នែកមួយនៃការ «សង្ខេបសេវាកម្មផ្សាយសំឡេងទូទាំងពិភពលោក* («SWB») *។ កម្រងសេចក្ដីរាយការណ៍សង្ខេបសេវាកម្មផ្សាយសំឡេងនៅទូទាំងពិភពលោកចំនួន៤៥ ច្បាប់ត្រូវបានដាក់នៅចំពោះមុខអង្គជំនុំជម្រះនៅក្នុងអំឡុងការជំនុំជម្រះ។ ទោះបីជាកម្រងសេចក្ដីរាយការណ៍ទាំងនេះមានចំណុចខ្វះខាតស្រដៀងគ្នា ដោយសារអង្គជំនុំជម្រះមិនអាចពិនិត្យទៅលើសំណៅដើមនៃខ្សែអាត់សំឡេងក៏ដោយ ប៉ុន្តែកម្រងសេចក្ដីរាយការណ៍ទាំងនេះ មានសារសំខាន់ស្រដៀងគ្នានឹងកម្រងសារព័ត៌មាន «FBIS» ដូចបានកត់សម្គាល់ខាងលើផងដែរ។ ឯកសារទាំងនេះមានតម្លៃជាភស្តុតាងយ៉ាងសំខាន់ហើយអង្គជំនុំជម្រះនឹងសំអាងលើឯកសារទាំងនេះ ក្រោមលក្ខខណ្ឌដូចគ្នា។*

**៤៧២.** *អង្គជំនុំជម្រះយល់ឃើញថា ការផ្សាយតាមវិទ្យុរួមទាំងការផ្សាយនានានៅក្នុងកម្រងសេចក្ដីរាយការណ៍របស់នៃកម្រងសារព័ត៌មាន «FBIS» និងសង្ខេបសេវាកម្មផ្សាយសំឡេងនៅទូទាំងពិភពលោក គឺជាសម្ភារខាងក្រៅរបស់ ប.ក.ក. ដើម្បីធ្វើការផ្សព្វផ្សាយជាលក្ខណៈសាធារណៈដែលនេះផ្ទុយពីឯកសារផ្ទៃក្នុងរបស់ ប.ក.ក. រួមមានកំណត់ហេតុប្រជុំ សៀវភៅកំណត់ត្រាគោលនយោបាយ និងទូរលេខនានា ហើយឯកសារប្រភេទនេះអាចមានខ្លឹមសារឃោសនា។ ហេតុដូច្នេះអង្គជំនុំជម្រះនិងពិចារណាលើចំណុចនេះផងដែរ នៅពេលវាយតម្លៃភស្តុតាង។*

## ៦.១.៥. ទស្សនាវដ្តី

**៤៧៣.** ចាប់ផ្តើមតាំងពីអំឡុងមុនឆ្នាំ១៩៧៥ មកប.ក.ក. បានបោះពុម្ពផ្សាយទស្សនាវដ្តីមួយចំនួនរបស់បក្ស ដែលមានចំណងជើងថាទង់បដិវត្តន៍ និងយុវជននិង យុវនារីបដិវត្តន៍ហើយដែលការបោះពុម្ពនេះធ្វើឡើងប្រហែលជាមួយខែម្តងៗ នៅមុនឆ្នាំ១៩៧៥ ទស្សនាវដ្តីទង់បដិវត្តន៍ត្រូវបានរៀបចំនិងចែកចាយជាសម្ងាត់ៗ ឯកសារនេះត្រូវបានសរសេរដោយដៃ ហើយមានសំណៅមួយចំនួនតែប៉ុណ្ណោះដែលត្រូវបានចម្លងឡើងវិញដើម្បីផ្សព្វផ្សាយ។

**៤៧៤.** ចាប់ពីឆ្នាំ១៨៧៥ មកទស្សនាវដ្តីទង់បដិវត្តន៍ត្រូវបានវាយដោយអង្គុលីលេខ និងបានថតចម្លងម៉ាស៊ីនអុហ្វសិត (offset printing) ។ ទាំងទស្សនាវដ្តីទង់បដិត្តន៍ និងទស្សនាវដ្តីយុវជនយុវនារីបដិវត្តន៍ ត្រូវបានបោះពុម្ពផ្សាយនៅមន្ទីរ ក-២៥ និងមន្ទីរក-២៦ ដែលស្ថិតនៅក្រោមការគ្រប់គ្រងរបស់ក្រសួងឃោសនានិងព័ត៌មានដែលដឹកនាំដោយ ហ៊ូ នឹម។ សាក្សី គឹម វ៉ុន ដែលធ្លាប់ធ្វើការនៅក្រសួងឃោសនាការ និងព័ត៌មានពុំអាចធ្វើការប៉ាន់ប្រមាណឲ្យបានច្បាស់អំពីចំនួនទស្សនាវដ្តីដែលត្រូវបានបោះពុម្ពផ្សាយនោះទេ។ ប៉ុន្តែ គាត់នៅចាំថាគាត់បានឃើញលេខផ្សាយនីមួយៗគឺ «គរជាគីប» ដែលគេរៀបចំ ដើម្បីចែកចាយ។

**៤៧៥.** ទោះបីជាទស្សនាវដ្តីទង់បដិវត្តន៍ និងទស្សនាវដ្តីយុវជននិងយុវនារីបដិវត្តន៍ ត្រូវបានចែកចាយឲ្យតែសមាជិក ប.ក.ក.ក៏ដោយតែមិនមែនមានន័យថាសមាជិកទាំងអស់សុទ្ធតែទទួលបាននូវទស្សនាវដ្តីនេះនោះទេ។ ទស្សនាវដ្តីទាំងនេះត្រូវបានរំពឹងថានឹងយកទៅអានរួមគ្នា ក្នុងចំណោមបណ្តាសមាជិកបក្សផ្សេងៗទៀត។ ទស្សនាវដ្តីមួយចំនួនត្រូវបានចែកចាយតាមក្រសួងនានានៃកម្ពុជាប្រជាធិបតេយ្យ អង្គភាពយោធា និងមន្ទីររបស់មជ្ឈិមបក្ស និងកម្មាភិបាលនៅថ្នាក់ភូមិភាគ តំបន់ស្រុក និងឃុំផងដែរ។

**៤៧៦.** ដំបូងឡើយ នួន ជា បានបដិសេធថាគាត់គ្មានតួនាទីក្នុងការ «រៀបចំ» ទស្សនាវដ្តីទង់បដិវត្តន៍នោះទេ។ ប៉ុន្តែក្រោយមក គាត់បានទទួលស្គាល់ថាទស្សនាវដ្តីទង់បដិវត្តន៍ ត្រូវបានសរសេរឡើងដោយសមាជិកគណៈកម្មាធិការអចិន្ត្រៃយ៍ ភាគច្រើនត្រូវបានសរសេរដោយខ្លួនគាត់ផ្ទាល់ និង ប៉ុល ពត។ ការទទួលស្គាល់នេះមានភាពស្របគ្នាទៅនឹងការទទួលស្គាល់របស់ នួន ជា ដែលថាគាត់ជា «សមាជិកត្រៀមម្នាក់ដែលទទួលការងារឃោសនាការ និង សរសេរអត្ថបទសម្រាប់ការសែត» ឲ្យបក្សកុម្មុយនីស្តឥណ្ឌូចិន និងបក្សប្រជាជនបដិវត្តន៍ខ្មែរដែលជាបុព្វាធិការីនៃ ប.ក.ក.នៅក្នុងទសវត្សរ៍ឆ្នាំ១៩៥០។ ក្រោយមក នួន ជា បានកែប្រែចម្លើយរបស់គាត់ម្តងទៀតដោយបានបដិសេធថាគាត់មិនមែនជាអ្នកនិពន្ធអត្ថបទ ដែលត្រូវបានបោះពុម្ពផ្សាយនៅក្នុងទស្សនាវដ្តីទង់បដិវត្តន៍នោះទេ ហើយបានអះអាងថា ប៉ុល ពត មាន «ក្រុមជំនួយការផ្ទាល់របស់គាត់ដែលជាអ្នកទទួលខុសត្រូវក្នុងការសរសេរអត្ថបទ» ។ បន្ទាប់មក នួន ជា បានបដិសេធមិនឆ្លើយតបទៅនឹងសំណួរ។ ដោយផ្អែកតាមការទទួលស្គាល់នាពេលមុនរបស់គាត់ ជាមួយនឹងការអនុវត្តសិទ្ធិនៅស្ងៀមមិនឆ្លើយតបរបស់គាត់នៅពេលខ្លះនោះ អង្គជំនុំជម្រះយល់ឃើញថាការបដិសេធរបស់ នួន ជា មិនអាចធ្វើឲ្យអង្គជំនុំជម្រះជឿជាក់បានទេ ហើយអង្គជំនុំជម្រះជឿជាក់ថា នួន ជា គឺជាអ្នកនិពន្ធដ៏សំខាន់ម្នាក់របស់ទស្សនាវដ្តី«ទង់បដិវត្តន៍»។

**៤៧៧.** ប.ក.ក. យល់ឃើញថាមានសារសំខាន់ណាស់ដែលសមាជិករបស់ខ្លួនត្រូវអានទស្សនាវដ្តីទង់បដិវត្តន៍ៗជាញឹកញាប់ ទស្សនាវដ្តីទង់បដិវត្តន៍ ត្រូវបានប្រើប្រាស់សម្រាប់គោលបំណងអប់រំនៅក្នុងវគ្គអប់រំឬវគ្គរៀនសូត្រនយោបាយរបស់ ប.ក.ក.។ ទស្សនាវដ្តីយុវជននិងយុវនារីបដិវត្តន៍ មានគោលដៅជាក់លាក់អប់រំដល់សមាជិកយុវកករបស់ ប.ក.ក.។ ទស្សនាវដ្តីទាំងនេះមានបញ្ចូលនូវឯកសារមួយចំនួន ដូចជាសុន្ទរកថា និងបទខ្ទេសនាមដែលបានធ្វើឡើងដោយអះអាងថាសម្រេចបាននិងមាគ៌ាបក្សជារួម ផែនការលម្អិតសម្រាប់អនាគត សេចក្តីណែនាំបក្សដល់សមាជិករបស់ខ្លួន និងយ៉ាងហោចណាស់ នៅក្នុងទស្សនាវដ្តីយុវជននិងយុវនារីបដិវត្តន៍ មានកំណាព្យបដិវត្តន៍ ដោយកំណាព្យខ្លះបង្ហាញពីការប៉ុនប៉ងយ៉ាងច្បាស់លាស់របស់ ប.ក.ក. ដើម្បីបញ្ចុះបញ្ចូលនិងបំពាក់បំប៉នដល់យុវជន និងយុវនារី។

**៤៧៨.** *ទស្សនាវដ្ដីទង់បដិវត្តន៍ ចំនួន២៤លេខ ខុសៗគ្នានិងទស្សនាវដ្ដីយុវជននិងយុវនារីបដិវត្តន៍ចំនួន២៨ លេខ ត្រូវបានដាក់នៅចំពោះមុខអង្គជំនុំជម្រះសាលាដំបូងៗ នៅក្នុងអំឡុងពេលសវនាការនៅក្នុងសំណុំរឿង០០២/០១ មេធាវីការពារក្ដី នួន ជា បានជំទាស់ទៅលើអំពីយថាភាពនៃសំណៅថតចម្លងរបស់ទស្សនាវដ្ដីទាំងនោះដែលមាននៅក្នុងសំណុំរឿងៗ ក្រោយមកសាក្សី Stephen HEDER បានផ្ដល់សក្ខីកម្ម អំពីប្រភពនិងយថាភាព នៃសំណៅថតចម្លងរបស់ទស្សនាវដ្ដីនីមួយៗ ហើយដូចគ្នានេះដែរ សាក្សី គីម វុន ក៏បានបញ្ជាក់ស្រដៀងគ្នាថាសំណៅថតចម្លងនៃទស្សនាវដ្ដីទង់បដិវត្តន៍ មួយច្បាប់នៅក្នុងសំណុំរឿងគឺជាសំណៅថតចម្លងចេញពីច្បាប់ដើមៗ អង្គជំនុំជម្រះក៏បានស្ដាប់សក្ខីកម្មរបស់សាក្សី វ៉ាន់ថាន់ ពៅដារ៉ា និង ឆាំង យុ មកពីមជ្ឈមណ្ឌលឯកសារកម្ពុជាផងដែរៗ សក្ខីកម្មរបស់សាក្សីទាំងពីរនាក់ បានបញ្ជាក់អំពីរបៀបនៃការទទួលការរក្សាទុកការបម្លែងជាប្រព័ន្ធឌីជីថល និងការបញ្ជាក់អំពីយថភាព មុនពេលដែលឯកសារទាំងនោះត្រូវបានដាក់បញ្ចូលក្នុងសំណុំរឿងៗ អង្គជំនុំជម្រះកត់សម្គាល់ឃើញថា ក្រៅពីការជំទាស់ទៅលើភាពអាចជឿជាក់បាននៃឯកសារនៅក្នុងសំណុំរឿង០០២/០១ មេធាវីការពារក្ដី នួន ជា បានពឹងផ្អែកយ៉ាងច្រើនទៅលើសំណៅថតចម្លងនៃទស្សនាវដ្ដីទង់បដិវត្តន៍ និងយុវជននិងយុវនារីបដិវត្តន៍ ដែលមាននៅក្នុងសំណុំរឿង០០២/០១ និង០០២/០២ៗ នៅក្នុងសំណុំរឿង០០២/០២ ពុំមានភាគីណាមួយលើកឡើងនូវការជំទាស់ថ្មី ពាក់ព័ន្ធនឹងយថាភាពនៃឯកសារចម្លងនៃទស្សនាវដ្ដីទង់បដិវត្តន៍ និងយុវជននិងយុវនារីបដិវត្តន៍នោះទេៗ អង្គជំនុំជម្រះជឿជាក់ថាទស្សនាវដ្ដីទង់បដិវត្តន៍ ទាំង២៤លេខ និងទស្សនាវដ្ដីយុវជននិងយុវនារីបដិវត្តន៍ទាំង២៨ លេខដែលមាននៅក្នុងសំណុំរឿងគឺជាសំណៅដែលបានថតចម្លងត្រឹមត្រូវពីច្បាប់ដើមនៃទស្សនាវដ្ដីរបស់ ប.ក.ក. ពិតប្រាដកមែនៗ*

**៤៧៩.** *អង្គជំនុំជម្រះយល់ឃើញថា ទោះបីជាទស្សនាវដ្ដីអប់រំទាំងនេះជាភ័ស្ដុតាងនាសម័យកាលនោះ មានគោលដៅអប់រំដល់សមាជិក ប.ក.ក. ក៏ដោយប៉ុន្ដែវាត្រូវបានគេយកទៅផ្សព្វផ្សាយយ៉ាងទូលំទូលាយជាឯកសារគោលនយោបាយ និងទូរលេខៗ ឯកសារទាំងនេះប្រហែលជាអាចមានខ្លឹមសារឃោសនាៗ អង្គជំនុំជម្រះនឹងពិចារណាលើចំណុចទាំងនោះ នៅពេលវាយតម្លៃលើភ័ស្ដុតាងបែបនេះៗ*



*កម្មាភិបាលខ្មែរក្រហមនៅមន្ទីរៗ (បណ្ណសារមជ្ឈមណ្ឌលឯកសារកម្ពុជា)*

**(តនៅលេខក្រោយ)**

# ការចងចាំពីថ្ងៃទី១៧ ខែមេសា

**ស៊ាង ចិន្តា**



ទិដ្ឋភាពនៅក្នុងក្រុងភ្នំពេញ នៅថ្ងៃទី១៧ ខែមេសា ឆ្នាំ២០២១។ (ស៊ាង ចិន្តា/មជ្ឈមណ្ឌលឯកសារកម្ពុជា)

ថ្ងៃនេះ កាលពី៤៦ឆ្នាំមុន កងទ័ពខ្មែរក្រហមបានចូលកាន់កាប់ទីក្រុងភ្នំពេញ។ ខ្មែរក្រហមបានបង្ខំប្រជាជនដែលរស់នៅក្នុងទីក្រុងភ្នំពេញឲ្យចាកចេញពីផ្ទះទៅកាន់ទីជនបទ។ ដោយពុំមានពេលវេលា គ្រប់គ្រាន់ដើម្បីរៀបចំសម្ភារប្រើប្រាស់ចាំបាច់ និងស្ថិតក្រោមការគំរាមកំហែងដោយកាំភ្លើងរបស់ខ្មែរក្រហម ប្រជាជនរស់នៅទីក្រុងភ្នំពេញ គ្មានជម្រើសអ្វីក្រៅពីការចាកចេញពីផ្ទះតែប៉ុណ្ណោះ។ មិនថាបុគ្គល នោះជានរណា ទាំងក្មេង ទាំងចាស់ ទាំងទន់ខ្សោយ និងទាំងឈឺថ្កាត់ ម្នាក់ៗត្រូវបានបង្ខំឲ្យធ្វើចាកចេញពីផ្ទះរបស់ខ្លួន និងធ្វើដំណើរនៅក្រោមការដុតកម្ដៅពីព្រះអាទិត្យក្នុងខែមេសា ឆ្នាំ១៩៧៥។

ថ្ងៃទី១៧ ខែមេសា គឺជាថ្ងៃទីក្រុងភ្នំពេញធ្លាក់ទៅក្នុងការគ្រប់គ្រងរបស់ខ្មែរក្រហម ព្រមទាំងជាថ្ងៃចាប់ផ្ដើមនៃរបបប្រល័យពូជសាសន៍ខ្មែរក្រហម។ ជារៀងរាល់ឆ្នាំនាថ្ងៃ១៧ ខែមេសា អ្នករស់រានមានជីវិត ពីរបបខ្មែរក្រហមតែងអញ្ជើញចូលរួមក្នុងពិធីរំឭកការចងចាំ, ចែករំលែករឿងរ៉ាវជីវិតជាមួយសិស្សានុសិស្ស និងធ្វើពិធីបង្សុកូលឧទ្ទិសកុសលផលបុណ្យ ជូនដល់អ្នកដែលបានបាត់បង់ជីវិតក្នុងរបបខ្មែរក្រហម។ ក្នុងអំឡុងពេលនៃការរីករាលដាលជំងឺរាតត្បាតកូវីដ១៩ អ្នកនៅរស់រានមានជីវិតពីរបបខ្មែរក្រហម អាចត្រឹមតែស្នាក់នៅក្នុងផ្ទះ និងធ្វើការរំឭកការចងចាំអំពីថ្ងៃទី១៧មេសា ពីព្រោះនៅតាមដង

ផ្លូវនានា គឺពុំមានមនុស្សធ្វើដំណើរ។ សាលារៀនបានបិទជាបណ្ដោះអាសន្ន។ ហាងនានាបានបិទទ្វារ។ ឯទីក្រុងភ្នំពេញត្រូវស្ថិតក្រោមការបិទខ្ទប់រយៈពេល២សប្ដាហ៍។

លោកតា ចាន់ ចេង អាយុ៨៨ឆ្នាំ គឺជាអ្នករស់រានមានជីវិតពីរបបខ្មែរក្រហម ប៉ុន្តែបានបាត់បង់ សមាជិកគ្រួសារមួយចំនួនបានលើកឡើងថា នេះគឺជាគ្រាដ៏លំបាកដែលយើងប្រឈមនិងស្វែងរកដំណោះស្រាយ ប៉ុន្តែខ្ញុំបានឆ្លងកាត់ការលំបាកជាច្រើនក្នុងរបបខ្មែរក្រហម» ។ លោកតា ចេង បានបន្ថែមទៀតថា «ចំពោះការប្រឈមនឹងការរីករាលដាលជំងឺកូវីដ១៩នេះ យើងម្នាក់ៗមានទំនួលខុសត្រូវបញ្ឈប់ជំងឺរាតត្បាតនេះ»។

អ៊ំស្រី ទី សុខៃ អាយុ៦១ឆ្នាំ គឺជាអ្នករស់រានមានជីវិតពីរបបក្រហមខ្មែរ បាននិយាយថាអ្វីដែលលំបាកបំផុតគឺការគិតដល់កូនៗនិងចៅៗ ដែលបានរស់នៅឆ្ងាយពីគាត់។ អ៊ំស្រី បានបន្ថែមថា «នៅក្នុងរបបខ្មែរក្រហមយើងរស់នៅក្នុងគុកឥតជញ្ជាំង និងគ្មានអាហារហូបចុកគ្រប់គ្រាន់ នឹងទុរទស្សន៍។ យើងអាចបាត់បង់ជីវិតនៅគ្រប់ពេលវេលា ប៉ុន្តែនៅពេលនេះ យើងគ្រាន់តែត្រូវស្នាក់នៅផ្ទះ និយាយប្រាប់អំពីរឿងរ៉ាវក្នុងរបបខ្មែរក្រហម និងអនុវត្តតាមការណែនាំរបស់ក្រសួងសុខាភិបាលដើម្បីការពារខ្លួនយើង»។

លោកតា ទេព សាវី អាយុ៦៩ឆ្នាំ គឺជាសិល្បករភ្លេងបុរាណខ្មែរ ដែលបានរស់រានមានជីវិតពីរបបខ្មែរក្រហម។ លោតា សាវី ដែលបច្ចុប្បន្នកំពុងរស់នៅក្នុងក្រុងកំពង់ចាម ខេត្តកំពង់ចាម មានទេពកោសល្យក្នុងការលេងភ្លេងបុរាណខ្មែរដោយប្រើឧបករណ៍ទ្រ។ លោកតា សាវី បាននិយាយថា សភាពស្ងប់ស្ងាត់នៅតាមដងផ្លូវនានាក្នុងក្រុងកំពង់ចាម និងទីក្រុងភ្នំពេញបានរំឭកលោកតាអំពីរឿងរ៉ាវជីវិតរបស់ខ្លួននៅក្នុងរបបខ្មែរក្រហម។ ទោះបីជាស្ថិតក្នុងកាលៈទេសៈដ៏លំបាកទាំងផ្នែកផ្លូវចិត្ត និងសេដ្ឋកិច្ច លោកតា សាវី នៅតែបន្តបន្លឺសំឡេងទ្រដែលគាត់បានបន្តលេងអស់រយៈពេល៤០ឆ្នាំកន្លងមកនេះ ដើម្បីបន្ធូរភាពតានតឹងនិងចៀសវាងការគិតច្រើនៗ។ លោកតា សាវី ក៏បានបញ្ជាក់ថា “ខ្ញុំមិនដឹងថាពេលណា ជំងឺកូវីដ១៩នេះបាត់ទៅវិញនោះទេ ក៏ប៉ុន្តែនៅក្នុងថ្ងៃទី១៧មេសា ខ្ញុំយកទ្ររបស់ខ្ញុំមកបន្លឺសំឡេង ដើម្បីជាការចងចាំ និងពញ្ញាក់ការរំឭកអំពីប្រវត្តិសាស្ត្រខ្មែរក្រហម ដែលរូបខ្ញុំផ្ទាល់បានឆ្លងកាត់ និងរស់រានមានជីវិត បើទោះបីជានៅក្នុងស្ថានភាពដ៏លំបាកនេះ ដែលយើងកំពុងប្រឈមមុខក៏ដោយ»។



ទិដ្ឋភាពនៅក្នុងក្រុងភ្នំពេញ នៅថ្ងៃទី១៧ ខែមេសា ឆ្នាំ១៩៧៥។
(ស៊ាង ចិន្តា/មជ្ឈមណ្ឌលឯកសារកម្ពុជា)



ទិដ្ឋភាពនៅក្នុងក្រុងកំពង់ចាមនៅថ្ងៃទី១៧ ខែមេសា ឆ្នាំ២០២១។
(ស៊ាង ចិន្តា/មជ្ឈមណ្ឌលឯកសារកម្ពុជា)











ទិដ្ឋភាពនៅក្នុងក្រុងកំពង់ចាម នៅថ្ងៃទី១៧ ខែមេសា ឆ្នាំ២០២១។ (ស៊ាង ចិន្តា/មជ្ឈមណ្ឌលឯកសារកម្ពុជា)





ការិយាល័យស្រាវជ្រាវ និងបណ្ណាល័យឯកសារខ្មែរក្រហម ខេត្តកំពង់ចាមនៃមជ្ឈមណ្ឌលឯកសារកម្ពុជា នៅថ្ងៃទី១៧ ខែមេសា ឆ្នាំ២០២១។ (ស៊ាង ចិន្តា/មជ្ឈមណ្ឌលឯកសារកម្ពុជា)

# ការចងចាំរបស់កងទ័ពខ្មែរក្រហមនៅ ថ្ងៃ ១៧ មេសា ឆ្នាំ១៩៧៥

ឡុង ដានី



*កងយោធាខ្មែរក្រហមចូលក្នុងទីក្រុងភ្នំពេញ ថ្ងៃទី១៧ ខែមេសា ឆ្នាំ១៩៧៥។ (បណ្ណសារមជ្ឈមណ្ឌលឯកសារកម្ពុជា)*

កាលពី៤៦ឆ្នាំមុន គឺនៅថ្ងៃទី១៧ ខែមេសា ឆ្នាំ១៩៧៥ កងទ័ពខ្មែរក្រហមបានចូលកាន់កាប់ទីក្រុងភ្នំពេញ។ បន្ទាប់ពីការចូលដល់ទីក្រុងភ្នំពេញបានប្រមាណជា៣ទៅ៤ម៉ោង មេដឹកនាំខ្មែរក្រហម បានបញ្ជាកងទ័ពឲ្យចាប់ផ្ដើមជម្លៀសប្រជាជនដោយបង្ខំចេញពីទីក្រុងភ្នំពេញ ទៅធ្វើការងារពលកម្មដ៏លំបាកវេទនានៅតាមវាលស្រែ នៃតំបន់ជនបទដាច់ស្រយាលនៃប្រទេសកម្ពុជា។ កងទ័ពខ្មែរក្រហមបានយកលេសដើម្បីជម្លៀសប្រជាជនចេញពីទីក្រុងភ្នំពេញថា សហរដ្ឋអាមេរិកនឹងមកទម្លាក់គ្រាប់នៅទីក្រុងភ្នំពេញ ប្រជាជនត្រូវជម្លៀសចេញពីទីក្រុងភ្នំពេញតែរយៈពេល២ទៅ៣ថ្ងៃនឹងបានវិលត្រឡប់មកផ្ទះវិញហើយ ដូច្នេះប្រជាជនមិនចាំបាច់ចាក់សោផ្ទះទេ។ ប៉ុន្តែការពិតខ្មែរក្រហមមិនបានអនុញ្ញាតឲ្យប្រជាជនត្រឡប់មកផ្ទះវិញពេញមួយរបបកម្ពុជាប្រជាធិបតេយ្យ (១៩៧៥-១៩៧៩)។ បន្ទាប់ពីដួលរលំនៅថ្ងៃទី៧ ខែមករា ឆ្នាំ១៩៧៩ ប្រជាជនជម្លៀសច្រើនលើសលប់បានស្លាប់ដោយសារការសម្លាប់ ការធ្វើការងារហួសកម្លាំង និងការអត់អាហារ។

អតីតកងទ័ពខ្មែរក្រហមចំនួន៣រូប ដែលបានចូលមកដល់ទីក្រុងភ្នំពេញនៅថ្ងៃ១៧ ខែមេសា ឆ្នាំ១៩៧៥ បានរំឭកឡើងវិញនូវអ្វីដែលបានកើតឡើងនៅទីក្រុងភ្នំពេញកាលថ្ងៃ១៧ ខែមេសា ឆ្នាំ១៩៧៥ ដូចខាងក្រោម៖



**ញឹម សឿន** អតីតកងទ័ពកងពលទី២ ភូមិភាគឧត្តរ បានរៀបរាប់ថា ខ្ញុំបានចូលមកដល់ទីក្រុងភ្នំពេញ តាមព្រែកក្តាមមកច្រាំងចំរេះ និងបន្តមកឈរជើងនៅម្តុំស្ពានជ្រោយចង្វារក្បែរស្ពានទូតបារាំង។ ពេលនោះខ្ញុំបានចូលរួមក្នុងការជម្លៀសប្រជាជនចេញពីទីក្រុងភ្នំពេញ ខ្ញុំសង្កេតឃើញប្រជាជនភាគច្រើនមានទឹកមុខស្រងូតស្រងាត់ ប្រជាជនខ្លះនៅស្តាយផ្ទះសម្បែង និងប្រជាជនខ្លះទៀតមានការភ័យខ្លាច។ នៅពេលជម្លៀសមានប្រជាជនច្រើនលើលប់ធ្វើដំណើរពេញដងផ្លូវទាំងអស់ និងមានប្រជាជនខ្លះបានស្លាប់នៅតាមផ្លូវ។ នៅមុខព្រួញរបស់ខ្ញុំប្រជាជនទាំងអស់ត្រូវជម្លៀសចេញពីភ្នំពេញតាមផ្លូវជាតិលេខ៥ ដោយប្រជាជនភាគច្រើនមានតែបង្វិចខោអាវ និងរបស់របរហូបចុកបន្តិចបន្តួចៗ។ កងទ័ពខ្មែរក្រហមបានដកហូតយកឡាន ម៉ូតូ មិនឲ្យប្រជាជនយកទៅជាមួយឡើយ។ ចំណែកមេទាហាននៃរបបសាធារណរដ្ឋខ្មែរ អ្នកសិល្បៈ និងអ្នកចំរៀង ត្រូវបានចាប់ខ្លួនប្រសិនបើកងទ័ពខ្មែរក្រហមបានស្គាល់អត្តសញ្ញាណ។ នៅខណៈពេលកំពុងជម្លៀសប្រជាជននោះ កងទ័ពខ្មែរក្រហមក៏បានដើរតាមផ្ទះប្រជាជន បើប្រជាជនណារឹងទទឹងមិនព្រមចាកចេញពីផ្ទះប្រជាជននោះនឹងត្រូវបាញ់សម្លាប់តែម្តង។ ប្រជាជនមួយចំនួនពេលបានឃើញកងទ័ពខ្មែរក្រហមបាញ់សម្លាប់ប្រជាជនដូច្នេះមានការភ័យខ្លាច និងបានចាកចេញពីផ្ទះសម្បែង។ នៅពេលនោះកងទ័ពមានតួនាទីហាមឃាត់ប្រជាជនមិនឲ្យយកឡានម៉ូតូទៅជាមួយ គឺយកតែរបស់របរណាស្រាលៗតាមខ្លួនតែប៉ុណ្ណោះ។ ការជម្លៀសប្រជាជនចេញពីទីក្រុងភ្នំពេញ គឺមានរយៈពេលប្រហែល៧ទៅ៨ថ្ងៃ ទើបស្ងាត់ពីទីក្រុងភ្នំពេញ។

នៅអំឡុងពេលជម្លៀសប្រជាជនចេញពីទីក្រុងភ្នំពេញនោះ ឡុង បូរ៉េត ដែលជាអតីតនាយករដ្ឋមន្ត្រីនៃរបបសាធារណរដ្ឋខ្មែរបានជិះទូកម្ចាគចក្រត្រឡប់មកចុះចតនៅស្តាតចាស់ក្បែរស្ពានទូតបារាំង។ នៅខណៈពេលនោះកងទ័ពខ្មែរក្រហមបានឡោមព័ទ្ធជុំវិញទូកម្ចាគចក្រ និងចាប់ខ្លួន ឡុង បូរ៉េត នៅពេលនោះតែម្តង។ ផ្ទះ ឡុង បូរ៉េត ស្ថិតនៅទល់មុខនឹងស្ពានទូតបារាំង។ នៅពេលប្រជុំប្រធានកងពលទី២ ឈ្មោះ សួង បាននិយាយថា ឡុង បូរ៉េត ជិះទូកម្ចាគចក្រត្រឡប់មកវិញនេះ គឺដើម្បីរៀបចំផែនការវាយបកមកលើកងទ័ពខ្មែរក្រហមវិញ។ បន្ទាប់មក ឡុង បូរ៉េត រួមជាមួយមេដឹកនាំនៃរបបសាធារណរដ្ឋខ្មែរមួយចំនួនទៀតត្រូវបានកងទ័ពខ្មែរក្រហមយកទៅសម្លាប់នៅតាមផ្លូវចូលពីវត្តសំរោងទៅខាងភ្នំបាសិទ្ធ។

---



**ចិន បឿន** បានរំឭកថា ខ្ញុំជាអតីតកងទ័ពនៃកងពល ១៤ ភូមិភាគពិសេស ប្រធាន និងអនុប្រធានកងពល ១៤ មានឈ្មោះ សូ សារឿន និង មាច សាន។ នៅថ្ងៃទី ១៧ ខែមេសា ឆ្នាំ១៩៧៥ កងទ័ពខ្មែរក្រហមក៏ទទួលបានជ័យជម្នះលើរបបសាធារណរដ្ឋខ្មែរ។ នៅខណៈពេលនោះ ខ្ញុំបានចូលមកទីក្រុងភ្នំពេញតាមពោធិ៍ចិនតុងរហូតដល់ផ្លូវកម្ពុជាក្រោមតាមពេទ្យលោកសង្ឃ និងបានស្នាក់នៅម្តុំសាលារៀនសន្ធរម៉ុក។ នៅពេលចូលដល់ភ្នំពេញភ្លាម ប្រធាន និងអនុប្រធានកងពលរបស់ពួកខ្ញុំបានទៅប្រជុំជាមួយថ្នាក់លើ។ បន្ទាប់ពីត្រឡប់មកពីប្រជុំវិញស្រាប់តែមានផែនការ ឲ្យជម្លៀសប្រជាពលរដ្ឋចេញពីទីក្រុងភ្នំពេញ។ រូបខ្ញុំដែលជាពេទ្យយោធា ត្រូវបានមេបញ្ជាការចាត់តាំងឲ្យនៅប្រចាំការនៅអគ្គភាព និងជួយរៀបចំផ្ទះសម្បែង។ ខ្ញុំឃើញប្រជាពលរដ្ឋបានចាកចេញពីផ្ទះមកតាមផ្លូវយ៉ាងច្រើនកុះករប្រហែលរយៈពេល ១០ថ្ងៃទើបចេញអស់ និងស្ងាត់ទីក្រុងភ្នំពេញតែម្តង។ ខ្ញុំបានឃើញមានទាំងទាហាន, មន្ត្រីរដ្ឋការ និងប្រជាជនធ្វើដំណើរតាមផ្លូវកម្ពុជាក្រោមឆ្ពោះទៅខាងពោធិ៍ចិនតុងដែលមានបង្វេចខោអាវ និងរបស់របរបន្តិចបន្តួចជាប់នឹងខ្លួនប្រកបដោយទឹកមុខភ័យខ្លាច និងព្រួយបារម្ភ។ បន្ទាប់មកប្រធានកងពលឈ្មោះ សូ សារឿន បានបញ្ជាពួកខ្ញុំឲ្យដើររើតាមផ្ទះប្រជាជនយករបស់របរ ដូចជា ទូរទឹកកក,

ម៉ាស៊ីនដេរ, កន្ត្រៃ មកទុកម្តុំៗ ក្រោយមកអង្គភាពរបស់ខ្ញុំត្រូវបានផ្លាស់ឲ្យទៅធ្វើស្រែនៅឃ្លាញ។ ចាប់តាំងពីពេលនោះមកខ្ញុំបានចូលមកទីក្រុងភ្នំពេញតែម្តងម្កាលដើម្បីបើកថ្នាំពេទ្យតែប៉ុណ្ណោះ។

---

**សេន យេន** អតីតកងទ័ពក្នុងកងពិសេស៨០៨ នៃកងពលទី១ ភូមិភាគឧត្តរ បានរៀបរាប់បន្តថា ខ្ញុំបានចូលដល់ទីក្រុងភ្នំពេញបន្ទាប់ពីកងទ័ពខ្មែរក្រហមទទួលជ័យជម្នះបានមួយថ្ងៃ។ ខ្ញុំបានដាសះស្បៀយពីរបួសជើង និងបានជិះឡានពីមន្ទីរពេទ្យនៅចំការអណ្តូងស្រុកចំការលើចូលមកភ្នំពេញតាមព្រែកព្នៅ។ នៅពេលនោះខ្ញុំបានឃើញប្រជាជនដើរចេញពីទីក្រុងភ្នំពេញតាមមុខសញ្ញាផ្លូវជាតិលេខ៥យ៉ាងច្រើនកុះករ។ ប្រជាជនខ្លះវង្វេងបាត់កូន បាត់ប្តី និងខ្លះមានតែបង្វិចខោអាវបន្តិចបន្តួចប៉ុណ្ណោះ។

ពេលខ្ញុំបានមកដល់អង្គភាពនៅជិតពេទ្យកាល់ម៉ែត្រ ខ្មែរក្រហមចាប់ផ្តើមធ្វើការឃោសនាតាមឧគ្ឃោសនសព្ទឲ្យអតីតមន្ត្រីរដ្ឋការ និងទាហាននៃរបបសាធារណរដ្ឋខ្មែរដែលមានឋានន្តរសក្តិចាប់ពីសក្តិបីឡើងទៅចុះឈ្មោះដើម្បីបានចូលធ្វើការងារដូចដើមវិញ។ តាមការពិតខ្មែរក្រហមចង់ប្រមូលយកមន្ត្រីរដ្ឋការ និងទាហានទាំងនោះទៅសម្លាប់ចោលតែប៉ុណ្ណោះ។ បន្ទាប់ពីខ្មែរក្រហមជម្លៀសប្រជាជនស្ងាត់ពីទីក្រុងភ្នំពេញ ខ្មែរក្រហមបានចាត់តាំងឲ្យអង្គភាពពិសេស ៨០៨ នៃកងពលទី១ យកមន្ត្រីរដ្ឋការ និងទាហានដែលបានចុះឈ្មោះទាំងអស់នោះទៅសម្លាប់នៅក្បែរអង់តែនទូរទស្សន៍ទួលគោកៗ នៅពេលនោះខ្មែរក្រហមបានចាត់តាំងខ្ញុំឲ្យជីករណ្តៅ ហើយកងទ័ពផ្សេងៗទៀតជាអ្នកយកមន្ត្រីរដ្ឋការ និងទាហានមកវាយទម្លាក់ក្នុងរណ្តៅដោយដែកសសៃរទំហំប៉ុនមេជើង។

ការសម្លាប់មន្ត្រីរដ្ឋការ និងទាហាននៃរបបសាធារណរដ្ឋខ្មែរមានរយៈពេលប្រហែល១០ថ្ងៃ។ ចំណែកសាកសពរាប់រយនាក់ត្រូវបានកប់នៅបរិវេណក្បែរៗ អង់តែនទូរទស្សន៍ទួលគោក ជិតដើមត្នោត និងតាមអណ្តូងនានានៅក្នុងវត្តញាណរង្សី ដែលស្ថិតនៅប៉ែកខាងអង់តែនទូរទស្សន៍ទួលគោកៗ បន្ទាប់មកកងពិសេស ៨០៨ នៃកងពលទី១ ត្រូវបានខ្មែរក្រហមបញ្ជូនទៅធ្វើជាកម្មករនៅកំពង់ផែកំពង់សោម។

អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជាបានរកឃើញថា នៅថ្ងៃ១៧ មេសា ឆ្នាំ១៩៧៥ ខ្មែរក្រហមបានជម្លៀសបង្ខំប្រជាជនចេញពីទីក្រុងភ្នំពេញយ៉ាងហោចណាស់ចំនួនប្រហែល ២លាននាក់ រួមមាន បុរស ស្ត្រី មនុស្សចាស់ ក្មេង ព្រះសង្ឃ វេជ្ជបណ្ឌិត គិលានុបដ្ឋាយិកា អ្នកជំងឺ អ្នករបួស ស្ត្រីទើបសម្រាលកូនៗ ប្រជាជនទាំងនោះមិនត្រូវបានខ្មែរក្រហមផ្តល់កន្លែងស្នាក់ និងស្បៀងអាហារហូបចុកគ្រប់គ្រាន់ ដែលជាហេតុនាំឲ្យមានការលំបាកវេទនា និងស្លាប់យ៉ាងច្រើនសន្ធឹកសន្ធាប់ៗ តាមការប៉ាន់ប្រមាណ មានប្រជាជនចំនួនចន្លោះពី ២ពាន់ ទៅ ២ម៉ឺននាក់ បានស្លាប់បាត់បង់ជីវិតនៅអំឡុងពេលបង្ខំឲ្យចាកចេញពីទីក្រុងភ្នំពេញ និងការធ្វើដំណើរតាមផ្លូវទៅកាន់ទីជនបទនានា។

មេដឹកនាំជាន់ខ្ពស់ខ្មែរក្រហម រួមមាន នួន ជា និង ខៀវ សំផន ត្រូវអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជាបានរកឃើញថាបានប្រព្រឹត្តឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ ដូចជា បទមនុស្សឃាត បទធ្វើទុក្ខបុកម្នេញដោយមូល









កងយោធាខ្មែរក្រហមចូលក្នុងទីក្រុងភ្នំពេញ ថ្ងៃទី១៧ ខែមេសា ឆ្នាំ១៩៧៥។ (បណ្ណសារមជ្ឈមណ្ឌលឯកសារកម្ពុជា)

ហេតុនយោបាយរួមទាំងអំពើអមនុស្សធម៌ផ្សេងៗទៀត ដែលជាប់ពាក់ព័ន្ធនឹងការជម្លៀសប្រជាជនចេញពីទីក្រុងភ្នំពេញនៅថ្ងៃ១៧ មេសា ឆ្នាំ១៩៧៥។ នៅថ្ងៃទី ២៣ ខែវិច្ឆិកា ឆ្នាំ២០១៦ នួន ជា និង ខៀវ សំផន ត្រូវបានអង្គជំនុំជម្រះតុលាការកំពូលបានសម្រេចផ្ដន្ទាទោសឲ្យជាប់ពន្ធនាគារអស់មួយជីវិត។

# ផ្នែកមួយនៃព្រឹត្តិការណ៍ថ្ងៃទី១៧ ខែមេសា ឆ្នាំ១៩៧៥

## នៅឃុំជីផុច និងឃុំអង្គរស ស្រុកមេសាង ខេត្តព្រៃវែង

**ផេង ពង្សរ៉ាស៊ី**

មុនឆ្នាំ១៩៧៥ ថ្ងៃទី១៧ ខែមេសា មិនត្រូវបានកំណត់នៅក្នុងប្រក្រតិទិនខ្មែរ ថាជាថ្ងៃបុណ្យជាតិ បុណ្យសាសនា ឬបុណ្យអ្វីឡើយ ប៉ុន្តែវាគ្រាន់តែជាថ្ងៃបន្ទាប់ពីរយៈពេលបីថ្ងៃនៃថ្ងៃចូលឆ្នាំប្រពៃណីជាតិខ្មែរ និងជាថ្ងៃដែលប្រជាជនកម្ពុជាចាប់ផ្តើមរៀបចំខ្លួន ដើម្បីបន្តបំពេញការងាររៀងៗខ្លួនសម្រាប់ឆ្នាំថ្មី រាប់ទាំងការសិក្សារបស់សិស្ស ការងាររបស់មន្ត្រីរាជការ ស្រែចម្ការ និងកិច្ចការផ្សេងទៀតប៉ុណ្ណោះ។

ក្នុងឆ្នាំ១៩៧៥ ថ្ងៃទី១៧ ខែមេសា ត្រូវបានមើលឃើញថា ជាថ្ងៃជ័យជម្នះរបស់ក្រុមកុម្មុយនីស្តខ្មែរក្រហម ដែលបានតស៊ូក្នុងព្រៃអស់រយៈពេលជាច្រើនឆ្នាំកន្លងមក។ ទាហានខ្មែរក្រហម បានវាយចូលទីក្រុងភ្នំពេញ និងគ្រប់គ្រងប្រទេសទាំងមូលនៅថ្ងៃទី១៧ ខែមេសា ឆ្នាំ១៩៧៥។ ជ័យជម្នះនេះ គឺជាកេរដំណែលនៃការតស៊ូវណ្ណៈ ក្រោមការជ្រោមជ្រែងនិងគាំទ្រពីកម្លាំងប្រជាជនកម្ពុជាជាច្រើននាក់ ដែលរស់នៅក្នុងមូលដ្ឋានដាច់ស្រយាលពីទីប្រជុំជននានានៃទឹកដីប្រទេសកម្ពុជា ក្នុងសម័យសង្គ្រាមរ៉ាំរ៉ៃដែលអូសបន្លាយពេលរាប់សិបឆ្នាំនៅកម្ពុជា និងជាពន្លឺដ៏ត្រចះត្រចង់នៃវណ្ណៈកសិករ ក្នុងឱកាសនៃការចាប់ផ្តើម ស្តារកសាង និងអភិវឌ្ឍប្រទេសជាតិ ដោយផ្អែកលើកម្លាំងពលកម្មរបស់ប្រជាជនសុទ្ធសាធក្នុងវិស័យកសិកម្មនិងឧស្សាហកម្ម ដោយមិនពឹងផ្អែកលើកម្លាំងបញ្ញា និងស្មារតី។

រយៈពេល៤៦ឆ្នាំនៃថ្ងៃ១៧មេសា មហាជោគជ័យរបស់ខ្មែរក្រហមបានកន្លងផុតទៅ។ ប្រក្រតិទិនខ្មែរសម្រាប់ឆ្នាំ២០២១ ក៏មិនបានកំណត់បង្ហាញពីថ្ងៃទី១៧ ខែមេសាថាជាថ្ងៃអ្វីទេ។ ក្មេងៗជំនាន់ក្រោយដែលមិនទាន់រៀនដល់ថ្នាក់មធ្យមសិក្សា ឬមិនទាន់បានសិក្សាពីប្រវត្តិសាស្ត្រខ្មែរក្រហម អាចមិនបានដឹងថា តើថ្ងៃ១៧មេសាជាពេលវេលាអ្វី ឬមានហេតុការណ៍អ្វីកើតឡើងក្នុងថ្ងៃនោះដែរ។ មានតែជនរងគ្រោះពីរបបខ្មែរក្រហមរាប់លាននាក់ដែលកំពុងរស់រានមានជីវិតនាពេលបច្ចុប្បន្នប៉ុណ្ណោះ ដែលនៅចងចាំយ៉ាងច្បាស់ពីព្រឹត្តិការណ៍ក្នុងថ្ងៃ១៧ មេសា ឆ្នាំ១៩៧៥។ ជារៀងរាល់ឆ្នាំ ទាំងបណ្តាញព័ត៌មាន និងប្រព័ន្ធផ្សព្វផ្សាយក្នុងស្រុក និងក្រៅស្រុកជាច្រើនបានចុះផ្សាយពីព្រឹត្តិការណ៍ថ្ងៃ១៧មេសា១៩៧៥ ដើម្បីជាការរំឭកដល់បទពិសោធន៍លំបាកៗជាច្រើន ដែលប្រជាជនកម្ពុជាទូទាំងប្រទេសបានជួបប្រទះ និងរងគ្រោះនៅក្នុងរបបខ្មែរក្រហម។ យុវវ័យជំនាន់ក្រោយជាច្រើននាក់ បានអាននិងទស្សនាពីការចុះផ្សាយទាំងនោះ ទោះបីជាអ្នកទាំងនោះបានស្វែងយល់ ឬមិនបានស្វែងយល់ឲ្យស៊ីជម្រៅពីព្រឹត្តិការណ៍ទាំងនេះក៏ដោយ។

ថ្ងៃ១៧មេសា១៩៧៥ នៅតែត្រូវបានរំឭកឡើងវិញ ដរាបណាអ្នករស់រានមានជីវិតពីរបបខ្មែរក្រហមនៅតែមានជីវិត ហើយក្មេងៗជំនាន់ក្រោយ នៅតែទទួលបានការសិក្សាស្វែងយល់ពីព្រឹត្តិការណ៍នេះគ្រប់ៗជំនាន់ ដរាបណាព្រឹត្តិការណ៍ថ្ងៃ១៧មេសា១៩៧៥ និងព្រឹត្តិការណ៍ឯទៀតនៃរបបខ្មែរក្រហម នៅតែត្រូវបានផ្សព្វផ្សាយ និងបង្រៀននៅតាមសាលារៀន។ គ្រូបង្រៀនចំនួន២៩នាក់ រស់នៅក្នុងឃុំចំនួនពីរក្នុងស្រុកមេសាង ខេត្តព្រៃវែង គឺឃុំជីផុចនិងឃុំអង្គរស បានផ្តល់កិច្ចសម្ភាសន៍ជាមួយ

មជ្ឈមណ្ឌលឯកសារកម្ពុជាក្នុងគម្រោងស្តីពីវេទិកាប្រវត្តិសាស្ត្រគ្រួសារ ដើម្បីចងក្រងបទពិសោធន៍ឆ្លងកាត់របបខ្មែរក្រហមរបស់គាត់។ គ្រូបង្រៀនទាំងអស់មានការចងចាំបានយ៉ាងល្អពីប្រវត្តិផ្ទាល់ខ្លួនឆ្លងកាត់របបខ្មែរក្រហម ក្នុងនោះការចងចាំពីរឿងរ៉ាវក្នុងថ្ងៃទី១៧ ខែមេសា ឆ្នាំ១៩៧៥ ក៏ត្រូវបានរៀបរាប់ប្រាប់ឲ្យដឹង ហើយត្រូវបានលើកយកមកអធិប្បាយដូចខាងក្រោម៖

ប្រជាជនគ្រប់ភូមិបានចូលរួមអបអរសាទរនឹងជ័យជម្នះ១៧មេសា១៩៧៥ ដែលបានប្រព្រឹត្តទៅនៅតាមទីកន្លែងដែលបានរៀបចំទុកដោយគណៈឃុំនិងគណៈស្រុក ដូចជា នៅតាមភូមិ និងនៅក្នុងបរិវេណវត្តអារាមជាដើម។ មនុស្សម្នាក្នុងភូមិជាច្រើននាក់ បានរូតរះធ្វើដំណើរទៅចូលរួមអបអរសាទរ និងស្វាគមន៍ចំពោះថ្ងៃជ័យជម្នះ១៧មេសា តាមការប្រកាសពីអាជ្ញាធរឃុំ និងស្រុក។ នៅតាមទីកន្លែងប្រារព្ធពិធីនីមួយៗ ពោរពេញទៅដោយការសប្បាយរីករាយ សើចក្អាកក្អាយ រាំច្រៀងតន្ត្រីសម័យ និងកន្លែងខ្លះមានប្រគុំតន្ត្រីបុរាណខ្មែរ ដូចជា ទ្រ ស្គរដៃ ឆៃយ៉ាំ និងចាប៉ី ទៀតផង។ លោកគ្រូ ជា សម័យ បច្ចុប្បន្នបង្រៀននៅសាលាបឋមសិក្សា ជីផុចបាននិយាយថា **«កាលហ្នឹង! ខ្ញុំមិនដឹងអីទេ ព្រោះខ្ញុំនៅក្មេង តែខ្ញុំក៏សប្បាយហ្នឹងថ្ងៃជ័យជម្នះ១៧មេសា ជាមួយគេដែរ»**។ បើតាមការឲ្យដឹងពីគ្រូបង្រៀននៅវិទ្យាល័យ អង្គរស ពីរនាក់រស់នៅក្នុងឃុំអង្គរស បានប្រាប់ថា ពិធីអបអរសាទរនិងស្វាគមន៍ ចំពោះថ្ងៃជ័យជម្នះនេះ គឺមិនត្រឹមតែបានធ្វើឡើងនៅតាមទីកន្លែងដែលបានកំណត់នោះទេ ប៉ុន្តែថែមទាំងបានហែរក្បួនពីភូមិមួយទៅភូមិមួយទៀត អមជាមួយការរាំច្រៀងយ៉ាងសប្បាយក្រៃលែង។ លោកគ្រូ ជុំ សុផល អាយុ៥៩ឆ្នាំ រស់នៅភូមិអង្គរស បាននិយាយ ព្រមទាំងបានសម្តែងទឹកមុខញញឹមញញែមថា «បែក១៧ មេសាភ្លាម យើងផ្អាកលើកប្រឡាយម៉ា (មួយ) ថ្ងៃពីរសិនរួចនាំគ្នាទៅទទួលជ័យជម្នះ១៧ មេសា និងបានចូលរួមដង្ហែរទៅកាន់វត្តពន្លៃទៀត។ អូយ! មានរាំមានច្រៀងទៀតណា៎។ សប្បាយនឹងការទទួលបានជ័យជម្នះនេះណាស់»។ អ្នកគ្រូ ប៉ែន សុគុណ សព្វថ្ងៃជានាយិកាវិទ្យាល័យ អង្គរស បានបន្ថែមថា **«អ្នកភូមិបានចូលរួមអបអរសាទរថ្ងៃជ័យជម្នះនៅវត្តអង្គរស រួចដង្ហែរបន្តទៅកាន់វត្តពន្លៃទៀត។ មានទាំងឆៃយ៉ាំ មានទាំងស្គរដង្ហែរទៅដែរ»** ។ អ៊ំប្រុស ជា ប៉ាក ជាអ្នករស់រានមានជីវិតម្នាក់រស់នៅភូមិស្រះតាអឹម ឃុំអង្គរស បានមានប្រសាសន៍ថា នៅភូមិស្រះតាអឹម ក៏មានរៀបចំពិធីអបអរសាទរ និងទទួលស្វាគមន៍ថ្ងៃជ័យជម្នះនេះដែរ។ មានទាំងឆៃយ៉ាំ ស្គរ រាំច្រៀង និងហូបអាហារជុំគ្នាយ៉ាងសប្បាយទៀតផង។ ដូចគ្នានឹងឃុំជីផុចដែរ អ្នកភូមិចូលរួមអបអរសាទរយ៉ាងសប្បាយអឹងកងចំពោះថ្ងៃជ័យជម្នះនេះ ព្រោះយល់ឃើញថា ជាថ្ងៃដែលខ្លួនបានរួចផុតពីការគ្រប់គ្រងរបស់លន់ នល់។ លោកគ្រូ ហំ គា ជាគ្រូបង្រៀននៅសាលាបឋមសិក្សា ជីផុច បានឲ្យដឹងថា គាត់បានឃើញអ្នកភូមិសប្បាយខ្លាំងណាស់ ហើយសភាពការណ៍ក្នុងភូមិ ក៏ពោរ


ជុំ សុផល អាយុ៥៩ឆ្នាំ គ្រូបង្រៀននៅវិទ្យាល័យអង្គរស រស់នៅភូមិអង្គរស ឃុំអង្គរស ស្រុកមេសាង ខេត្តព្រៃវែង។ (ផេង ពង្សរ៉ាស៊ី/មជ្ឈមណ្ឌលឯកសារកម្ពុជា)


ជា ប៉ាក អាយុ៧៨ឆ្នាំ រស់នៅភូមិស្រះតាអឹម ឃុំអង្គរស ស្រុកមេសាង។ (ផេង ពង្សរ៉ាស៊ី/មជ្ឈមណ្ឌលឯកសារកម្ពុជា)


ហំ គា អាយុ៥៣ឆ្នាំ គ្រូបង្រៀននៅសាលាបឋមសិក្សាជីផុច និងកូនស្រីឈ្មោះ គា នីតា ហៅ លក្ខិណា បច្ចុប្បន្នរស់នៅភូមិវាំង ឃុំជីផុច ស្រុកមេសាង ខេត្តព្រៃវែង។ (ផេង ពង្សរ៉ាស៊ី/មជ្ឈមណ្ឌលឯកសារកម្ពុជា)


ជា សម័យ ហៅ ម៉ៃ អាយុ៥៩ឆ្នាំ គ្រូបង្រៀននៅសាលាបឋមសិក្សាជីផុច បច្ចុប្បន្នរស់នៅភូមិវាំង ឃុំជីផុច ស្រុកមេសាង ខេត្តព្រៃវែង។ (ផេង ពង្សរ៉ាស៊ី/មជ្ឈមណ្ឌលឯកសារកម្ពុជា)

*ពេញទៅដោយភាពអ៊ូអរ រាំច្រៀង និងស្រែកជ័យឃោសៗ **«សប្បាយហ្នឹងគឺសប្បាយមែន ។ សប្បាយគ្រប់កន្លែងទាំងអស់ៗ រាំច្រៀង វ៉ៃស្គរ វ៉ៃប៉ោត មានទាំងទ្រអីហ្នឹងសប្បាយណាស់»** ។ លោកគ្រូចូលនិវត្តន៍ ហាស់ ឆឹម អាយុ៨០ឆ្នាំ រស់នៅភូមិនិងឃុំអង្គរសបានមានប្រសាសន៍ថា **«គណៈឃុំបានអនុញ្ញាតឲ្យពួកយើងកាប់ជ្រូក មាន់ទា និងវេចនំអន្សមហូប ដើម្បីទទួលថ្ងៃមហាជ័យជម្នះៗ ពួកយើងក្នុងភូមិសប្បាយគ្រប់ៗគ្នា»**ៗ*



*ហាស់ ឆឹម អាយុ៨០ឆ្នាំ រស់នៅភូមិអង្គរស ឃុំអង្គរស ស្រុកមេសាង ខេត្តព្រៃវែងៗ (ផេង ពង្សរ៉ាស៊ី/មជ្ឈមណ្ឌលឯកសារកម្ពុជា)*

*ក្នុងថ្ងៃដដែល ក្បួនហែរ អង្គមីទ្ទីញ ការរាំច្រៀង និងភ្លេងតន្ត្រីនានា ត្រូវបានផ្អាក និងបញ្ចប់យ៉ាងគក់គ្រហល់បំផុតៗ ស្គរ ចាប៉ី ទ្រ និងឆៃយ៉ាំត្រូវបានបំផ្លាញចោលគ្មានសល់ៗ អ្នកចូលរួមអបអរសាទរទាំងប៉ុន្មាន ត្រូវបានប្រាប់ឲ្យវិលត្រឡប់ទៅកាន់ផ្ទះសម្បែងរៀងៗខ្លួនវិញ និងចាប់ផ្តើមរៀបចំខ្លួនដើម្បីទទួលភារកិច្ចថ្មីៗ ព្រឹត្តិការណ៍នេះ បានកើតឡើងដូចៗគ្នានៅតាមឃុំនីមួយៗក្នុងស្រុកមេសាងៗ នៅក្នុងឃុំជីផុច លោកគ្រូ ហំ គា បានមានប្រសាសន៍ប្រាប់ថា **«សប្បាយ! អាហ្នឹងសប្បាយម៉ាពេលៗ តែមិនយូរទេ ខ្ញុំឃើញអត់យូរអញ្ចោះ មិនយូរយ៉ាងម៉េច? រយៈពេលក្រោយមក ស្រាប់តែក្រុមហ្នឹងដដែល ក្រុមរាំច្រៀងហ្នឹង ដូចថារាំច្រៀងលេងតែរយៈពេលប្រហែលជាម៉ា(មួយ)ម៉ោង ឬម៉ាម៉ោងកន្លះទៅ ២ ម៉ោងអញ្ចឹង! ស្រាប់តែទម្លាក់ទ្រ ទម្លាក់ស្គរ រាំជាន់បាក់ខ្ទេចអស់ៗ កម្ទេចចោលទាំងអស់តែម្តង ហើយក៏មិនដឹងដែរថា វាជាគោលការណ៍គេឲ្យកម្ទេចចោលទាំងអស់ឬយ៉ាងណាទេ ហើយខ្ញុំក៏មិនដឹងធ្វើម៉េចដែរ ដូចថា ភ្លើងឆេះឈុលអញ្ចឹងទៅ ក៏ពន្លត់ទៅវិញភ្លឹបតែម្តងៗ ដូចថាចាប់ពីពេលហ្នឹងមក វាដូចថាប្លែកៗរហូតមក»** ។ នៅឃុំអង្គរសឯណោះវិញ លោកគ្រូ ជុំ សុផល, អ្នកគ្រូ ប៉ែន សុគុណ, អ៊ំប្រុស ជា ប៉ាក, លោកគ្រូ ហាស់ ឆឹម និង លោកគ្រូ ជិន ថន បានមានប្រសាសន៍ដូចគ្នាថា ឧបករណ៍ភ្លេងទាំងឡាយត្រូវបានកម្ទេចចោលគ្មានសល់ ហើយអ្នកចូលរួមក្នុងពិធីទាំងប៉ុន្មាន បានវិលត្រឡប់មកកាន់ផ្ទះសម្បែងរៀងៗខ្លួនវិញ ជាមួយនឹងចម្ងល់ក្នុងចិត្តពីទង្វើរដែលបានកើតមានៗ **«កំពុងតែសប្បាយជុំគ្នាទទួលជ័យជម្នះនេះ ស្រាប់តែឃើញអ្នករាំច្រៀង អ្នកកាន់ស្គរ អ្នកកាន់ចាប៉ី ឆៃយ៉ាំ គេនាំគ្នាទម្លាក់ និងបោះចោលឧបករណ៍ទាំងនោះ រួចនាំគ្នារាំជាន់កម្ទេចចោល ហើយស្រែកថា លះបង់ឲ្យអស់! កម្ទេចសក្តិភូមិនាយទុនៗ ម្នាក់ៗនាំគ្នាស្រងាកចិត្តគ្រប់ៗគ្នា តែមិនហ៊ាននិយាយ រួចនាំគ្នាវិលត្រឡប់មកផ្ទះវិញ»**ៗ*



*ជិន ថន អាយុ៧៦ឆ្នាំសព្វថ្ងៃរស់នៅក្នុងភូមិស្រះតាអឹម ឃុំអង្គរស ស្រុកមេសាង ខេត្តព្រៃវែងៗ (ផេង ពង្សរ៉ាស៊ី/មជ្ឈមណ្ឌលឯកសារកម្ពុជា)*

*លោកគ្រូ ជិន ថន, អ៊ំប្រុស ជា ប៉ាក, លោកគ្រូ ម៉ាត់ កូយ និងគ្រូបង្រៀនមួយចំនួនទៀត បានរំឭកពីថ្ងៃដែលប្រជាជននាំគ្នាទៅចូលរួមអបអរសាទរនេះថា គឺក្នុងគោលបំណងទទួលស្វាគមន៍ចំពោះការយាងនិវត្តន៍របស់សម្តេចឪចូលក្នុងប្រទេសវិញ តាមការសន្យាពីក្រុមខ្មែររំដោះ ដែលបានសន្យាក្នុងរយៈពេលកន្លងមកៗ ម្នាក់ៗ បានកើតមានចម្ងល់គ្រប់ៗគ្នាថា ហេតុអ្វីបានជាពិធីអបអរសាទរមិនបានរំឭកដល់ឈ្មោះរបស់សម្តេចឪទាល់តែសោះៗ លោកគ្រូ ជិន ថន ជាគ្រូបង្រៀនចូលនិវត្តន៍ រស់នៅភូមិស្រះតាអឹម ឃុំអង្គរស បាននិយាយដូច្នេះថា **«គោលការណ៍ខ្ញុំ គឺទៅចូលរួមដើម្បីទទួលការវិលត្រឡប់របស់សម្តេចឪ ព្រោះគេបានប្រាប់ថា ពេលជ័យជម្នះទាំងស្រុងហើយ គេនាំសម្តេចឪចូលស្រុកវិញៗ ដល់ទៅមានណា! គេអត់មានស្រែកជយោសម្តេចឪផងៗ គេស្រែកតែជយោ ប៉ុល ពត សោះៗ ខ្ញុំខកចិត្តៗ អ្នកចូលរួមផ្សេងទៀតក៏ខកចិត្តដែរ»** ។ ចំណែកឯលោកគ្រូ ម៉ាត់ កូយ ជាគ្រូចូលនិវត្តន៍ រស់នៅក្នុងភូមិអង្គ្រង ឃុំអង្គរស ក៏មិនខុសពីលោកគ្រូ ហាស់ ឆឹម និងលោកគ្រូ ជិន ថន ដែរៗ គាត់មានការសោកស្តាយ*


ម៉ាត់ កូយ អាយុ៧១ឆ្នាំ សព្វថ្ងៃរស់នៅភូមិអន្ទ្រង ឃុំអន្ទរស ស្រុកមេសាង ខេត្តព្រៃវែង។ (ដេង ពង្សរ៉ាស៊ី/មជ្ឈមណ្ឌលឯកសារកម្ពុជា)

ចំពោះពេលវេលារបស់គាត់ក្នុងការគាំទ្រចលនាខ្មែររំដោះ ព្រោះគាត់បានគិតថា នៅពេលដែលទទួលបានជ័យជម្នះលើរបប លន់ នល់ រួចហើយ ប្រទេសជាតិពិតជាទទួលបានសុខសន្តិភាព ក្រោមការដឹកនាំរបស់សម្តេចឪដូចពេលមុនទៀត។ **«ពេលទទួលបានជ័យជម្នះ ១៧ មេសា ១៩៧៥ ហើយ យើងស្មានតែបានសេរីភាពពេញបរិបូរណ៌ហើយ។ តាមពិតវាផ្ទុយស្រឡះពីការប៉ាន់ស្មានរបស់យើង»** ។

ក្នុងនាមជាអ្នកអប់រំពីប្រវត្តិសាស្ត្រខ្មែរក្រហមម្នាក់ ជានិច្ចកាលខ្ញុំតែងតែពន្យល់ដល់ក្មេងៗ ជំនាន់ក្រោយពីព្រឹត្តិការណ៍ថ្ងៃទី១៧ ខែមេសា ឆ្នាំ១៩៧៥ ថាជាការបន្តបង្កើតចេញនូវព្រឹត្តិការណ៍ធំៗពីរគឺ ១) ថ្ងៃមហាជ័យជម្នះរបស់ខ្មែរក្រហម និង ២) ការប្រព្រឹត្តទៅនៃអំពើប្រល័យពូជសាសន៍នៅកម្ពុជា។ ការពន្យល់នេះ គឺជាការពន្យល់ដោយលើកអង្គហេតុនានានៃបរិបទប្រវត្តិសាស្ត្រជាក់ស្តែង ដែលបានកើតឡើងក្នុងចន្លោះថ្ងៃទី១៧ ខែមេសា ឆ្នាំ១៩៧៥ ដល់ថ្ងៃទី៦ ខែមករា ឆ្នាំ១៩៧៩ អមជាមួយនឹងឯកសារយោងរាប់លានទំព័រដែលមានតម្កល់នៅក្នុងបណ្ណសារមជ្ឈមណ្ឌលឯកសារកម្ពុជាសព្វថ្ងៃ ហើយដែលអង្គហេតុនិងឯកសារយោងទាំងនោះ បង្ហាញឲ្យឃើញពីព្រឹត្តិការណ៍ជាប្រវត្តិសាស្ត្រសំខាន់ៗ ចំនួន៤គឺ៖ (១) មានថ្ងៃជ័យជម្នះ១៧មេសា ទើបមានថ្ងៃប្រកាសជាផ្លូវការដោយសភាតំណាងប្រជាជនកម្ពុជា នៅខែមករា ឆ្នាំ១៩៧៦ នូវរបបដឹកនាំថ្មីមួយគឺ របបកម្ពុជាប្រជាធិបតេយ្យ និងការឡើងគ្រប់គ្រងប្រទេសដោយ ប៉ុល ពត មានឈ្មោះដើម សាឡុត ស។ (២) មានរបបកម្ពុជាប្រជាធិបតេយ្យ ដឹកនាំដោយ ប៉ុល ពត ទើបមានការផ្លាស់ប្តូរសង្គមតាមរបៀបរបបរស់នៅនិងការងារថ្មីមួយដែលមិនតម្រូវឲ្យប្រជាជនរស់នៅជុំគ្នា ធ្វើការហួសកម្លាំង និងបំបិទសិទ្ធិសេរីភាពពីធម្មជាតិរបស់មនុស្សសម្រាប់ការរស់រានមានជីវិត។ (៣) មានគំនិតក្នុងការផ្លាស់ប្តូរសង្គមថ្មី ទើបមានការអនុម័តនិងប្រើប្រាស់គោលនយោបាយជាយុទ្ធសាស្ត្រ ៨ ចំណុចរួមមាន ការជម្លៀសប្រជាជនដោយបង្ខំ ការបំបែកបំបាក់ក្រុមគ្រួសារ ការបំបិទការចរាចរណ៍រូបិយប័ណ្ណ ការបំបិទសាសនា និងវត្តអារ៉ាម ការបង្ខំឲ្យធ្វើការលើសពី ១២ម៉ោងក្នុងមួយថ្ងៃការធ្វើទារុណកម្ម ការបោសសម្អាតខ្មាំងនិងការធ្វើសង្គ្រាមជាមួយវៀតណាម និង (៤) មានការអនុវត្តគោលនយោបាយទាំង ៨ ចំណុច ទើបមានអំពើប្រល័យពូជសាសន៍កើតឡើងនៅកម្ពុជា។ មនុស្សប្រមាណពី១លាន៧សែននាក់ទៅ២លាន២សែននាក់ បានស្លាប់នៅក្នុងរបបកម្ពុជាប្រជាធិបតេយ្យ ក្រោមការដឹកនាំរបស់ ប៉ុល ពត។ មនុស្សប្រមាណ៥លាននាក់ទៀត មានសំណាងបានរួចរស់ជីវិតពីរបបកម្ពុជាប្រជាធិបតេយ្យបន្ទាប់ពីថ្ងៃរំដោះទី៧ ខែមករា ឆ្នាំ១៩៧៩។ មកដល់បច្ចុប្បន្ននេះ អ្នករស់រានមានជីវិតទាំង៥លាននាក់ បានបាត់បង់ជាបណ្តើរៗទៅតាមការវិវត្តរបស់ធម្មជាតិ ចាស់ជរា ជំងឺ និងគ្រោះធម្មជាតិ ហើយប្រវត្តិសាច់រឿងជាច្រើនក៏ត្រូវបានរលាយបាត់ជាមួយគ្នាដែរ។ នៅមានប្រវត្តិរឿងរ៉ាវយ៉ាងច្រើនទៀតដែលកំពុងស្ថិតនៅក្នុងអារម្មណ៍ និងវិញ្ញាណរបស់អ្នករស់រានមានជីវិតនាពេលបច្ចុប្បន្ន។ ព្រឹត្តិការណ៍ថ្ងៃ១៧មេសា១៩៧៥ នៅមិនទាន់បិទបញ្ចប់សាច់រឿងត្រឹមការអធិប្បាយខាងលើនេះទេ ព្រោះនៅមានមនុស្សរាប់លាននាក់ទៀតកំពុងតែរំឭកឡើងវិញពីព្រឹត្តិការណ៍នេះប្រាប់ខ្លួនឯងដោយស្ងាត់ស្ងៀម ហើយការរំឭកទាំងនេះ ពិតជាមិនអាចដឹងបានឡើយ ប្រសិនជាពុំមានការចង់ចេះចង់ដឹង ឬចង់ស្វែងយល់បន្ថែមពីសំណាក់ក្មេងៗជំនាន់ក្រោយទេ។

# មាស យឹម
## ពីគ្រូបង្រៀនក្នុងរបបសង្គមរាស្ត្រនិយមទៅជាកម្មាភិបាលសេដ្ឋកិច្ច ក្នុងសម័យខ្មែរក្រហម

*សូ ហាន់*



*រូបខាងឆ្វេង ជួរខាងក្រោម៖ មាស យឹម អាយុ៨០ឆ្នាំ សព្វថ្ងៃរស់នៅភូមិពេជ្ជីរតន៍ ឃុំចាម ស្រុកកំពង់ត្របែក ខេត្តព្រៃវែង ផ្តល់បទសម្ភាសន៍ពីចម្ងាយទាក់ទងនឹងជីវប្រវត្តិរបស់គាត់ តាមប្រព័ន្ធអ៊ីនធើណែតដោយប្រើប្រាស់កម្មវិធីហ្គូហ្គលមីត* (Google Meet) *ដល់បុគ្គលិកមជ្ឈមណ្ឌលឯកសារកម្ពុជា។ (ផេង ពង្សរ៉ាស៊ី/មជ្ឈមណ្ឌលឯកសារកម្ពុជា)*

តាមរយៈកញ្ចក់អេក្រង់កុំព្យូទ័រចេញពីការិយាល័យស្រាវជ្រាវ និងបណ្ណាល័យឯកសារខ្មែរក្រហម ខេត្តព្រៃវែង និងចេញពីមជ្ឈមណ្ឌលឯកសារកម្ពុជាក្នុងទីក្រុងភ្នំពេញ យើងបានមើលឃើញទឹកមុខរស់រាយរាក់ទាក់ញញឹមញញែម និងប្រកបដោយភាពស្និទ្ធស្នាលរបស់បុរសវ័យចំណាស់ម្នាក់ ដែលមានសក់ល្បាយអាចម៍ខ្លាថ្ងាសទូលាយ ពាក់អាវសដៃខ្លី កំពុងអង្គុយនៅក្រោមផ្ទះឈើមួយខ្នងនៅពីមុខកញ្ចក់អេក្រង់ទូរសព្ទដៃរបស់គាត់ ដែលកំពុងនិយាយមកកាន់ បុគ្គលិកមជ្ឈមណ្ឌលឯកសារកម្ពុជា អំពីជីវប្រវត្តិគាត់ដែលឆ្លងកាត់ច្រើនជំនាន់ តាំងពីអំឡុងឆ្នាំ១៩៥០រហូតមកដល់បច្ចុប្បន្ន។

គាត់មានឈ្មោះ មាស យឹម អាយុ៨០ឆ្នាំ រស់នៅភូមិពេជ្ជីរតន៍ ឃុំចាម ស្រុកកំពង់ត្របែក ខេត្តព្រៃវែង គឺជាគ្រូបង្រៀនចូលនិវត្តន៍ម្នាក់ដែលធ្លាប់បង្រៀននៅសាលាបឋមសិក្សាពេជ្ជីរតន៍ និងជាអតីតកម្មាភិបាលក្នុងមន្ទីរសេដ្ឋកិច្ចស្រុកកំពង់ត្របែកក្នុងចន្លោះឆ្នាំ១៩៧៥ ដល់ ១៩៧៨។

នៅវេលាម៉ោង៩ព្រឹក ថ្ងៃទី៦ ខែមេសា ឆ្នាំ២០២១ ក្រុមការងារនៃការិយាល័យស្រាវជ្រាវ និងបណ្ណាល័យឯកសារខ្មែរក្រហម ខេត្តព្រៃវែង បានភ្ជាប់បណ្តាញទំនាក់ទំនងជាមួយលោកគ្រូ មាស យឹម តាមប្រព័ន្ធអ៊ីនធើណែតដោយប្រើប្រាស់កម្មវិធីហ្គូហ្គលមីត (Google Meet) ដើម្បី

ស្នើសុំការសហការផ្តល់កិច្ចសម្ភាសន៍ពីចម្ងាយ ទាក់ទងនឹងជីវប្រវត្តិឆ្លងកាត់សម័យកាលជាច្រើនរបស់គាត់ៗ កិច្ចសម្ភាសន៍តាមប្រព័ន្ធអ៊ីនធើណែត បានចាប់ផ្តើមឡើងរវាងបុគ្គលិកមជ្ឈមណ្ឌលឯកសារកម្ពុជាបីរូប និងលោកគ្រូ មាស យីម ចាប់ពីម៉ោងប្រមាណ៩ព្រឹក រហូតដល់ម៉ោងជាង១១ពេលព្រឹកក្នុងថ្ងៃដដែលៗ

មាស យីម កើតនៅឆ្នាំ១៩៤១ នៅភូមិពេជ្ជីរតន៍ ឃុំចាម ស្រុកកំពង់ត្របែក ខេត្តព្រៃវែងៗ គាត់មានឪពុកឈ្មោះ មាស ភោគ និងម្តាយឈ្មោះ អុង ឈឿៗ គាត់គឺជាកូនទី៣ ក្នុងចំណោមបងប្អូន ៦នាក់ៗ យីម បានចាប់ផ្តើមការសិក្សានៅអាយុ១០ឆ្នាំ ក្នុងវត្តមួយនៅឯស្រុកកំណើត ហើយបញ្ចប់ការសិក្សានៅវិទ្យាល័យព្រះសូរិយាវង្ស ក្នុងខេត្តស្វាយរៀង នៅអាយុប្រហែល ២៥ឆ្នាំៗ នៅឆ្នាំ១៩៦៦ យីម បានប្រឡងជាប់គ្រូ និងបានចូលរៀននៅសាលាគរុកោសល្យ កំពង់កន្ទួត ស្រុកកណ្តាលស្ទឹង ខេត្តកណ្តាលៗ នៅឆ្នាំ១៩៦៨ យីម បានប្រឡងបញ្ចប់វគ្គគ្រូ បង្រៀន និងត្រូវបានបញ្ជូនឲ្យទៅធ្វើជាគ្រូបង្រៀននៅក្នុងខេត្តរតនៈគិរីៗ មួយឆ្នាំក្រោយមក គាត់បានស្នើសុំផ្លាស់ប្តូរមកបង្រៀននៅក្នុងសាលាបឋមសិក្សាព្រៃដង្ហុំ និងក្រោយមកទៀត ប្តូរមកសាលាបឋមសិក្សា ពេជ្ជីរតន៍ស្រុកកំពង់ត្របែក ដែលជាស្រុកកំណើតរបស់គាត់វិញៗ យីម បានពេញចិត្តនឹងជីវិតជាគ្រូបង្រៀនរបស់គាត់ និងបានស្ងើចសរសើរពីការដឹកនាំរបស់សម្តេចព្រះ នរោត្តម សីហនុ ក្នុងសម័យសង្គមរាស្ត្រនិយមថា បានផ្គាប់ចិត្តប្រជារាស្ត្រភាគច្រើនលើសលុបតាមរយៈការប្រារព្ធធ្វើអង្គសមាជជាតិ ដែលបានផ្តល់ឱកាសដល់ប្រជារាស្ត្រក្នុងការបញ្ចេញមតិយោបល់ពីទុក្ខកង្វល់ និងបញ្ហាផ្សេងៗដែលខ្លួនបានជួបប្រទះៗ យីម បានលើកឧទាហរណ៍ជាក់ស្តែងមួយ ដែលគាត់បានចូលរួមក្នុងអង្គសមាជជាតិដោយផ្ទាល់ ហើយគាត់នៅចងចាំមិនភ្លេចពីសកម្មភាពនោះ គឺសម្តេចព្រះ នរោត្តម សីហនុបានផ្តល់អព្យាក្រិត្យភាពមួយដល់ការផ្លាស់ប្តូរមុខតំណែងរដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច ពីឈ្មោះ ខៀវ សំផន ទៅឈ្មោះ និន នារ៉ុម វិញ ដោយសារតែតម្លៃសាច់គោឡើងថ្លៃពី២០រៀល ទៅ៤០រៀលក្នុងមួយគីឡូក្រាម ក្នុងអំឡុងទសវត្សរ៍ឆ្នាំ១៩៦០ តាម



មាស យីម អាយុ៨០ឆ្នាំ គឺជាគ្រូបង្រៀនចូលនិវត្តន៍ សព្វថ្ងៃរស់នៅភូមិពេជ្ជីរតន៍ ឃុំចាម ស្រុកកំពង់ត្របែក ខេត្តព្រៃវែងៗ (ផេង ពង្សរ៉ាស៊ី/មជ្ឈមណ្ឌលឯកសារកម្ពុជា)

សេចក្តីសម្រេចរបស់អង្គសមាជជាតិដែលមានប្រជារាស្ត្រចូលរួមគាំទ្រៗ យីម បានបន្តថា ប្រជាជនភាគច្រើនបំផុតបានពេញចិត្ត និងមានមោទកភាពចំពោះខ្លួនឯងថា ខ្លួនត្រូវបានលើកកម្ពស់ឲ្យចូលរួមដោះស្រាយកិច្ចការប្រទេសជាតិៗ និយាយដល់ត្រឹមនេះ យីម បានទម្លាក់ទឹកមុខបន្តិច រួចនិយាយបន្ត ពីការអាក់អន់ចិត្តពីសំណាក់ប្រជារាស្ត្រមួយចំនួនថា «នៅតែមានមនុស្សមួយចំនួនតូច ដែលភាគច្រើនចេញពីស្រទាប់គ្រូបង្រៀន មិនពេញចិត្តចំពោះការដឹកនាំរបស់សម្តេចឪទេ ហើយថែមទាំងបានងាកទៅគាំទ្រចលនាខ្មែរក្រហមវិញ ដូចជា ភោគ ឆាយ, ឈូក ម៉ឹងម៉ៅ, ភួង តុន និងទីវ អុល» ៗ ភោគ ឆាយ គឺជាប្រធានសមាគមន៍ និស្សិតខ្មែរនៅកម្ពុជាៗ ឯកសារលេខJ00៤៤៦ តម្កល់នៅក្នុងបណ្ណសារមជ្ឈមណ្ឌលឯកសារកម្ពុជា បានឲ្យដឹងថា ភោគ ឆាយ ធ្លាប់ត្រូវរដ្ឋាភិបាលសម័យសង្គមរាស្ត្រនិយមចាប់ដាក់ឃុំឃាំងជាមួយ ខៀវ សំផន, ហ៊ូ យន់ និង ហ៊ូ នឹម កាលពីឆ្នាំ១៩៦៧ ដោយសារទំនាស់ពាក្យសម្តីអំពីការតាំងពិព័រណ៍វត្ថុសិល្បៈចិនៗ ក្រោយមក ភោគ ឆាយ

ត្រូវបានដោះលែងមកវិញ និងបានចូលបម្រើក្នុងចលនាបដិវត្តន៍រហូតដល់ថ្ងៃដែលអង្គការចាប់ខ្លួននៅថ្ងៃទី១៨ ខែមីនា ឆ្នាំ១៩៧៧ មកដាក់នៅក្នុងមន្ទីរសន្តិសុខ ស-២១ និងត្រូវបានសម្លាប់ក្នុងរយៈពេលបន្តិចក្រោយមកទៀត។ រីឯ ឈូក ម៉ឺងម៉ៅ (ឯកសារខ្លះសរសេរឈ្មោះ ឈូក ម៉េងម៉ៅ) គឺជាចាងហ្វាងកិច្ចការគរុកោសល្យនៅទីក្រុងភ្នំពេញ ពីចន្លោះឆ្នាំ១៩៥៦ដល់១៩៦៧ និងជាអធិការអមទីស្តីការក្រសួងអប់រំ ពីចន្លោះឆ្នាំ១៩៦៨ និងឆ្នាំ១៩៦៩។ យោងតាមឯកសារចម្លើយសារភាពរបស់ ឈូក ម៉ឺងម៉ៅ បានឲ្យដឹងថា គាត់ត្រូវបានចាប់ខ្លួននៅថ្ងៃទី១៧ ខែធ្នូ ឆ្នាំ១៩៧៦ និងបានបញ្ជូនមកកាន់មន្ទីរស-២១ ពីបទក្បត់នឹងអង្គការបក្ស ដោយបានលួចលាក់បង្កប់កម្លាំងក្បត់ និងបង្កបង្កើតកម្លាំងក្បត់ក្នុងជួរបក្សជាបន្តបន្ទាប់ដើម្បីផ្តួលរំលំអង្គការបក្ស។ ចំណែកឯ ភូង តុន (ឯកសារខ្លះសរសេរឈ្មោះ ភឹង តុន) គឺជាសាកលវិទ្យាធិការសាកលវិទ្យាល័យ ភ្នំពេញ និងជាសាស្ត្រាចារ្យនិតិសាស្ត្រ។ នៅខែសីហា ឆ្នាំ១៩៦៨ ភូង តុន ត្រូវរដ្ឋាភិបាលសង្គមរាស្ត្រនិយមចាប់ខ្លួន និងឃុំខ្លួនអស់រយៈពេលមួយខែ ពីមូលហេតុថា មានគំនិតឆ្វេងនិយមប្រឆាំងនឹងការគ្រប់គ្រងរបស់សម្តេច សីហនុ។ នៅថ្ងៃទី១២ ខែធ្នូ ឆ្នាំ១៩៧៦ ភូង តុន ត្រូវបាននាំខ្លួនមកកាន់មន្ទីរស-២១ ក្នុងអំឡុងពេលដែលគាត់កំពុងចូលរួមវគ្គនយោបាយនៅបឹងត្របែក បន្ទាប់ពីគាត់ត្រូវបានបញ្ចុះបញ្ចូលឲ្យវិលត្រឡប់មកពីប្រទេសស៊ុីស ដើម្បីចូលរួមកសាងប្រទេសជាតិឡើងវិញ។ នៅអំឡុងខែកក្កដា ឆ្នាំ១៩៧៧ ភូង តុន ត្រូវបានសម្លាប់នៅក្នុងមន្ទីរស-២១។ ចំណែក ទីវ អុល គឺជានាយកអនុវិទ្យាល័យ អង្គខ្លុងទីរួមខេត្តព្រៃវែង។ យោងតាមឯកសារលេខ J00៥0២ មានចំណងជើង «ប្រវត្តិសកម្មភាពក្បត់របស់ ទីវ អុល ហៅ ពេញ» តម្កល់នៅក្នុងការិយាល័យស្រាវជ្រាវ និងបណ្ណាល័យឯកសារខ្មែរក្រហមខេត្តព្រៃវែង បានឲ្យដឹងថា ទីវ អុល បានចូលជាខ្មែរសេរីក្នុងឆ្នាំ១៩៥៧ ក្រោមការចាត់តាំងពីឈ្មោះ ឈូក ម៉ឺងម៉ៅ, ឆេង ផុន និង កុយ ធួន។ ទីវ អុល ចូលជាសមាជិក សេ.អ៊ី.អា នៅឆ្នាំ១៩៦១ និងបានកសាងកម្លាំង សេ.អ៊ី.អា ជាច្រើននាក់ តាមរយៈសិស្ស និងគ្រូ បង្រៀន។ នៅឆ្នាំ១៩៧៣ ទីវ អុល បានបើកវគ្គអប់រំចំនួនពីរដងនៅក្នុងភូមិភាគបូព៌ា ក្នុងគោលបំណងកសាងកម្លាំង សេ.អ៊ី.អា និងបង្កើនទំនាក់ទំនងខ្សែក្បត់ក្នុងភូមិភាគបូព៌ា។ ចាប់តាំងពីពាក់កណ្តាលឆ្នាំ១៩៦៨ រហូតដល់ខែមីនា ឆ្នាំ១៩៧៧ ទីវ អុល បានធ្វើកិច្ចការសំខាន់ៗជាច្រើនក្នុងជួរបដិវត្តន៍ទាក់ទងនឹងការងារអប់រំមនោគមវិជ្ជា និងកិច្ចការបរទេស។ នៅខែមេសា ឆ្នាំ១៩៧៧ អង្គការបានចាប់ខ្លួន ទីវ អុល និងបានបញ្ជូនគាត់ទៅកាន់មន្ទីរសន្តិសុខស-២១ ។ ក្នុងឆ្នាំ១៩៧៧ដដែល ទីវ អុល ត្រូវបានសម្លាប់ចោលដោយចោទប្រកាន់ថាបានបទក្បត់នឹងអង្គការបដិវត្តន៍។

យឹម គឺជាគ្រូបង្រៀនម្នាក់ដែលមិនជាប់ពាក់ព័ន្ធនឹងនិន្នាការនយោបាយដូចគ្រូបង្រៀនខ្លះទៀតឡើយ ប៉ុន្តែគាត់ក៏មិនពេញចិត្តចំពោះរដ្ឋាភិបាលដែលកើតចេញពីរដ្ឋប្រហាររបស់ លន់ នល់ ដែរ។ បន្ទាប់ពីរដ្ឋប្រហារថ្ងៃទី១៨ ខែមីនា ឆ្នាំ១៩៧០ យឹម នៅតែជាគ្រូបង្រៀនដដែល ហើយគាត់ត្រូវបានបញ្ចុះបញ្ចូលឲ្យប្រើប្រាស់អាវុធ ដើម្បីចូលរួមជួយការពារភូមិស្រុកពីការចូលលុកលុយរបស់កងទ័ព លន់ នល់។ យឹម បាននិយាយថា «រដ្ឋប្រហារទម្លាក់សម្តេចព្រះ នរោត្តម សីហនុ គឺជាពេលវេលាចាប់ផ្តើមកកើតសង្គ្រាមស៊ីវិល»។ ភូមិស្រុកដែលពុំធ្លាប់មានសង្គ្រាមបែរជាកើតមានសង្គ្រាម។ យុវជនដែលធ្លាប់តែរស់នៅប្រកបរបររកស៊ីធ្វើស្រែចម្ការនៅក្នុងភូមិ បែរជារត់ចូលព្រៃដើម្បីគេចពីគ្រាប់ផ្លោង និងស្ម័គ្រចិត្តចូលបម្រើបដិវត្តន៍តាមការអំពាវនាវរបស់សម្តេចឪពីប៉េកាំង។ គ្រូបង្រៀនមួយចំនួន បានងាកទៅរកការស្តារប្រទេសតាមរបៀបកុម្មុយនីស្តនិយម និងបានចូលរួមបម្រើក្នុងចលនាខ្មែររំដោះ។ យឹម ដែលធ្លាប់តែជាមនុស្សគិតគូរពីការបង្កើនចំណេះដឹងដល់សិស្សដោយមិនខ្វាយខ្វល់ពីបញ្ហានយោបាយ ក៏ត្រូវស្ទាក់ស្ទើរក្នុងចិត្តមួយរយៈពេល ហើយក្រោយមកក៏បានសម្រេច ចិត្តងាកទៅរកមាគ៌ាមួយដែលជាវិធីតែមួយគត់ក្នុងការស្តារស្ថានភាពប្រទេសកម្ពុជាឡើងវិញ នោះគឺការចូលរួមជាមួយចលនាបដិវត្តន៍តាមរយៈការរួបរួមកម្លាំងជាមួយរណសិរ្សរួបរួមជាតិកម្ពុជា ដែលមានសម្តេចព្រះ នរោត្តម សីហនុជាប្រធាន។ នៅឆ្នាំ១៩៧២ យឹម បានទទួលលិខិតមួយច្បាប់ពីឈ្មោះ ជ័យ សារិន ជាអនុប្រធានគណៈស្រុកកំពង់ត្របែក បញ្ចុះ

បញ្ចូលគាត់ឲ្យចូលរួមក្នុងចលនាបដិវត្តន៍ដើម្បីជួយរៀបចំស្រុកភូមិឡើងវិញ។ យឹម បានយល់ព្រមជាមួយ សារិន ហើយគាត់ក៏ទទួលបានការតែងតាំងជាកម្មាភិបាលមន្ទីរវប្បធម៌ស្រុកកំពង់ត្របែក មានភារកិច្ចរៀបចំភូមិឃុំក្នុងស្រុកកំពង់ត្របែក ដូចជា ឃុំចាម ឃុំព្រៃពោន ឃុំគោខ្ចក ឃុំជាងដែក និងឃុំជ្រៃ និងចាត់តាំងកម្មាភិបាលឲ្យធ្វើជាគ្រូបង្រៀន ព្រមទាំងប្រមែប្រមូលសិស្សឲ្យមករៀនតាមផ្ទះ និងក្រោមដើមឈើ។

នៅឆ្នាំ១៩៧៣ យឹម ត្រូវបានស្នើសុំឲ្យផ្លាស់ប្ដូរភារកិច្ចថ្មីទៅធ្វើការនៅក្នុងមន្ទីរសិល្បៈស្រុកកំពង់ត្របែកវិញ ដែលមានប្រធានសិល្បៈឈ្មោះ ស ទី ជាអ្នកគ្រប់គ្រង។ នៅទីនោះ យឹម បានទទួលភារកិច្ចសំខាន់ៗចំនួនពីរគឺ ១) ដឹកនាំការសម្ដែងសិល្បៈតាមភូមិឃុំ និង ២) បង្រៀនបច្ចេកទេសសិល្បៈដល់សិស្ស។ ទោះបីជា យឹម មិនមានជំនាញខាងសិល្បៈច្បាស់លាស់ក៏ដោយ ក៏គាត់បានព្យាយាមបង្ហាត់បង្រៀនសិស្សពីការសម្ដែងសិល្បៈតាមខ្លឹមសារដែលបក្សបានកំណត់ ក្នុងន័យបម្រើដល់វិស័យកសិកម្ម និងវិស័យកងទ័ព។ យឹម បានប្រាប់ថា «បក្សបានណែនាំថា ការបង្ហាត់បង្រៀនសិល្បៈគឺត្រូវបង្រៀនពីបច្ចេកទេសសិល្បៈ និងខ្លឹមសារបដិវត្តន៍ទាក់ទងនឹងការបង្កបង្កើនផលនិងការវាយខ្មាំង» ។

ចាប់តាំងពីឆ្នាំ១៩៧៤ រហូតដល់ឆ្នាំ១៩៧៨ យឹម ត្រូវអង្គការផ្លាស់ប្ដូរឲ្យទៅបម្រើការជាកម្មាភិបាលក្នុងមន្ទីរសេដ្ឋកិច្ចស្រុកកំពង់ត្របែក មានតួនាទីជាអ្នកគ្រប់គ្រងឃ្លាំងសម្ភារ និងស្រូវអង្ករប្រចាំស្រុកកំពង់ត្របែក។ យឹម តែងតែធ្វើរបាយការណ៍ផ្ញើទៅកាន់ថ្នាក់លើរបស់ខ្លួនពីៈ ១) ការទទួលស្រូវ អង្ករ ប្រេងកាត អំបិល និងសម្ភារផ្សេងៗចូលក្នុងមន្ទីរ និង ២) ការចែកចាយសម្ភារទាំងនោះទៅកាន់សហករណ៍នានា និងមូលដ្ឋានកងទ័ពក្នុងស្រុកកំពង់ត្របែក។ យឹម បានធ្វើកិច្ចការងារនេះមិនដែលមានកំហុសឆ្គងម្ដងណាឡើយ។ ស្ថិតក្រោមការគ្រប់គ្រងរបស់ខ្មែរក្រហមពីឆ្នាំ១៩៧៥ដល់១៩៧៨ យឹម មិនដែលទទួលរងការលំបាក ជួបប្រទះភាពអត់ឃ្លាន ឬត្រូវបង្ខិតបង្ខំឲ្យធ្វើការហួសកម្លាំងឡើយ ប៉ុន្តែគាត់បានប្រាប់ថា គាត់មានការហត់នឿយបន្តិចបន្តួចពីកិច្ចការសរសេររបាយការណ៍ប្រចាំសប្ដាហ៍ ប្រចាំខែ ប្រចាំត្រីមាស និងប្រចាំឆមាស ផ្ញើទៅកាន់ថ្នាក់លើ។ ក្រោយថ្ងៃទី៧ មករា ឆ្នាំ១៩៧៩ យឹម បានចូលបម្រើការងារជាគ្រូបង្រៀនម្ដងទៀត ហើយគាត់បានចូលនិវត្តន៍នៅឆ្នាំ១៩៩៨។

រយៈពេលជាង៤០ឆ្នាំកន្លងផុតទៅ យឹម នៅតែមានការចងចាំបានល្អពីបទពិសោធន៍ជីវិតរបស់គាត់។ គាត់តែងតែនិយាយរឿងរ៉ាវដែលបានកើតឡើងកាលពីអតីតកាល ប្រាប់ដល់កូនៗ គ្រូបង្រៀន និងអ្នកជិតខាងរបស់គាត់ ហើយអ្នកទាំងនោះមានការជឿជាក់ថា ព្រឹត្តិការណ៍ដែលបានកើតឡើងក្នុងភូមិឃុំដែលខ្លួនកំពុងរស់នៅ ពិតជាព្រឹត្តិការណ៍ប្រវត្តិសាស្ត្រដែលគួរចងចាំ និងរៀនសូត្រពីសំណាក់ក្មេងៗជំនាន់ក្រោយ។ សព្វថ្ងៃ យឹម មិនមានប្រកបរបរអ្វីទៀតទេ ក្រៅពីធ្វើបុណ្យទាន និងចាស់ព្រឹទ្ធាចារ្យក្នុងភូមិដែលជាទីពឹងពាក់អាស្រ័យនៃអ្នកភូមិ និងក្មេងៗជំនាន់ក្រោយ។



មាស យឹម (ផេង ពង្សរ៉ាស៊ី/មជ្ឈមណ្ឌលឯកសារកម្ពុជា)

## «ផេះផង់ធូលី»

# រឿងរ៉ាវចេញពីប្រជាជនថ្មីក្រោមរបបកម្ពុជាប្រជាធិបតេយ្យ

# ស៊ីវ សុខគា៖ អ្នកបើកតាក់ស៊ី

ប្រពន្ធខ្ញុំ និងខ្ញុំគឺជាកូនកាត់កម្ពុជា-ចិន ប៉ុន្តែយើងមិនអាចនិយាយភាសាចិនបាននោះទេ។ យើងមិនដែលបានជួបគ្នារហូតដល់ថ្ងៃមង្គលការរបស់យើង ទោះបីយើងគឺជាបងប្អូនជីដូនមួយដ៏ល្អម្នាក់ក៏ដោយ។ ឪពុកម្តាយរបស់យើងបានរៀបចំមង្គលការឲ្យយើង ហើយក្នុងនាមខ្ញុំជាកូនប្រុសរបស់គាត់ ខ្ញុំមិនមានសេចក្តីក្លាហានក្នុងការនិយាយតវ៉ាទៅកាន់ពួកគាត់នោះទេ។ ពិធីមង្គលការរបស់យើងត្រូវបានប្រារព្ធធ្វើឡើងតាមទំនៀមទម្លាប់ចិន និងខ្មែរ។ ឪពុកម្តាយរបស់យើងគឺជាអ្នកអភិរក្សនិយម ដូច្នេះហើយយើងបានស្លៀកសម្លៀកបំពាក់ប្រពៃណី។ ខ្ញុំបានស្លៀកសម្លៀកបំពាក់ត្រឹមតែមួយសម្រាប់ប៉ុណ្ណោះ ប៉ុន្តែប្រពន្ធរបស់ខ្ញុំបានស្លៀកសម្លៀកបំពាក់ពីរសម្រាប់ មួយសម្រាប់គឺជាពណ៌ក្រហម រីឯមួយសម្រាប់ទៀត គឺជាពណ៌ផ្កាឈូក។ បន្ទាប់ពីរបបខ្មែរក្រហម បងស្រីរបស់ខ្ញុំបានប្រាប់ខ្ញុំថា គាត់បានដោះដូរសម្លៀកបំពាក់អាពាហ៍ពិពាហ៍ជាមួយអង្ករ។ គាត់បានអរគុណខ្ញុំដោយនិយាយថា គាត់នឹងអត់ឃ្លានស្លាប់ប្រសិនបើគ្មានសម្លៀកបំពាក់នោះដើម្បីដោះដូរ។

ប្រពន្ធខ្ញុំបានកាន់កន្សែងដៃដើម្បីខ្ចប់លុយ ព្រោះស្ត្រីខ្មែរនៅពេលនោះមិនបានកាន់កាបូបជាញឹកញាប់នោះទេ។ គាត់បានដេរវាដោយខ្លួនឯងព្រោះគាត់ចូលចិត្តដេរ និងប៉ាក់។ គាត់បានប៉ាក់រូបផ្កាជាច្រើនប្រភេទលើសម្លៀកបំពាក់ និងខ្នើយ។



ស៊ីវ សុខគា និងប្រពន្ធ (បណ្ណសារមជ្ឈមណ្ឌលឯកសារកម្ពុជា)

យើងស្រឡាញ់គ្នាខ្លាំងណាស់។ បន្ទាប់ពីមង្គលការរបស់យើង យើងនៅមានកម្រិតជីវភាពមធ្យម។ គាត់នៅផ្ទះ ហើយមើលថែទាំកូនៗ ខណៈពេលដែលខ្ញុំលក់ស្ករត្នោតនៅឯផ្សារ។ នៅក្នុងរយៈពេលមួយឆ្នាំខ្ញុំបានលក់ស្ករត្នោតរាប់រយពាង ហើយទទួលបានប្រាក់កម្រៃជាច្រើន។

យើងបានផ្លាស់ប្តូរកន្លែងរស់នៅជាញឹកញាប់។ ដំបូងយើងរស់នៅក្នុងផ្ទះឪពុកម្តាយក្មេករបស់ខ្ញុំនៅខេត្តកំពង់ស្ពឺ ហើយបន្ទាប់មកក៏មកនៅភ្នំពេញ។ នៅទីបំផុតខ្ញុំបានសន្សំប្រាក់គ្រប់គ្រាន់ដើម្បីទិញឡានរត់តាក់ស៊ីពីភ្នំពេញទៅខេត្តបាត់ដំបង។

ខ្ញុំបានបើកឡានតាក់ស៊ីរបស់ខ្ញុំនៅដើមទសវត្សរ៍ ឆ្នាំ១៩៧០។ ទាហាន លន់ នល់ ជាច្រើនតែងតែបើកបរនៅពីមុខឡានខ្ញុំ ដើម្បីការពារសុវត្ថិភាពរបស់យើងពីព្រោះទាហានខ្មែរក្រហមនឹងឡោមព័ទ្ធយើងនៅតាមផ្លូវ។ ដោយសារតែស្ថានភាពកាន់តែអាក្រក់ ខ្ញុំបានឈប់រត់តាក់ស៊ីទៅផ្លូវបាត់ដំបង ហើយទិញឡានតូចថ្មីមួយជំនួសវិញ។ ខ្ញុំបានរត់តាក់ស៊ីនៅក្នុងទីក្រុងភ្នំពេញ។ នាយប៉មួយបងប្អូនជីដូនមួយរបស់ខ្ញុំបានអុជចង្កៀងប្រេងកាត ហើយក៏បានឆេះផ្ទះរបស់គាត់។ ពេលនោះមានខ្យល់បក់យ៉ាងខ្លាំងបណ្តាលឲ្យឆេះរាលដាល។ វាបានសម្លាប់កូនរបស់បងប្រុសខ្ញុំ ហើយបានបំផ្លាញផ្ទះចំនួន ១៧ខ្នង រួមទាំងផ្ទះរបស់ខ្ញុំ។ អ្វីដែលខ្ញុំនៅសេសសល់គឺឡានតូចរបស់ខ្ញុំ និងលុយនៅក្នុងហោប៉ៅរបស់ខ្ញុំ។ ខ្ញុំបានយកប្រាក់ដែលនៅសេសសល់ទៅទិញស្បែកជើងព្រោះខ្ញុំបានរត់ចេញពីផ្ទះដោយជើងទទេ។

ទាហាន លន់ នល់ បានឃុំខ្លួនយើងនៅក្នុងការិយាល័យសន្តិសុខមួយរយៈ បន្ទាប់ពីសង្ស័យថាគ្រួសារខ្ញុំគឺជាអ្នកដុតៗ កាសែតបានសរសេរអំពីព្រឹត្តិការណ៍នោះ ដោយនិយាយថា «ឡៅ សុខគា គឺជាជនជាតិចិនបានបង្កឲ្យមានអគ្គីភ័យ ដើម្បីផ្តល់ឱកាសឲ្យសត្រូវចូលមកក្នុងប្រទេស»ៗ

នៅថ្ងៃរំដោះក្នុងឆ្នាំ១៩៧៥ គ្រាប់បែកជាច្រើនត្រូវបានទម្លាក់នៅក្បែរផ្ទះរបស់ខ្ញុំៗ ប្រជាជនមិនអាចធ្វើដំណើរទៅណាបានទេ ដូច្នេះខ្ញុំក៏ឈប់រត់គាក់ស៊ីតទៅទៀតៗ ខ្ញុំបានយកសម្លៀកបំពាក់អាពាហ៍ពិពាហ៍របស់ខ្ញុំ ទៅផ្ញើទុកនៅផ្ទះបងប្អូនជីដូនមួយរបស់ខ្ញុំនៅភ្នំពេញ មុនពេលដែលគ្រួសារខ្ញុំត្រូវបានជម្លៀសចេញៗ ខ្ញុំបានជួលទូកទៅភូមិកំណើតប្រពន្ធរបស់ខ្ញុំ ប៉ុន្តែយោធាខ្មែរក្រហមបញ្ជាឲ្យយើងទៅខេត្តកណ្តាលជំនួសវិញៗ

ប្រពន្ធរបស់ខ្ញុំបានរកស៊ីដូរញដូរៗ នៅពេលដែលយើងទៅដល់ខេត្តកណ្តាលដំបូង គាត់បានដូរអង្ករចំនួនបីតៅ ដែលគាត់បានយកមកពីផ្ទះដើម្បីដូរមាសៗ ក្រោយមក គាត់បានដូរមាសនោះយកអង្ករបានច្រើនជាងមុនទៀតៗ ប៉ុន្តែនៅពេលអង្គការចាប់ផ្តើមមានសហករណ៍ វានៅសល់របស់តិចតួចដើម្បីជំនួញដូរៗ ខ្ញុំមិនអាចបំពេញក្រពះរបស់ខ្ញុំបានឆ្អែតនោះទេ ដោយហូបតែបបរ និងបន្លែប៉ុណ្ណោះៗ មិនមានសាច់ហើយសម្បុរគឺមើលទៅគួរឲ្យខ្លាចៗ

យើងបានខិតខំធ្វើការៗ មានពេលមួយកូនប្រុសខ្ញុំមិនបានទៅធ្វើការនៅវាលស្រែទេ ដូច្នេះមានកម្មាភិបាលម្នាក់បានដាក់ទោសវាៗ កម្មាភិបាលបានរុញក្បាលកូនប្រុសរបស់ខ្ញុំចូលទៅក្នុងទឹក ដាក់កន្ទុយបារីលើខ្លួនកូនប្រុសរបស់ខ្ញុំ ហើយបន្ទាប់មកដាក់ស្រមោចឲ្យខាំវាៗ ខ្ញុំបានលួងលោមកូនប្រុសរបស់ខ្ញុំ ហើយបានប្រាប់វាឲ្យទៅធ្វើការនៅឯចម្ការដើម្បីកុំឲ្យវាទទួលទោសម្តងទៀតៗ ការរស់នៅជាមួយប្រជាជនមូលដ្ឋានបានធ្វើឲ្យគ្រួសារខ្ញុំមានបញ្ហាជាច្រើនៗ អ្នកជិតខាងបានហៅយើងថា «អាចិន» ដោយសារតែស្បែករបស់ខ្ញុំមើលទៅដូចជនជាតិចិនៗ អង្គការបានចំអកដាក់ខ្ញុំនូវពាក្យទាំងនេះ ហើយបានបញ្ជាឲ្យខ្ញុំឲ្យលើករងដាំដំណាំឲ្យបានចំនួន២៥រងក្នុងមួយថ្ងៃៗ ពួកគេបាននិយាយថា ប្រសិនបើខ្ញុំមិនអាចបំពេញភារកិច្ចនេះបានទេ ខ្ញុំនឹងត្រូវបានយកទៅសម្លាប់ៗ មុនឆ្នាំ១៩៧៩ អង្គការបានស្នើឲ្យអ្នកភូមិទាំងអស់ចូលរួមការប្រជុំនៅក្នុងព្រៃនៅវេលាប្រហែលម៉ោង ៣ ឬ៤ព្រឹកៗ ខ្ញុំនៅទីវាល ប៉ុន្តែនៅពេលប្រពន្ធរបស់ខ្ញុំមកដល់ គាត់ក៏បានឃើញកម្មាភិបាលកំពុងតែរត់ទៅទិសដៅផ្សេងៗគ្នា ហើយបានឮសំឡេងកាំភ្លើង និងគ្រាប់បែកទម្លាក់នៅក្បែរនោះៗ កម្មាភិបាលម្នាក់បាននិយាយថា «សូមកុំបារម្ភអីការប្រយុទ្ធគ្នាគឺនៅតាមព្រំដែននោះទេ»ៗ ប៉ុន្តែមិនយូរប៉ុន្មានអ្នកភូមិទាំងអស់បានចាប់ផ្តើមជួបជុំគ្នារត់ៗ គាត់ និងកូនៗបានរត់មករកខ្ញុំហើយ យើងក៏បានជួបជុំគ្នាវិញៗ

នៅថ្ងៃរំដោះខ្ញុំបានឃើញឯកសាររបស់ខ្មែរក្រហមដែលមានឈ្មោះរបស់ខ្ញុំនៅលើនោះៗ នៅលើឯកសារបាននិយាយថាខ្ញុំគឺជាអតីតទាហាន ហើយប្រពន្ធរបស់ខ្ញុំគឺជាកម្មករខ្ចិលច្រអូសៗ វាបានប្រាប់ឈ្មោះប្រជាជនមូលដ្ឋានពីរនាក់ ដែលបានរាយការណ៍មកខ្ញុំៗ ខ្ញុំមិនដែលមានជម្លោះជាមួយនរណាម្នាក់នោះទេ ដូច្នេះខ្ញុំមិនយល់ពីមូលហេតុដែលប្រជាជនទាំងនេះធ្វើបាបខ្ញុំៗ

សូម្បីតែថ្ងៃដែលខ្ញុំស្អប់ពាក្យថា «សមមិត្ត» ដែលត្រូវបានប្រើជាញឹកញាប់នៅក្នុងការប្រជុំជាមួយខ្មែរក្រហមៗ ពេលខ្លះខ្ញុំបានឮវាតាមទូរទស្សន៍ហើយ ខ្ញុំបានបិទវាភ្លាមៗៗ ខ្ញុំមិនចង់ឮពាក្យនេះជាថ្មីម្តងទៀតនោះទេៗ

**ប៉ាង ពីច័ន្ទ និង ខេនី ខករម្ភៀល**



ស៊ីវ សុខគា និងប្រពន្ធ
នៅថ្ងៃរៀបការ
(បណ្ណសារមជ្ឈមណ្ឌល
ឯកសារកម្ពុជា)

រូបក្របមុខ៖

រថយន្តសង្គ្រោះបន្ទាន់របស់ក្រុមគ្រូពេទ្យ
បើកកាត់វិមានឯករាជ្យ
នៅថ្ងៃទី១៧ ខែមេសា ឆ្នាំ២០២១។
(សន លាក់/មជ្ឈមណ្ឌលឯកសារកម្ពុជា)

រូបក្របក្រោយ ៖

សត្វក្របីនៅវិមានឯករាជ្យ។
ប្រជាជនបានវិលត្រឡប់មកផ្ទះសម្បែងវិញ
បន្ទាប់ពីរបបខ្មែរក្រហមបានដួលរលំ
នៅថ្ងៃទី៧ ខែមករា ឆ្នាំ១៩៧៩។
(បណ្ណសារមជ្ឈមណ្ឌលឯកសារកម្ពុជា)



**មជ្ឈមណ្ឌលឯកសារកម្ពុជា ៖ ការិយាល័យព័ត៌មានសាធារណៈ**

ផ្ទះលេខ៦៦ មហាវិថីព្រះសីហនុ រាជធានីភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា ទូរសព្ទ៖ (៨៥៥) ២៣ ២១១ ៨៧៥

DC-Cam/PIR: #66 ◆ Preah Sihanouk Blvd ◆ Phnom Penh ◆ Cambodia ◆ Tel: (855) 23 211 875 ◆ dccam@online.com.kh ◆ www.dccam.org

A magazine of the Documentation Center of Cambodia: Searching for the Truth ◆ Issue 256, April 2021 ◆ Funded by USAID

Licensed by the Ministry of Information of the Kingdom of Cambodia, Prakas No. 375 P.M. PRA. KA, 30 October 2018.